# ការវិភាគស្ថានភាព ជនមានអូទីស្សឹម នៅកម្ពុជា

ខែឧសភា ឆ្នាំ២០២២

រៀបចំដោយ

University of Northampton

# មាតិកា


| | | |
|---|---|---|
| អារម្ភកថា | | ២ |
| សេចក្ដីថ្លែងអំណរគុណ | | ៣ |
| ស្ថានភាពនៃរបាយការណ៍ | | ៤ |
| សង្ខេបគម្រោង | | ៤ |
| និយមន័យ និងអត្រាប្រេវ៉ាឡង់នៃអូទីស្សឹម | | ៤ |
| ការអភិវឌ្ឍក្រុមការងារ | | ៥ |
| វិធីសាស្ត្រដែលបានប្រើប្រាស់ | | ៥ |
| ការងារចុះមូលដ្ឋានកន្លងមក | | ៦ |
| បញ្ហាប្រឈមក្នុងអំឡុងពេលអនុវត្តគម្រោង និងដំណោះស្រាយ | | ២៤ |
| របកគំហើញបឋម | | ២៥ |
| អនុសាសន៍ | | ៣៦ |
| **ឧបសម្ព័ន្ធ** | | **៤០** |
| ឧបសម្ព័ន្ធទី១៖ | សមាជិកក្រុម | ៤០ |
| ឧបសម្ព័ន្ធទី២៖ | ឯកសារដែលត្រូវបានពិនិត្យ សិក្សា និងវិភាគ | ៤១ |
| ឧបសម្ព័ន្ធទី៣៖ | ក្រមសីលធម៌ និងទម្រង់នៃកិច្ចព្រមព្រៀង | ៤៣ |
| ឧបសម្ព័ន្ធទី៤៖ | ឧបករណ៍ស្រាវជ្រាវសម្រាប់អ្នកផ្ដល់ និងអ្នកប្រើប្រាស់សេវា | ៤៤ |
| សេចក្ដីបន្ថែមទី៥: | សៀវភៅណែនាំអំពីរោគវិនិច្ឆ័យ និងស្ថិតិនៃវិបត្តិផ្លូវចិត្ត បោះពុម្ពលើកទីប្រាំ (DSM-5) និយមន័យអូទីស្សឹម | ៤៨ |

# អារម្ភកថា




ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការនៅខែធ្នូ ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការគ្រប់បែប យ៉ាងដើម្បីជាឧត្តមប្រយោជន៍សម្រាប់ជនមានពិការភាពបាន ចូលរួមដោយស្មើភាពរាល់សកម្មភាពទាំងអស់នៅក្នុងសង្គម។ បច្ចុប្បន្ននេះ សេចក្តីព្រាងច្បាប់ជាតិថ្មីស្តីពីកិច្ចគាំពារសិទ្ធិជន មានពិការភាពកំពុងត្រូវបានរៀបចំ ក្នុងគោលបំណងកំណត់ អំពីកិច្ចការពារ ការលើកកម្ពស់ និងការធានាការទទួលបាន ពេញលេញនិងស្មើភាពគ្នានូវសិទ្ធិ និងសេរីភាពរបស់ជនមាន ពិការភាព ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា វិស័យពិការភាពបាននឹងកំពុងអភិវឌ្ឍន៍គួរ ឱ្យកត់សំគាល់រួមមាន៖ប្រសិទ្ធភាពនៃការកសាង ការអនុវត្ត ច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ ផ្សេងៗ ការផ្តល់និងការបង្កលក្ខណៈងាយស្រួលដល់ជនមាន ពិការភាពក្នុងការទទួលបានសេវានានានិងការសម្របសម្រួល ឱ្យមានការចូលរួមរបស់អង្គការតំណាងជនមានពិការភាពទាំង ក្នុងការរៀបចំនិងការអនុវត្តបទដ្ឋានគតិយុត្តជាតិពាក់ព័ន្ធ។ល។

ទន្ទឹមនឹងការរីកចម្រើនលើវិស័យពិការភាព ក៏មានបញ្ហា ប្រឈមមួយចំនួន រួមមានកង្វះនៃទិន្នន័យពិការភាព និងកង្វះ នៃបទដ្ឋានគតិយុត្តជាក់លាក់ទាក់ទងនឹងជនមានអូទីស្សឹម។

តាមរយៈភាពជាដៃគូរវាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា សកម្មភាពជនពិការ (DAC-SG) និងកម្មវិធីសហប្រតិបត្តិការ អូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តភាព និង សមធម៌ (ACCESS) បានរៀបចំក្រុមការងារជំនាញនិងមាន បទពិសោធន៍ លើវិស័យពិការភាព ជាពិសេសការងារអូទីស្សឹម ដើម្បីធ្វើការសិក្សាពីស្ថានភាពជនមានអូទីស្សឹមនៅកម្ពុជា និង ផ្តល់ជាអនុសាសន៍នានាក្នុងការពង្រឹងសេវាគាំទ្រ រួមមានជា អាទិ៍ ការអប់រំ ការស្តារលទ្ធភាពពលកម្ម និងការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈ។

តាងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជន ពិការ ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះក្រុមការងារជំនាញ ដែលបានបញ្ចប់របាយការណ៍ខាងក្រោមស្តីពីការវិភាគស្ថាន ភាពជនមានអូទីស្សឹមនៅកម្ពុជាប្រកបដោយជោគជ័យ ដើម្បី ជាចំណែកមួយដ៏សំខាន់សម្រាប់រៀបចំផែនការសកម្មភាពលើ ការងារអូទីស្សឹមនៅកម្ពុជា។

ខ្ញុំសូម ឯកឧត្តម លោកជំទាវ លោក លោកស្រីបន្តការខិត ខំប្រឹងប្រែងបន្ថែមទៀតក្នុងការពង្រឹងកិច្ចសហការជាអន្តរវិស័យ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលនយោបាយ ដែលផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់ជនមានអូទីស្សឹម និងពង្រឹងប្រសិទ្ធភាព នៃការផ្តល់សេវាគាំទ្រនានា រួមមាន សេវាអប់រំ សេវាស្តារលទ្ធភាពពលកម្ម និងការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈដើម្បីគាំទ្រពួកគេបានចូលរួមពេញលេញជាមួយ រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រនិងការកសាងសង្គម មួយប្រកបដោយស្មើភាព ស្មើសិទ្ធិ និងបរិយាបន្ន។

ថ្ងៃច័ន្ទ ២ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២

**ឯម ច័ន្ទមករា**

# សេចក្តីថ្លែងអំណរគុណ

របាយយការណ៍ស្តីពីការវិភាគស្ថានភាពជនមានអូទីស្សឹម នៅកម្ពុជា បានរៀបចំឡើងដោយក្រុមការងារទីប្រឹក្សា ដែលមានលោកសាស្ត្រាចារ្យ Richard Rose លោកសាស្ត្រាចារ្យ Emeritus មកពីនាយកដ្ឋានអប់រំបរិយាបន្ននៃសាកលវិទ្យាល័យ Northampton នៃប្រទេសអង់គ្លេស សម្រាប់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានកិច្ចសហការណ៍ជាមួយមជ្ឈមណ្ឌលថៃទាំសុខភាពផ្លូវចិត្តកុមារនិងក្មេងជំទង់ (Caritas-CCAMH) ក្រោមជំនួយឧបត្ថម្ភពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ ( កម្មវិធីACCESS ) ។

យើងខ្ញុំសូមថ្លែងអំណរគុណ លោកសាស្ត្រាចារ្យ Richard Rose ចំពោះតួនាទីដ៏សំខាន់របស់គាត់ក្នុងការសម្របសម្រួល និងរៀបចំការវិភាគស្ថានភាពនេះឡើង ដោយមានការចូលរួមពីលោកវេជ្ជបណ្ឌិត Bhoomikumar Jegannathan គ្រូពេទ្យឯកទេសវិកលវិទ្យាកុមារ និងក្រុមវិជ្ជាជីវៈរបស់គាត់ផ្នែកសុខភាពផ្លូវចិត្ត ដែលមានកញ្ញាវេជ្ជបណ្ឌិត ម៉ុង ដាលីន គ្រូពេទ្យឯកទេសវិកលវិទ្យា លោកស្រី សុខ ឡៅរ៉ូហ្សេត និងលោកប៉ាត ពុទ្ធី ជាគ្រូពេទ្យឯកទេសចិត្តវិទ្យា ដែលកំពុងបម្រើការងារនៅអង្គការ Caritas-CCAMH ។ ពួកគេបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់រកអ្នកដែលត្រូវចូលរួមសម្ភាសន៍ រួមទាំងការប្រមូលនិងការវិភាគទិន្នន័យ ។ ការសិក្សាស្រាវជ្រាវនេះបានអនុវត្តឡើងក្នុងបរិបទនៃវិបត្តិសុខភាពជាសកលនៃជំងឺកូវីដ-១៩ រួមទាំងការអនុវត្តនូវវិធានការណ៍បិទខ្ទប់ផ្សេងៗ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមការងារនៅតែអាចបន្តអនុវត្តការសិក្សាស្រាវជ្រាវនេះបាន ដោយបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការណ៍ការពារផ្សេងៗក្រោមការណែនាំពីអាជ្ញាធរមូលដ្ឋាននិងក្រសួងសុខាភិបាល ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី តាមរយៈកម្មវិធីACCESS សម្រាប់ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសក្នុងការរៀបចំការសិក្សាស្រាវជ្រាវនិងការបោះពុម្ពឯកសារដ៏មានសារៈសំខាន់នេះ ។

## ស្ថានភាពនៃរបាយការណ៍

របាយការណ៍នេះបង្ហាញពីដំណើរការ របកគំហើញ និងអនុសាសន៍ផ្អែកលើការវិភាគស្ថានភាពជនមានអូទីស្សឹមនៅកម្ពុជា។ ទិន្នន័យដែលបានប្រមូលសម្រាប់ការវិភាគនេះបានប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងគោលបំណងទាំងបីដែលបានកំណត់ក្នុងគម្រោងដូចបង្ហាញខាងក្រោម។ ក្នុងរបាយការណ៍នេះបានលម្អិតអំពីវិធីសាស្ត្រនៃការប្រមូលទិន្នន័យដែលក្រុមការងារបានប្រើប្រាស់កន្លងមក។ ការរៀបចំក្រុមការងារនេះសម្រាប់ចុះធ្វើការងារនៅតាមមូលដ្ឋានដើម្បីធានាបាននូវភារកិច្ចនិងការអនុវត្តប្រកបដោយក្រមសីលធម៌ និងការដាក់កូដទិន្នន័យ និងរបកគំហើញបឋមពីគម្រោង។ របាយការណ៍នេះត្រួសត្រាយផ្លូវដើម្បីគាំទ្រដល់ការផ្តល់នូវអនុសាសន៍សម្រាប់ចាត់វិធានការបន្ថែមក្នុងការគាំទ្រដល់ការអភិវឌ្ឍនៃការផ្តល់ដល់ជនមានអូទីស្សឹម និងគ្រួសាររបស់ពួកគេ។

## សង្ខេបគម្រោង

ក្រុមការងារគម្រោងត្រូវបានជ្រើសរើសដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ និងកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តភាព និងសមធម៌ (ACCESS) ដើម្បីផ្តល់ការវិភាគស្ថានភាពក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងបំពេញចំណុចខ្វះខាតនៃចំណេះដឹងពាក់ព័ន្ធនឹងជនមាន អូទីស្សឹម និងគ្រួសាររបស់ពួកគេនៅកម្ពុជា។ គោលបំណងទាំងបីរបស់គម្រោងត្រូវបានកំណត់ដូចខាងក្រោម៖

១. ធ្វើការវាយតម្លៃ និងវិភាគសេវាគាំទ្រដែលមានសម្រាប់ជនមានអូទីស្សឹម
២. វិភាគស្ថានភាពជនអូទីស្សឹមក្នុងការទទួលបានសេវាគាំទ្រ ដែលអាចរាប់បញ្ចូលទាំងកត្តាសម្របសម្រួល ឧបសគ្គ និងបញ្ហាប្រឈម និង
៣. ផ្តល់អនុសាសន៍អំពីជម្រើសនានាក្នុងការពង្រឹងសេវាគាំទ្រ រួមមានជាអាទិ៍ ការអប់រំ ការស្តារលទ្ធភាពពលកម្ម និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។

## និយមន័យ និងអត្រាប្រេវ៉ាឡង់នៃជំងឺអូទីស្សឹម

ចំណាត់ថ្នាក់ស្ថិតិអន្តរជាតិនៃជំងឺនិងបញ្ហាសុខភាពផ្សេងទៀត (ICD-10) គឺជាសៀវភៅណែនាំរោគវិនិច្ឆ័យដែលប្រើជាទូទៅមួយដែលត្រូវបានណែនាំដោយអង្គការសុខភាពពិភពលោក។ និយមន័យអូទីស្សឹម ដូចមានចែងក្នុង ICD 10៖

អូទីស្សឹម (ហៅថា 'Pervasive Developmental Disorders' នៅក្នុង ICD 10) ត្រូវបានកំណត់ថាជា "ក្រុមនៃជំងឺដែលត្រូវបានកំណត់លក្ខណៈដោយភាពមិនប្រក្រតីនៃគុណភាពក្នុងការធ្វើអន្តរកម្មសង្គមទៅវិញទៅមក និងនៅក្នុងទម្រង់នៃការប្រាស្រ័យទាក់ទងគ្នា និងដោយការដាក់កម្រិត គំរូមិនប្រក្រតីការបង្ហាញនូវចំណាប់អារម្មណ៍ និងសកម្មភាពដដែលៗ។ ភាពមិនប្រក្រតីប្រកបដោយគុណភាពទាំងនេះគឺជាលក្ខណៈពិសេសដែលរីករាលដាលនៃដំណើរការរបស់បុគ្គលនៅក្នុងគ្រប់ស្ថានភាពទាំងអស់"។

មានឧបករណ៍វាយតម្លៃ និងរោគវិនិច្ឆ័យក្រៅពី ICD-10 ក្នុងការប្រើប្រាស់ទូទៅជាអន្តរជាតិ។ ឧបករណ៍ទាំងនេះរួមមានសៀវភៅណែនាំរោគវិនិច្ឆ័យ និងស្ថិតិនៃជំងឺផ្លូវចិត្ត បោះពុម្ពលើកទីប្រាំ (DSM-5)។ និយមន័យពីសៀវភៅណែនាំនេះត្រូវបានភ្ជាប់ជាមួយរបាយការណ៍នេះនៅឧបសម្ព័ន្ធទី៥ ។

តួលេខត្រឹមត្រូវដែលទាក់ទងនឹងអត្រាប្រេវ៉ាឡង់នៃអូទីស្សឹមគឺមិនងាយស្រួលទទួលបាននោះទេ ហើយមានភាពខុសប្លែកគ្នាច្រើននៅទូទាំងការសិក្សាដែលបានបោះពុម្ពផ្សាយ។ អង្គការសុខភាពពិភពលោកបានប៉ាន់ប្រមាណថានៅទូទាំងពិភពលោកប្រហែល កុមារ ១ នាក់ ក្នុងចំណោមកុមារ ១៦០ នាក់មានអូទីស្សឹម។ អត្រាប្រេវ៉ាឡង់នៃអូទីស្សឹម នៅក្នុងប្រទេសដែលមានចំណូលទាបនិងមធ្យមជាច្រើន រួមទាំងប្រទេសកម្ពុជាមិនទាន់ដឹងនៅឡើយ។

ក្នុងឆ្នាំ ២០១៤ វិទ្យាស្ថានជាតិស្ថិតិនៃប្រទេសកម្ពុជាបានធ្វើការអង្កេតប្រជាសាស្ត្រ និងសុខភាព ដោយប្រើប្រាស់កម្រងសំណួរអំពីពិការភាពរបស់ក្រុមការងារវ៉ាស៊ីនតោន (The Washington Group)។ ទិន្នន័យត្រូវបានទទួលពីគំរូសំណាកចំនួន ១៦,៣៥៦ គ្រួសារ ដែលមានស្ត្រី ១៨,០១២នាក់ និងបុរស ៥,៤៨៤នាក់ ដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ឆ្នាំ។

អត្រាឆ្លើយតបនៃការអង្កេតនេះ ៩៩% ត្រូវបានទទួល (១៥,៨២៥ គ្រួសារ; ៧៤,១១២នាក់)។ អត្រាប្រេវ៉ាឡង់នៃពិការភាពសរុប ដែលទទួលបានពីការអង្កេតនេះគឺមានចំនួន ៩.៥% នៃប្រជាជនដែលមានអាយុប្រាំឆ្នាំឡើងទៅ។

ខណៈពេលដែលទិន្នន័យទទួលបានពីការអង្កេតនេះមានសារៈសំខាន់ និងអាចជួយដល់ការរៀបចំគោលនយោបាយពិការភាពក្នុងប្រទេសកម្ពុជា ប៉ុន្តែវានៅមានកម្រិតនៅឡើយនៅពេលក្រុមការងារព្យាយាមស្វែងយល់ពីស្ថានភាពសម្រាប់អ្នកមានអូទីស្សឹមនិងគ្រួសាររបស់ពួកគេ។ ការអង្កេតនេះផ្តោតទៅលើបុគ្គលដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅ ហើយបានសួរសំណួរថាតើបុគ្គលនោះមានការលំបាកក្នុងការមើលឃើញ ការស្តាប់ ការដើរ ឬឡើងជណ្តើរ ការចងចាំ ឬការផ្តោតអារម្មណ៍ ការថែទាំខ្លួនឯង ឬការទំនាក់ទំនង។ អ្នកដែលមានអូទីស្សឹម អាចជួបប្រទះនឹងបញ្ហាប្រឈមទាំងនេះខ្លះ ឬទាំងអស់ ប៉ុន្តែការអង្កេតចំនួនប្រជាជនជាក់លាក់ និងផ្តោតសំខាន់ជាងនេះ គឺចាំបាច់ ប្រសិនបើការយល់ដឹងកាន់តែច្រើនអំពីអត្រាប្រេវ៉ាឡង់ និងតម្រូវការរបស់ជនមានអូទីស្សឹមត្រូវបានធ្វើឡើង។

## ការអភិវឌ្ឍក្រុមការងារ

ក្រុមការងារដែលបានប្រមូលផ្តុំដើម្បីអនុវត្តការងារនេះត្រូវបានជ្រើសរើសដោយផ្អែកលើមុខជំនាញក្នុងការអនុវត្តការងារវិភាគស្ថានភាពប្រភេទនេះ ចំណេះដឹងអំពីស្ថានភាពប្រទេសជាតិសម្រាប់កុមារ និងកូនក្មេងមានពិការភាព និងគ្រួសាររបស់ពួកគេនៅកម្ពុជា និងសមត្ថភាពរកទិន្នន័យតាមរយៈការចូលរួមពីសំណាក់ ទាំងអ្នកផ្តល់និងអ្នកប្រើប្រាស់ សេវានៅទូទាំងប្រទេស។

ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នារវាងក្រុមការងារ គេបានរៀបចំកិច្ចប្រជុំប្រចាំសប្តាហ៍ដោយមានសមាជិកទាំងអស់អញ្ជើញចូលរួម។ លើសពីនេះទៅទៀត ប្រធានក្រុមការងារគម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកមូលដ្ឋានដើម្បីធានាថា សមាជិកគ្រប់រូបមានចំណេះដឹងអំពីអភិក្រមផ្អែកលើវិធីសាស្រ្ត តម្រូវការក្រមសីលធម៌ និងមានការផ្តោតយ៉ាងសំខាន់ទៅលើគោលបំណងរបស់គម្រោង។

កិច្ចការរបស់ក្រុមការងារគម្រោងត្រូវបានបែងចែកទៅតាមមុខជំនាញ និងចំណេះដឹងអំពីស្ថានភាពមូលដ្ឋាន និងប្រទេសជាតិ។ ការងារនេះបានជួយដល់កិច្ចការជាមូលដ្ឋានដែលត្រូវធ្វើឡើងជាមួយនឹងគំរូតាងចំណាត់ថ្នាក់ តាមគោលបំណង (purposive stratified sample) និងទិន្នន័យដែលត្រូវប្រមូលដោយប្រើប្រាស់ទាំងភាសាអង់គ្លេស និងភាសាខ្មែរ ក្នុងករណីដែលចាំបាច់។ ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុត្រូវបានសម្របសម្រួលតាមរយៈមជ្ឈមណ្ឌលថែទាំសុខភាពផ្លូវចិត្តកុមារ និងក្មេងជំទង់ (CCAMH) នៅខេត្តកណ្តាល។

## វិធីសាស្រ្តដែលបានប្រើប្រាស់

### ការពិនិត្យឯកសារឡើងវិញ

តាមរយៈគម្រោងនេះ សំណុំឯកសារ (មាននៅក្នុងឧបសម្ព័ន្ធទី២) ទាំងឯកសារផ្លូវការ និងឯកសារដែលផ្តល់ដោយអង្គការ និងអ្នកឆ្លើយសំណួរ ត្រូវបានប្រមូល ពិនិត្យ និងវិភាគ ដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធនឹង៖

១. គំនិតផ្តួចផ្តើមគោលនយោបាយជាតិទាក់ទងនឹងពិការភាព (ដោយយោងជាពិសេសទៅលើអូទីស្សឹម)
២. ការឆ្លើយតបរបស់កម្ពុជាទៅនឹងកិច្ចព្រមព្រៀង និងគំនិតផ្តួចផ្តើមអន្តរជាតិផ្សេងៗ
៣. ការសិក្សាស្រាវជ្រាវដែលផ្តោតលើការងារពិការភាពនៅកម្ពុជា ដោយយោងជាពិសេសទៅលើអូទីស្សឹម។

ការត្រួតពិនិត្យជាបឋមលើឯកសារទាំងនេះ បានផ្តល់លទ្ធភាពឱ្យក្រុមការងារស្រាវជ្រាវ ទទួលបានការយល់ដឹងច្បាស់អំពីបញ្ហាបរិបទពាក់ព័ន្ធនឹងការផ្តល់សេវាសម្រាប់ជនមានអូទីស្សឹមនៅកម្ពុជា។ បច្ចុប្បន្ន ឯកសារទាំងនេះត្រូវបានពិនិត្យឡើងវិញ ហើយកូដពាក់ព័ន្ធទៅតាមប្រធានបទត្រូវបានបង្កើតឡើងសម្រាប់វិភាគទិន្នន័យ ដូចបានរៀបរាប់ខាងក្រោម ។ ចំណុចទាំងឡាយណា ដែលមានភាពសមស្របទៅនឹងផ្នែកដែលពាក់ព័ន្ធនឹងឯកសារទាំងនេះត្រូវបានធ្វើឡើងនៅក្នុងផ្នែកដែលរកឃើញនៃរបាយការណ៍នេះ។

**ការស្រាវជ្រាវដល់ទីកន្លែង**

វិធីសាស្ត្របែបគុណភាពត្រូវបានបង្កើតឡើង ក្នុងគោលបំណងទទួលបានបទពិសោធន៍ ពីបុគ្គលដែលពាក់ព័ន្ធផ្ទាល់ និងអង្គការដែលធ្វើការជាមួយកូនក្មេងដែលមានអូទីស្សឹម ឬផ្តល់ការគាំទ្រផ្នែកវិជ្ជាជីវៈដល់ជនមានអូទីស្សឹមនៅក្នុងប្រទេសកម្ពុជា។

ឧបករណ៍៖ បទសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ (semi-structured interviews) និងក្រុមគោលដៅត្រូវបានដាក់ពង្រាយដើម្បីប្រមូលទិន្នន័យពីមូលដ្ឋាន។ ជម្រើសនៃអភិក្រមពាក់កណ្តាលរចនាសម្ព័ន្ធ (semi-structured approach) បានអនុញ្ញាតឱ្យមានភាពបត់បែនក្នុងការសួរនាំអ្នកឆ្លើយសំណួររកព័ត៌មានកាន់តែស៊ីជម្រៅ ក្នុងករណីដែលចាំបាច់។ ឧបករណ៍នេះត្រូវបានបង្កើតឡើងដោយក្រុមការងារគម្រោង និងត្រូវបានសាកល្បងនៅកម្ពុជាដើម្បីបង្ហាញឱ្យឃើញប្រសិទ្ធភាពរបស់វា។ ដោយផ្អែកលើដំណើរការសាកល្បងនេះ គេបានធ្វើការកែសម្រួល មុនពេលប្រើប្រាស់ឧបករណ៍ជាមួយនឹងគំរូតាងនៃការសិក្សាជាសារវន្ត។ ឧបករណ៍សម្ភាសន៍ និងក្រុមគោលដៅត្រូវបានរៀបចំរួចរាល់សម្រាប់ក្រុមការងារគម្រោងទាំងជាភាសាខ្មែរ និងអង់គ្លេស ជាមួយនឹងអ្នកឆ្លើយសំណួរទៅតាមជម្រើសភាសាណាមួយដែលពួកគេត្រូវប្រើ។

ទម្រង់បែបបទដែលផ្តល់ការព្រមព្រៀងដោយមានការជូនដំណឹងពីអ្នកឆ្លើយសំណួរទាំងអស់ត្រូវបានបង្កើតឡើង និងថែរក្សាដោយបុគ្គលិកមូលដ្ឋាន ក្នុងអំឡុងពេល និងបន្ទាប់ពីការប្រមូលទិន្នន័យ។ (ព័ត៌មានលម្អិតអំពីនីតិវិធីស្តីពីសីលធម៌មានភ្ជាប់មកជាមួយនូវក្នុងឧបសម្ព័ន្ធទី៣)។

**គំរូតាង៖** គំរូតាងចំណាត់ថ្នាក់តាមគោលបំណងត្រូវបានទទួលដោយគិតទៅលើចំនួនប្រជាជនផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។ ការធ្វើបែបនេះបានអនុញ្ញាតឱ្យយើងទទួលបានទិន្នន័យពីកន្លែងផ្សេងៗ និងតាមរយៈការទំនាក់ទំនងដោយផ្ទាល់ទាំងនៅទីប្រជុំជន និងជនបទ នៅក្នុងខេត្តកណ្តាល ខេត្តបាត់ដំបង និងខេត្តកំពង់ចាម ដែលពួកគេទាំងនោះជាក្រុមអ្នកផ្តល់សេវាផងនិងជាអ្នកប្រើប្រាស់សេវាផង។ ទោះបីជាមានការលំបាកក្នុងការធ្វើដំណើរក៏ដោយ ដោយមូលហេតុនៃជំងឺរាតត្បាតសកលកូវីដ-១៩ ក៏ទិន្នន័យបន្ថែមត្រូវបានប្រមូលពីក្រុមស្រដៀងគ្នានៅក្នុងខេត្តកំពត ភ្នំពេញ ព្រៃវែង ពោធិ៍សាត់ ព្រះសីហនុ ស្វាយរៀង និងខេត្តតាកែវ ដែលទិន្នន័យទាំងនេះ ត្រូវបានប្រមូលតាមរយៈបទសម្ភាសន៍តាមប្រព័ន្ធអេឡិចត្រូនិក។

បន្ថែមពីលើការធានាបាននៃការប្រមូលទិន្នន័យពីបរិយាកាសផ្សេងៗគ្នា ក្រុមការងារក៏បានពិចារណាអំពីក្រុមដែលមានឥទ្ធិពលទាក់ទងនឹងសាសនា អង្គការមិនមែនរដ្ឋាភិបាល (NGO) និងរដ្ឋាភិបាល និងអាជ្ញាធរដែនដី ជាក្រុមចូលរួមឆ្លើយតបទៅនឹងការសិក្សានេះផងដែរ។ តារាងនៃស្ថាប័នដែលបានចូលរួមក្នុងការសិក្សានេះ មានភ្ជាប់មកជាមួយ នៅផ្នែកខាងក្រោមនៃរបាយការណ៍នេះ (ការងារចុះតាមមូលដ្ឋាន)។ ការជ្រើសរើសគំរូតាងតាមវិធីសាស្ត្រដុំព្រិល (snowball) ក៏ត្រូវបានយកមកអនុវត្ត ដែលអ្នកឆ្លើយសំណួរទាំងនោះត្រូវបានកំណត់អត្តសញ្ញាណដោយស្ថាប័នដែលយើងបានសម្ភាសន៍ ក៏ដូចជាអ្នកផ្តល់សេវាគាំទ្រដល់ជនមានអូទីស្សឹមនៅប្រទេសកម្ពុជា។

ការបណ្តុះបណ្តាល៖ មុននឹងក្រុមការងារចុះធ្វើការនៅតាមមូលដ្ឋាន ប្រធានក្រុមការងារស្រាវជ្រាវក៏បានផ្តល់ការបណ្តុះបណ្តាលដល់ពួកគេផងដែរ។ ការបណ្តុះបណ្តាលដំបូងគឺផ្តោតលើការពិចារណាអំពីក្រមសីលធម៌ និងផ្តោតលើប្រសិទ្ធភាពនៃការគ្រប់គ្រងការសម្ភាសន៍ រួមទាំងការសម្ភាសន៍ជាក្រុម។ ដំណើរការ ទិដ្ឋភាពផ្សេងៗទាក់ទងនឹងក្រមសីលធម៌ និងបច្ចេកទេសនៃបទសម្ភាសន៍ជាបុគ្គល (KII) និងការពិភាក្សាជាក្រុម (FGDs) និងភាពខុសគ្នារវាងនីតិវិធីទាំងនេះត្រូវបានពិភាក្សាយ៉ាងលម្អិត។ បន្ទាប់ពីការចាប់ផ្តើមប្រមូលទិន្នន័យ ការបណ្តុះបណ្តាលបន្ថែមត្រូវបានផ្តល់ជូនទាក់ទងនឹង ការអភិវឌ្ឍ និងការអនុវត្តកូដតាមប្រធានបទ។ សមាជិកក្រុមទាំងអស់ បានចុះហត្ថលេខាលើទម្រង់នៃកិច្ចព្រមព្រៀងស្តីពីក្រមសីលធម៌ មុនពេលចាប់ផ្តើមប្រមូលទិន្នន័យ។

## ការងារចុះមូលដ្ឋានកន្លងមក

លក្ខណៈវិនិច្ឆ័យដូចខាងក្រោមត្រូវបានយកមកអនុវត្តសម្រាប់ការជ្រើសរើសអ្នកដែលនឹងចូលរួមក្នុងបទសម្ភាសន៍៖

១. ជាស្ថាប័ន ឬបុគ្គលដែលធ្លាប់ជួយដល់ជនមានពិការភាព រួមទាំងជនមានអូទីស្សឹម

២. ជាស្ថាប័នដែលមានការទទួលខុសត្រូវ ផ្នែកផ្លូវច្បាប់សម្រាប់ជនមានពិការភាព រួមទាំងជនមានអូទីស្សឹម

៣. ជាឪពុកម្តាយ/អ្នកថែទាំជនមានអូទីស្សឹម

ទិន្នន័យត្រូវបានទទួលពីអ្នកចូលរួមបទសម្ភាសន៍ រួមទាំងពីស្ថាប័ន ដូចមានបង្ហាញក្នុងតារាងទី១ "ក" និងតារាងទី១

"ខ" ខាងក្រោម (សូមកត់សម្គាល់ថា៖ ដោយសារហេតុផលក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ទោះបីជាឈ្មោះ ស្ថាប័នត្រូវបានដាក់បញ្ចូលក៏ដោយ ក៏ឈ្មោះរបស់បុគ្គលដែលបានចូលរួមមិនត្រូវបានបង្ហាញនោះទេ)។ ក្រុមការងារមិនបានសម្ភាសន៍ជាមួយជនមានអូទីស្សឹមនោះទេដោយសារតែបញ្ហាប្រឈមបណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩ និងដោយហេតុផលនៃចំនួនជនមានអូទីស្សឹម អ្នកដែលត្រូវសម្ភាសន៍ដែលបានធ្វើពាគវិនិច្ឆ័យត្រឹមត្រូវនៅមានកម្រិត។

## ផែនទីខាងក្រោមបង្ហាញពីរបាយនៃសំណាកគំរូនៃការសិក្សាស្រាវជ្រាវ

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ មកពីខេត្តផ្សេងៗ




FGD៖ ការពិភាក្សាជាក្រុមជាមួយឪពុក/ម្តាយរបស់កុមារមានអូទីស្សឹម
KII៖ ការពិភាក្សាជាបុគ្គលជាមួយអ្នកផ្តល់សេវា

## តារាងទី១ក. ស្ថាប័នដែលចូលរួមការសម្ភាសន៍

| ល.រ | អ្នកផ្តល់សេវា / ស្ថាប័ន | តួនាទីរបស់អ្នកចូលរួមការសម្ភាសន៍ | ភាសាដែលប្រើក្នុងការសម្ភាសន៍ | ព័ត៌មានសង្ខេបអំពីអ្នកផ្តល់សេវា/ស្ថាប័ន |
|---|---|---|---|---|
| ១ | នាយកដ្ឋានអប់រំពិសេស ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ | ប្រធានការិយាល័យកុមារមានពិការភាពសតិបញ្ញា | ខ្មែរ | នាយកដ្ឋានអប់រំពិសេស ក្រសួងអប់រំយុវជន និងកីឡា (MoEYS) រាជធានីភ្នំពេញ<br>មន្ទីររបស់រដ្ឋាភិបាលដែលផ្តល់ការគាំទ្រសម្រាប់សកម្មភាពនានា ដើម្បីលើកទឹកចិត្តដល់ការបង្រៀន និងការរៀនប្រកបដោយប្រសិទ្ធភាព ការអភិវឌ្ឍសង្គម និងផ្លូវចិត្ត និងស្តង់ដារកម្មវិធីសិក្សាសម្រាប់គ្រូបង្រៀន និងកុមារ ដែលធ្វើការជាមួយសិស្សដែលមានតម្រូវការអប់រំពិសេស និង/ឬពិការភាព។ |
| ២ | វិទ្យាស្ថានជាតិអប់រំពិសេស រាជធានីភ្នំពេញ | នាយក | ខ្មែរ | វិទ្យាស្ថានជាតិអប់រំពិសេស ក្រសួងអប់រំយុវជន និងកីឡា (MoEYS) រាជធានីភ្នំពេញ។ |
| ៣ | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ | អគ្គលេខាធិការរង | ខ្មែរ | ស្ថាប័នដែលមានការទទួលខុសត្រូវក្នុងការសម្របសម្រួលនិងពិគ្រោះយោបល់លើបញ្ហាពិការភាព រួមទាំងតាមដាន វាយតម្លៃ និងជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ផ្សេងៗទាក់ទងនឹងពិការភាព។<br>ស្ថាប័នដែលមានការទទួលខុសត្រូវក្នុងការលើកកម្ពស់សុខុមាលភាពរបស់កុមារ គ្រួសារ និងជនមានពិការភាព។ |
| ៤ | អង្គការម្លប់តាប៉ាង ជាអង្គការមិនមែនរដ្ឋាភិបាលនៅខេត្តព្រះសីហនុ | ប្រធានក្រុមការងារផ្នែកតម្រូវការពិសេស | ខ្មែរ | អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនេះគឺជាមជ្ឈមណ្ឌលដ៏ទូលំទូលាយមួយ ដែលធ្វើកិច្ចការផ្តោតលើកុមារ និងយុវជនដែលជួបការលំបាកនៅក្រុងព្រះសីហនុ ប្រទេសកម្ពុជា។ មជ្ឈមណ្ឌលមានផ្តល់ទីជម្រក ការថែទាំសុខភាព ការអប់រំ កីឡា សិល្បៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការប្រឹក្សាយោបល់ ការគាំទ្រ និងការការពារគ្រួសារមិនឱ្យមានការរំលោភបំពានគ្រប់ទម្រង់។ តាមរយៈកម្មវិធីជាច្រើនដែលផ្តោតលើបញ្ហាប្រឈមនានានៅទូទាំងសហគមន៍ក្នុងក្រុងព្រះសីហនុ អង្គការនេះជួយដល់កុមារ យុវជន និងគ្រួសាររបស់ពួកគេដែលងាយរងហានិភ័យ។ |

| ល.រ | អ្នកផ្ដល់សេវា / ស្ថាប័ន | តួនាទីរបស់អ្នកចូលរួមការសម្ភាសន៍ | ភាសាដែលប្រើក្នុងការសម្ភាសន៍ | ព័ត៌មានសង្ខេបអំពីអ្នកផ្ដល់សេវា/ស្ថាប័ន |
|---|---|---|---|---|
| ៥ | អង្គការករុណាបាត់ដំបង ខេត្តបាត់ដំបង | ប្រធានគ្រប់គ្រងកម្មវិធី | ខ្មែរ | អង្គការមិនមែនរដ្ឋាភិបាល ផ្ដល់សេវាផ្សព្វផ្សាយព្យាបាលដល់មូលដ្ឋាន ប្រចាំខែ។ នៅឆ្នាំ២០១៦ និងដោយមានការកើនឡើងឥតឈប់ឈរនៃតម្រូវការសង្គម និងមនុស្សធម៌ អង្គការក្នុងស្រុកនេះត្រូវបានបង្កើតឡើងដើម្បីបំពេញនូវតម្រូវការទាំងនេះ។ អង្គការនេះបានដំណើរការការងារដែលគ្របដណ្ដប់នៅទូទាំងខេត្តបាត់ដំបង។<br>បេសកកម្មរបស់អង្គការគឺ៖ ការផ្ដល់ការថែទាំតាមមណ្ឌល និងការថែទាំតាមផ្ទះនៅតាមគ្រួសារ និងសហគមន៍។ ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ការគាំទ្រផ្នែកសេដ្ឋកិច្ច និងការព្យាបាលកម្រិតមូលដ្ឋានដល់ជនមានពិការភាព យុវជន ស្ត្រី និងកុមារ។ |
| ៦ | មជ្ឈមណ្ឌលភូមិសន្តិភាព (PVC) ខេត្តតាកែវ | នាយកមជ្ឈមណ្ឌល | ខ្មែរ | អង្គការដែលធ្វើការសហការជាមួយអង្គការផ្សេងទៀតដើម្បីផ្ដល់សេវាបញ្ជូនបន្ត។ សេវានានា រួមមាន ការព្យាបាល និងការអប់រំ ដែលផ្ដល់ជូនដល់អតិថិជនជាច្រើនដែលមានតម្រូវការដែលមានភាពស្មុគស្មាញ។ អង្គការនេះទទួលបានការគាំទ្រពី Phnom Penh Church Diocese ដែលបានបើកដំណើរការមជ្ឈមណ្ឌលថែទាំ (day care center) និងគាំទ្រការថែទាំតាមផ្ទះ។ |
| ៧ | អេពិកអាត ខេត្តកំពត | នាយកប្រចាំប្រទេស និងប្រធានក្រុមការងារអប់រំពិសេស | ខ្មែរ | អង្គការដែលលើកកម្ពស់បរិយាបន្នជនដែលមានសមត្ថភាព និងពិការភាពគ្រប់ប្រភេទតាមរយៈសិល្បៈ។ ពួកគេប្រើប្រាស់សិល្បៈជាទម្រង់នៃការបញ្ចេញមតិ និងពង្រឹងអំណាច ដើម្បីនាំមកនូវភាពរួមគ្នារវាងជនមាននិងគ្មានពិការភាព។ |
| ៨ | កម្មវិធីសេវាអភិវឌ្ឍន៍ពិការភាព (DDSP) ខេត្តពោធិ៍សាត់ | នាយកប្រតិបត្តិ | ខ្មែរ | អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការដើម្បីលើកកម្ពស់សុខុមាលភាពរបស់ជនមានពិការភាព តាមរយៈការពង្រឹងសិទ្ធិអំណាច និងការពង្រឹងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធក្នុងការទទួលបានសេវាដ៏ទូលាយ រួមទាំង សេវាផ្នែកទឹកស្អាតនិងអនាម័យ (WASH) ការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ស្ដីពីសិទ្ធិជនមានពិការភាព និងធ្វើការឆ្ពោះទៅរកបរិយាបន្នសង្គម និងកែលម្អគុណភាព ការរៀនសូត្ររបស់កុមារមានពិការភាព ក្រោមកិច្ចសហការជាមួយនាយកដ្ឋានអប់រំ យុវជន និងកីឡា និងមន្ទីរពាក់ព័ន្ធដទៃទៀតរបស់រដ្ឋាភិបាល។ |

| ល.រ | អ្នកផ្តល់សេវា / ស្ថាប័ន | តួនាទីរបស់អ្នកចូលរួមការសម្ភាសន៍ | ភាសាដែលប្រើក្នុងការសម្ភាសន៍ | ព័ត៌មានសង្ខេបអំពីអ្នកផ្តល់សេវា/ស្ថាប័ន |
|---|---|---|---|---|
| ៩ | គណៈកម្មាធិការជាតិស្ប៉ែស្យាល់អូឡាំពិកកម្ពុជា រាជធានីភ្នំពេញ | មន្ត្រីជាន់ខ្ពស់នៃគណៈកម្មាធិការប្រតិបត្តិ | ខ្មែរ | គណៈកម្មាធិការជាតិស្ប៉ែស្យាល់អូឡាំពិក កម្ពុជា រៀបចំសកម្មភាពកីឡាសម្រាប់កុមារពិការភាពខាងសតិបញ្ញា និងអូទីស្សឹម។ ស្ប៉ែស្យាល់អូឡាំពិកផ្តល់នូវការហ្វឹកហ្វឺនកីឡាប្រចាំឆ្នាំ និងការប្រកួតកីឡាអត្តពលកម្ម ក្នុងប្រភេទកីឡាអូឡាំពិកជាច្រើនប្រភេទសម្រាប់កុមារនិងមនុស្សពេញវ័យដែលមានពិការភាពខាងសតិបញ្ញា។ សកម្មភាពទាំងនោះផ្តល់ឱ្យពួកគេនូវឱកាសបន្តដើម្បីអភិវឌ្ឍកាយសម្បទា បង្ហាញពីភាពក្លាហាន បទពិសោធន៍រីករាយ និងចូលរួមក្នុងការចែករំលែកសមត្ថភាព ជំនាញ និងមិត្តភាព។ |
| ១០ | សាលាអប់រំពិសេសនៃការលូតលាស់ រាជធានីភ្នំពេញ | ម្តាយរបស់កូនប្រុសអូទីស្សឹម និងនាយកសាលារៀន | ខ្មែរ | សាលាអប់រំពិសេសបានបើកដំបូងក្នុងឆ្នាំ២០១៧ ក្រោមការឧបត្ថម្ភពី Child Jesus Parish នៅបែកខាងត្បូងនៃរាជធានីភ្នំពេញ និងដោះស្រាយតម្រូវការរបស់កុមារអូទីស្សឹម។ មានកុមារប្រហែល១០០នាក់ទទួលសេវានៅទីនោះ។ បុគ្គលិកធ្វើការលើការអភិវឌ្ឍលើផ្នែករាងកាយ សតិបញ្ញា សង្គម និងផ្លូវចិត្ត ហើយសម្រាប់ការងារមួយចំនួនពួកគេប្រើវិធីសាស្ត្រសិក្សាអាកប្បកិរិយា ( Applied Behaviour Approach-ABA ) ។ |
| ១១ | អង្គការសាលារៀនទន្សាយ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តសៀមរាប | អ្នកគ្រប់គ្រងកម្មវិធី | ខ្មែរ | អង្គការសាលាពិសេសមួយនេះបានធ្វើការជាមួយកុមារមានពិការភាពផ្នែកសតិបញ្ញាក្នុងប្រទេសកម្ពុជាជាង ២០ឆ្នាំមកហើយ។ ពួកគេលើកកម្ពស់សិទ្ធិរបស់កុមារមានពិការភាពផ្នែកសតិបញ្ញា ដើម្បីជួយឱ្យពួកគេទទួលបានការអប់រំ។ អង្គការនេះបានចាប់ផ្តើមថ្នាក់សមាហរណកម្មគ្នាដំបូងគេនៅក្នុងសាលាបឋមសិក្សា និងផ្នែកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងរាជធានីភ្នំពេញ។ ចាប់តាំងពីឆ្នាំ២០១៤ អង្គការបាននិងកំពុងពង្រីកសេវាទៅខេត្តផ្សេងទៀត ហើយបច្ចុប្បន្នមានគម្រោងអប់រំនៅខេត្តកណ្តាល កំពង់ស្ពឺ និងខេត្តសៀមរាប។ |
| ១២ | សាលាអង្គការដើម្បីភាពញញឹមនៃកុមារ រាជធានីភ្នំពេញ | អ្នកគ្រប់គ្រងកម្មវិធីពិការភាព | ខ្មែរ | សាលានេះមានបេសកកម្មជួយកុមារឱ្យរួចផុតពីភាពអត់ឃ្លាន និងនាំពួកគេទៅរកការងារសមរម្យ មានជំនាញ និងទទួលបានប្រាក់ខែល្អ។ ដើម្បីសម្រេចបានការងារទាំងនេះ កម្មវិធីសំខាន់ៗចំនួនប្រាំមួយ ដែលសម្របតាមតម្រូវការរបស់កុមារ ត្រូវបានបង្កើតឡើង៖ អាហារ សុខភាព ការការពារ ការអប់រំ និងសាលារៀន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនួយសម្រាប់គ្រួសារ។ |

| ល.រ | អ្នកផ្តល់សេវា / ស្ថាប័ន | តួនាទីរបស់អ្នកចូលរួមការសម្ភាសន៍ | ភាសាដែលប្រើក្នុងការសម្ភាសន៍ | ព័ត៌មានសង្ខេបអំពីអ្នកផ្តល់សេវា/ស្ថាប័ន |
|---|---|---|---|---|
| ១៣ | មជ្ឈមណ្ឌលជំនួយនៃក្តីសង្ឃឹមសម្រាប់សហគមន៍ (HHC) ជាសាលារបស់រដ្ឋ ខេត្តកណ្តាល | នាយកប្រតិបត្តិ | ខ្មែរ | សាលានេះគឺធ្វើការលើកកម្ពស់ និងការពារសិទ្ធិរបស់កុមារ និងយុវជនពិការសតិបញ្ញា និងអូទីស្សឹម ផ្តល់អំណាចដល់គ្រួសារ និងសហគមន៍ និងចូលរួមជាមួយរដ្ឋាភិបាលឱ្យមានការឆ្លើយតបកាន់តែច្រើន។ សាលាធ្វើការដើម្បីដោះស្រាយ អន្តរាគមន៍ពិការភាពទាន់ពេលវេលា រួមមាន ការរកឃើញទាន់ពេល ការអប់រំពិសេស និងការកំណត់អត្តសញ្ញាណ ដោយមានការគាំទ្រ និងការបណ្តុះបណ្តាលដល់ឪពុកម្តាយ និងក្រុមគ្រួសារ ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍកុមារជាអតិបរមា ស្តារលទ្ធភាពពលកម្មកាយសម្បទា និងការចុះឈ្មោះកុមារមានពិការភាពក្នុងប្រព័ន្ធអប់រំប្រកបដោយគុណភាព និងសមធម៌។ |
| ១៤ | មូលនិធិកុមារពិការ (KPF) ជាសាលារបស់រដ្ឋ រាជធានីភ្នំពេញ និងខេត្តក្រចេះ | គ្រូបង្រៀនបឋមសិក្សា | ខ្មែរ | បុគ្គលិកនៅសាលាទាំងនេះបានមានឆន្ទៈចង់ឃើញកុមារ និងយុវជនមានពិការភាពចាប់ពីកម្រិតមធ្យមទៅធ្ងន់ធ្ងរ រស់នៅក្នុងជីវិតថ្លៃថ្នូរ ជាមួយគ្រួសាររបស់ខ្លួន នៅក្នុងសហគមន៍ប្រកបដោយបរិយាបន្ន។ ដោយប្រើវិធីសាស្ត្រផ្តោតលើការជួយសហគមន៍ ជួយខ្លួនឯង សាលារៀនកសាងសមត្ថភាពគ្រួសារ ក្នុងការតស៊ូមតិដើម្បីតម្រូវការរបស់កូនៗរបស់ពួកគេ និងធានាឱ្យបាននូវការគោរពសិទ្ធិរបស់ពួកគេ។ ពួកគេចូលរួមយ៉ាងសកម្មជាមួយសហគមន៍ ដើម្បីជួយសម្រួលដល់ការដាក់បញ្ចូលជនមានពិការភាពទាំងអស់ នៅគ្រប់វិស័យនៃជីវិត។ ធ្វើបែបនេះរួមបញ្ចូលទាំងការធ្វើការជាមួយក្រសួងរបស់រដ្ឋាភិបាល អង្គការជនពិការ ក្រុមមាតាបិតា និងអង្គការផ្សេងទៀត ដើម្បីតស៊ូមតិសម្រាប់តម្រូវការរបស់កុមារដែលងាយរងគ្រោះ។ |
| ១៥ | អង្គការធ្វើឱ្យប្រសើរឡើងដល់សេវាព្យាបាលការប្រាស្រ័យទាក់ទងនិងលេបអាហារនៅកម្ពុជា (OIC) រាជធានីភ្នំពេញ | នាយកប្រតិបត្តិ | ខ្មែរ | អង្គការធ្វើឱ្យប្រសើរឡើងដល់ការប្រាស្រ័យទាក់ទងដែលធ្វើការដើម្បីធ្វើឱ្យសេវាព្យាបាលដោយការនិយាយឱ្យបានទៅដល់អ្នកមានតម្រូវការ នៅក្នុងប្រទេសកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយ ដែលកំពុងធ្វើការដើម្បីពង្រីកសេវាព្យាបាលដោយការនិយាយនៅក្នុងប្រទេសកម្ពុជា និងជួយអ្នកដែលមានការលំបាកក្នុងការប្រាស្រ័យទាក់ទង និងការលេបអាហារ និងផ្តល់ការព្យាបាល និងការនិយាយប្រកបដោយវិជ្ជាជីវៈ ដល់កុមារដើម្បីឱ្យពួកគេអាចទៅរៀន និងចូលរួមយ៉ាងពេញលេញនៅក្នុងសង្គម។ |

| ល.រ | អ្នកផ្តល់សេវា / ស្ថាប័ន | តួនាទីរបស់អ្នកចូលរួមការសម្ភាសន៍ | ភាសាដែលប្រើក្នុងការសម្ភាសន៍ | ព័ត៌មានសង្ខេបអំពីអ្នកផ្តល់សេវា/ស្ថាប័ន |
|---|---|---|---|---|
| ១៦ | បុរីទារកនិងកុមារជាតិ (NBIC) រាជធានីភ្នំពេញ | នាយក | ខ្មែរ | អង្គការដែលផ្តល់ផ្ទះដល់កុមារនិងក្មេងពេញវ័យដែលគេបោះបង់ចោល ឬកំព្រាដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងជនមានពិការភាពផ្សេងទៀត។ |
| ១៧ | ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុ រាជធានីភ្នំពេញ | សាកលវិទ្យាធិការស្តីទី | ខ្មែរ | គ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលមិនស្វែងរកប្រាក់កម្រៃ ដែលផ្តល់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ និងក្រោយឧត្តមសិក្សាសម្រាប់និស្សិត រួមទាំងអ្នកដែលនឹងធ្វើការក្នុងវិស័យអប់រំ សុខាភិបាល និងការថែទាំ។ |
| ១៨ | គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា រាជធានីភ្នំពេញ | ជំនួយការ | ខ្មែរ | ក្រុមប្រឹក្សាត្រួតពិនិត្យសុខុមាលភាពសហគមន៍ឥស្លាមនៅកម្ពុជា។ ជាអង្គការដែលរក្សានូវទិដ្ឋភាពទូទៅ និងគាំទ្រសុខុមាលភាពរបស់សមាជិកទាំងអស់នៃសហគមន៍ឥស្លាមនៅកម្ពុជា រួមទាំងជនមានពិការភាពផងដែរ។ |
| ១៩ | អង្គការសមាគមសម្រាប់ជំនួយនឹងសង្គ្រោះនៃប្រទេសជប៉ុន (AAR ប្រទេសជប៉ុន) រាជធានីភ្នំពេញ ខេត្តកណ្តាល | ប្រធានអង្គការ | អង់គ្លេស | អង្គការអន្តរជាតិដែលលើកកម្ពស់ការអប់រំប្រែកបដោយបរិយាបន្ន ដោយសហការជាមួយសាលារៀន និងសហគមន៍ក្នុងខេត្ត កណ្តាល តាំងពីឆ្នាំ២០១៣ ដើម្បីធានាថាកុមារមានសិទ្ធិចូលរៀន និងអាចរៀនជាមួយគ្នាបាន ដោយមិនគិតពីពិការភាពរបស់ពួកគេ ខណៈពេលដែលទទួលបានការថែទាំ និងការយកចិត្តទុកដាក់សមស្រប ទៅតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។ កម្មវិធីអប់រំប្រែកបដោយបរិយាបន្ន រួមមាន ការបង្កើតបរិយាកាសសាលារៀនគ្មានឧបសគ្គ និងផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀន ដើម្បីជួយពួកគេឱ្យកាន់តែមានទំនាក់ទំនងល្អជាមួយកុមារ មានពិការភាព។ |
| ២០ | អង្គការកុមារក្នុងគ្រួសារ (CIF) រាជធានីភ្នំពេញ ខេត្តស្វាយរៀង | ទីប្រឹក្សាបច្ចេកទេស | អង់គ្លេស | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលចំណាយពេលវេលាក្នុងការផ្តល់ការថែទាំតាមគ្រួសារប្រកបដោយគុណភាពខ្ពស់ ដល់កុមារកំព្រា និងកុមារងាយរងគ្រោះនៅប្រទេសកម្ពុជា។ អង្គការនេះក៏ផ្តល់ការថែទាំជាក់លាក់ដល់កុមារមានពិការភាព និងមានជំងឺរ៉ាំរ៉ៃតាមរយៈគម្រោងគោលដៅ និងចូលរួមជាមួយសហគមន៍កាន់តែទូលំទូលាយតាមរយៈគម្រោងផ្សព្វផ្សាយដល់មូលដ្ឋាន និងគម្រោងភាពជាដៃគូរបស់ព្រះវិហារ។ |

| ល.រ | អ្នកផ្តល់សេវា / ស្ថាប័ន | តួនាទីរបស់អ្នកចូលរួមការសម្ភាសន៍ | ភាសាដែលប្រើក្នុងការសម្ភាសន៍ | ព័ត៌មានសង្ខេបអំពីអ្នកផ្តល់សេវា/ស្ថាប័ន |
|---|---|---|---|---|
| ២១ | មន្ទីរពេទ្យកុមារជាតិ (NPH) រាជធានីភ្នំពេញ | ពេទ្យឯកទេសជំងឺកុមារ/ អនុប្រធានផ្នែកផ្តល់សេវា | អង់គ្លេស | មន្ទីរពេទ្យដែលគ្រប់គ្រងដោយរដ្ឋាភិបាល ផ្តល់សេវាវេជ្ជសាស្ត្រនានា រួមមាន ការវាយតម្លៃ និងអន្តរាគមន៍ព្យាបាលសម្រាប់កុមារ និងគ្រួសារ រួមទាំងជនមានពិការភាពផងដែរ។ |
| ២២ | ស្ថាបនិកអង្គការករុណា ខេត្តបាត់ដំបង អង្គការមិនមែនរដ្ឋាភិបាល | ប្រធានអង្គការ | អង់គ្លេស | នៅឆ្នាំ២០១៦ ដោយសារការរីកចម្រើនឥតឈប់ឈរនៃគម្រោងសង្គម និងមនុស្សធម៌ ទើបប្រធានអង្គការមិនមែនរដ្ឋាភិបាលនេះ ដឹកនាំបង្កើតអង្គការក្នុងស្រុកនេះឡើង។ អង្គការនេះបង្កើតជាភូមិភាគការិតាល័យនៃភូមិភាគខេត្តបាត់ដំបង ដែលគ្របដណ្តប់ទូទាំងខេត្តរបស់ខ្លួន។ បេសកកម្មរបស់អង្គការគឺ៖ ផ្តល់ការថែទាំតាមមណ្ឌល និងការថែទាំតាមផ្ទះនៅតាមគ្រួសារ និងសហគមន៍ ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ការគាំទ្រផ្នែកសេដ្ឋកិច្ច និងការព្យាបាលតាមបែបវេជ្ជសាស្ត្រជាមូលដ្ឋាន ដល់ជនមានពិការភាព យុវជន ស្ត្រី និងកុមារ។ |
| ២៣ | ឪពុកម្តាយផ្ទាល់របស់កុមារដែលមានអូទីស្សឹម | ម្តាយរបស់កុមារដែលមានអូទីស្សឹម និងជាគ្រូបង្រៀន | អង់គ្លេស | ម្តាយរបស់កូនស្រីអាយុ ១៥ឆ្នាំ។ |
| ២៤ | អ្នកជំនាញវេជ្ជសាស្ត្រធ្វើការវាយតម្លៃ និងអន្តរាគមន៍ជាមួយជនមានពិការភាព ព្រមទាំងអូទីស្សឹម | អ្នកជំនាញវេជ្ជសាស្ត្រ | អង់គ្លេស | រដ្ឋាភិបាលបានជួលវេជ្ជបណ្ឌិតដែលបានចូលរួមក្នុងកម្មវិធីវាយតម្លៃ និងអន្តរាគមន៍ សម្រាប់កុមារមានពិការភាព រួមទាំងជនមានអូទីស្សឹមផងដែរ។ |
| ២៥ | អង្គការដំណក់ទឹក-Goutte D'eau | ប្រធានកម្មវិធីពិការភាព | អង់គ្លេស | អង្គការដែលធ្វើការជាមួយកុមារដែលបានសង្គ្រោះពីអំពើជួញដូរ រួមទាំងជនមានពិការភាពជាច្រើននាក់ផងដែរ។ |
| ២៦ | សមាគមមាតាបិតាសម្រាប់កុមារពិការសតិបញ្ញា | ប្រធានអង្គការ និងមាតា/បិតា | ខ្មែរ | អង្គការដែលធ្វើការគាំទ្រក្រុមគ្រួសារនិងមានសកម្មភាពជាច្រើនជួយដល់ជនមានពិការភាពសតិបញ្ញា រួមទាំងជនមានអូទីស្សឹមផងដែរ។ |

ក្រៅពីបទសម្ភាសន៍ដែលបានធ្វើឡើងជាមួយបុគ្គល ក្រុមគោលដៅជាបន្តបន្ទាប់ត្រូវបានបង្កើតឡើងជាមួយ ឪពុកម្តាយដូចបានបញ្ជាក់នៅក្នុងតារាង(១២)ខាងក្រោម។

### តារាងទី១ ខ. អ្នកឆ្លើយសំណួរជាឪពុកម្តាយដែលទិន្នន័យរបស់ខ្លួនត្រូវបានទទួលពីក្រុមគោលដៅ

| ល.រ | កាលបរិច្ឆេទធ្វើកិច្ច ពិភាក្សាជាក្រុម | ទីតាំងក្រុម គោលដៅ | ចំនួនឪពុកម្តាយ ដែលបានចូលរួម | ភាសាដែល ប្រើប្រាស់ |
|---|---|---|---|---|
| ១ | ២៥ មិថុនា ២០២១ | CCAMH | ឪពុកម្តាយ៦នាក់ ( ឪពុក២នាក់ ម្តាយ៤នាក់ ) | ខ្មែរ |
| ២ | ០៩ កក្កដា ២០២១ | CCAMH | ឪពុកម្តាយ៥នាក់ ( ឪពុក៣នាក់ ម្តាយ២នាក់ ) | ខ្មែរ |
| ៣ | ១២ កក្កដា ២០២១ | CCAMH | ឪពុកម្តាយ៥នាក់ ( ឪពុក១នាក់ ម្តាយ៤នាក់ ) | ខ្មែរ |
| ៤ | ១៤ កក្កដា ២០២១ | CCAMH | ឪពុកម្តាយ៦នាក់ ( ឪពុក៥នាក់ ម្តាយ១នាក់ ) | ខ្មែរ |
| ៥ | ១៦ កក្កដា ២០២១ | CCAMH | ឪពុកម្តាយ៧នាក់ ( ឪពុក៤នាក់ ម្តាយ៣នាក់ ) | ខ្មែរ |
| ៦ | ២២ កក្កដា ២០២១ | ខេត្តកំពង់ចាម | ឪពុកម្តាយ៥នាក់ ( ឪពុក០នាក់ ម្តាយ៥នាក់ ) | ខ្មែរ |
| ៧ | ១៩ សីហា ២០២១ | ខេត្តកំពង់ចាម | ឪពុកម្តាយ៧នាក់ ( ឪពុក៥នាក់ ម្តាយ២នាក់ ) | ខ្មែរ |
| ៨ | ០២ កញ្ញា ២០២១ | ខេត្តបាត់ដំបង | ឪពុកម្តាយ៤នាក់ ( ឪពុកម្នាក់ ម្តាយ៣នាក់ ) | ខ្មែរ |
| ៩ | ០៣ កញ្ញា ២០២១ | ខេត្តបាត់ដំបង | ឪពុកម្តាយ៤នាក់ ( ឪពុកម្នាក់ ម្តាយ៣នាក់ ) | ខ្មែរ |

### រូបភាពទី ១. សំនុំទិន្នន័យនៃកុមារមានអូទីស្សឹម៖



## តារាងទី ២. ព័ត៌មានប្រជាសាស្ត្រនៃសំណាកគំរូគ្រួសារ

| ក្រុម | ពេលវេលាពិភាក្សាក្រុម | ទីតាំងពិភាក្សាក្រុម | ចំនួនឪពុកម្តាយ | ភេទ/អាយុរបស់កុមារ | ការអប់រំរបស់កុមារ | អ្នកផ្តល់ព័ត៌មាន/អាយុឪពុកម្តាយ | មុខរបរ/ស្ថានភាពសង្គមសេដ្ឋកិច្ច |
|---|---|---|---|---|---|---|---|
| ១ | ២៥ មិថុនា ២០២១ | CCAMH | ៦ នាក់ (ឪពុក ២នាក់ ម្តាយ ៤ នាក់) នៅក្នុងរាជធានីភ្នំពេញ | ប្រ/៤ ឆ្នាំ | 1. មត្តេយ្យសិក្សា (សាលាឯកជន) | 1. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៣៩ ឆ្នាំ) & ឪពុក៖ ៥០ ឆ្នាំ) | 1.អាជីវកម្ម (ផ្ទះជួល ហើយឪពុកគឺជាបុគ្គលិកក្រុមហ៊ុន-ជនជាតិសឹង្ហបុរី។ |
| | | | | ប្រ/១១ ឆ្នាំ | 2. មិនចូលសាលា | 2. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៤១ ឆ្នាំ & ម្តាយ៖ ៣៩ ឆ្នាំ) | 2. ជាងជួសជុល-ឪពុក, ម្តាយគឺជាអ្នកលក់អង្ករ |
| | | | | ប្រ/ ៣ឆ្នាំ | 3. មិនចូលសាលា | 3. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៥០ ឆ្នាំ) & ម្តាយ(៤០ ឆ្នាំ) | 3. ទាំងពីរនាក់គឺជាមន្ត្រីរាជការ (ឪពុកធ្វើការនៅធនាគារជាតិនៃកម្ពុជា, ម្តាយធ្វើការនៅក្រសួងហិរញ្ញវត្ថុ) |
| | | | | ប្រ/ ៦ឆ្នាំ | 4.មត្តេយ្យសិក្សា (សាលាឯកជន) | 4. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៣៥ ឆ្នាំ & ឪពុក៖ ៣៣ ឆ្នាំ) | 4. បុគ្គលិករដ្ឋនៅ ប.ស.ស ហើយឪពុកគឺជាបុគ្គលិកក្រុមហ៊ុន |
| | | | | ប្រ/ ៧ ឆ្នាំ | 5.សាលាអប់រំពិសេស | 5. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៣៧ ឆ្នាំ) និងឪពុក៖ (៣៥ ឆ្នាំ)- ឪពុកម្តាយលែងលះគ្នា | 5.បុគ្គលិករដ្ឋនៅក្រសួងបរិស្ថាន |
| | | | | ស្រ/ ៤ឆ្នាំ | 6. មិនទៅសាលា | 6. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៣៩ ឆ្នាំ) និង ឪពុក៖ (៤៣ ឆ្នាំ) | 6.ម្តាយ៖អ្នកលក់អនឡាញ, ឪពុកជាងថតរូប |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ៩ កក្កដា ២០២១ | CCAMH | ៥ នាក់ (ឪពុក ៣ នាក់ និង ម្តាយ ២ នាក់) | ប្រ/ ៨ឆ្នាំ | 7.សាលាពិសេស (HHC) | 7. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (២៩ ឆ្នាំ) & ឪពុក (៣៨ ឆ្នាំ) | 7. ម្តាយគឺជាមេផ្ទះ ហើយឪពុកគឺជា មន្ត្រីឥណទាន |
| | | | | ស្រ/ ៥ឆ្នាំ | 8. មត្តេយ្យសិក្សា (សាលាឯកជន) | 8. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៤១ ឆ្នាំ) & ម្តាយ (៣៧ ឆ្នាំ) | 8. បុគ្គលិករដ្ឋនៅក្រសួងមហាផ្ទៃ-ឪពុក, ម្តាយ គឺជាគ្រូពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលា |
| | | | | ប្រ/ ៧ ឆ្នាំ | 9. សាលាឯកជន (សាលាសុវណ្ណភូមិ នៅថ្នាក់ទី ១) | 9. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៤០ ឆ្នាំ) & ឪពុក (៤៨ ឆ្នាំ) | 9. ទាំងពីរនាក់គឺជាអ្នកលក់ដូរ |
| | | | | ប្រ/ ៥ ឆ្នាំ | 10.មត្តេយ្យសិក្សា (សាលារដ្ឋ) | 10. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៣៧ ឆ្នាំ) & ម្តាយ(៣០ ឆ្នាំ) | 10. ឪពុកបុគ្គលិកដឹកជញ្ជូន ហើយម្តាយគឺជាបុគ្គលិកក្រុមហ៊ុនភីហ្សា។ |
| | | | | ប្រ/ ៩ឆ្នាំ | 11. សាលាពិសេស (សាលាទន្សាយ) | 11. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៤៥ ឆ្នាំ) & ម្តាយ(៤០ ឆ្នាំ) | 11. ឪពុក ជា មន្ត្រីរាជការនៅមន្ទីរកសិកម្មខេត្តកំពង់ចាម ហើយម្តាយធ្វើការនៅអគ្គិសនីកម្ពុជា (EDC) នៅខេត្តកំពង់ចាម |
| ៣ | ១២ កក្កដា ២០២១ | CCAMH | ៥នាក់ (ឪពុក ១ នាក់, ម្តាយ ៤នាក់) | ប្រ/ ១៤ឆ្នាំ | 12.សាលាពិសេស (សាលាទន្សាយ) | 12.ព័ត៌មានមិនមាន | 13. ម្តាយគឺជាអ្នកលក់ដូរ ហើយឪពុកគឺជាកីឡាករ។ |
| | | | | ប្រ/ ៧ឆ្នាំ | 13. សាលាពិសេស (HHC) | 13. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៤១ ឆ្នាំ) & ឪពុក(៤២ ឆ្នាំ) | 13. ឪពុកគឺជាអ្នកបើបរ ហើយម្តាយគឺជាមេផ្ទះ) |
| | | | | ប្រ/ ៤ឆ្នាំ | 14. មិនចូលសាលា | 14. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៣២ ឆ្នាំ) & ឪពុក(៤៥ឆ្នាំ) | 14. ឪពុកនិងម្តាយ គឺជាបុគ្គលិកក្រុមហ៊ុន |
| | | | | ប្រ/ ៦ឆ្នាំ | 15. មត្តេយសិក្សា (សាលាឯកជន) | 15. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៣៣ ឆ្នាំ) & ឪពុក៤៣ ឆ្នាំ) | 15. ទាំងឪពុកទាំងម្តាយ គឺជាអ្នកលក់ដូរ |
| | | | | F/4 ឆ្នាំ | 16. សាលាពិសេស (HHC) | 16. អ្នកផ្តល់ព័ត៌មាន៖ ជីដូន (ឪពុកអាយុ 37 ឆ្នាំ & ម្តាយ៖ 36 ឆ្នាំ) | 16. ទាំងឪពុកទាំងម្តាយ គឺជាអ្នកលក់ដូរ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | ១៤ កក្កដា ២០២១ | CCAMH | ៦នាក់ (ឪពុក ៥ នាក់ និង ម្តាយ ១ នាក់) | ប្រ/ ៥ឆ្នាំ | 17.មិននៅក្នុងសាលា | 17. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៤០ឆ្នាំ) & ម្តាយ (៤០ឆ្នាំ) | 17. ឪពុកគឺជាអ្នកលក់ដូរ ហើយម្តាយគឺជាបុគ្គលិករដ្ឋ (រដ្ឋបាល) នៅឯក្រសួងអប់រំ |
| | | | | ប្រ/ ៧ឆ្នាំ | 18. សាលាពិសេស (សាលាអប់រំពិសេស) | 18. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៣៨ឆ្នាំ & ម្តាយ៖ ៣៦ ឆ្នាំ) | 18. ឪពុកម្តាយជាអ្នកលក់ចាប់ហួយ |
| | | | | ស្រ/ ៩ឆ្នាំ | 19. សាលាឯកជន (ថ្នាក់ទី ១) | 19. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៤២ ឆ្នាំ & ម្តាយ (៤៣ ឆ្នាំ) | 19. ឪពុកជាអ្នករត់ម៉ូតកង់បី និង ម្តាយជាស្ត្រីមេផ្ទះ) |
| | | | | ប្រ/ ៧ឆ្នាំ | 20. សាលាឯកជន (ថ្នាក់ទី ១) នៅតាខ្មៅ ខេត្តកណ្តាល (សាលារដ្ឋ)។ | 20. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៣៦ ឆ្នាំ & ម្តាយ (៣២ ឆ្នាំ) | 20. ឪពុក និងម្តាយទាំងពីរជាបុគ្គលិករដ្ឋនៅក្រសួងសេដ្ឋកិច្ច និងក្រសួងសុខាភិបាល។ |
| | | | | ប្រ/ ៧ឆ្នាំ | 21. សាលាបឋមសិក្សា (ថ្នាក់ទី ២) ក្នុងខេត្តព្រៃវែង (សាលារដ្ឋ) | 21. អ្នកផ្តល់ព័ត៌មាន៖ ឪពុកអ(៣៤ ឆ្នាំ & ម្តាយ (៣០ ឆ្នាំ)។ | 21. ឪពុកម្តាយ គឺជាគ្រូបង្រៀនទាំងពីរនាក់។ |
| | | | | ប្រ/ ៣ ឆ្នាំ | 22. មត្តេយ្យសិក្សា (សាលាឯកជន) | 22. អ្នកផ្តល់ព័ត៌មាន៖ ឪពុក អាយុ ៣៣ ឆ្នាំ & ម្តាយ (២៩ ឆ្នាំ)។ | 22. ឪពុកនិងម្តាយ គឺជាអ្នកលក់ដូរទាំងពីរនាក់។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | ១៦ កក្កដា ២០២១ | CCAMH | ៧នាក់( ឳពុក ៤ នាក់, ម្តាយ ៣ នាក់ ) | ប្រ/ ៥ ឆ្នាំ | 23. មិនចូលសាលា | 23. អ្នកផ្តល់ព័ត៌មាន៖ ឳពុក ( ៣៦ ឆ្នាំ & ម្តាយ( ៣៥ ឆ្នាំ ) | 23.ឳពុកគឺជានគរបាល ហើយម្តាយគឺជាមេផ្ទះ |
| | | | | ប្រ/ ៥ឆ្នាំ | 24. មិនចូលសាលា | 24. អ្នកផ្តល់ព័ត៌មាន៖ ឳពុក  ( ៤៨ ឆ្នាំ & ម្តាយ៣១ឆ្នាំ ). | 24. ឳពុកគឺជាបុគ្គលិករដ្ឋនៅក្រសួងការបរទេស ហើយម្តាយគឺជាបុគ្គលិកក្រុមហ៊ុន |
| | | | | ប្រ/ ៦ឆ្នាំ | 25. មិនចូលសាលា | 25. អ្នកផ្តល់ព័ត៌មាន៖ ឳពុក ( ៣៩ ឆ្នាំ & ម្តាយ ( ៣៦ ឆ្នាំ ) | 25. ឳពុកជានគរបាន ហើយម្តាយជាគ្រូពេទ្យនៅមន្ទីរពេទ្យបង្អែកមានជ័យ រាជធានីភ្នំពេញ។ |
| | | | | M/ 7 ឆ្នាំ | 26. គ្មានព័ត៌មាន | គ្មានព័ត៌មាន | 26. គ្មានព័ត៌មាន |
| | | | | ប្រ/ ៧ឆ្នាំ | 27.  មត្តេយ្យសិក្សា ( សាលាឯកជន ) | 27. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ  ( ៣៧ ឆ្នាំ & ឳពុក( ៤៤ ឆ្នាំ ) | 27. ឳពុកនិងម្តាយ គឺជាអ្នកលក់ម៉ូតូ។ |
| | | | | ប្រ/ ៧ឆ្នាំ | 28. សាលាមត្តេយ្យ ( សាលារដ្ឋ ) | 28. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ   ( ៣០ ឆ្នាំ & ឳពុក ( ៣៣ ឆ្នាំ ) | 28. ឳពុកម្តាយគឺជាបុគ្គលិកក្រុនហ៊ុន |
| | | | | ប្រ/ ៧ឆ្នាំ | 29. សាលាពិសេស ( សាលាឯកជន - King Kids ) | 29. អ្នកផ្តល់ព័ត៌មាន៖ ឳពុក   ( ៣៨ឆ្នាំ & ម្តាយ ( ៣៦ ឆ្នាំ ) | 29. ឳពុកម្តាយគឺជាអ្នកលក់នំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | ២២ កក្កដា ២០២១ | កំពង់ចាម | ៥ នាក់ (គ្មានឪពុក, ម្តាយ ៥ នាក់) | ប្រ/ ៥ឆ្នាំ | 30. មិនទៅសាលា | 30. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ(២៨ ឆ្នាំ & ឪពុក(២៩ ឆ្នាំ) | 30.ម្តាយគឺជាគ្រូបឋមសិក្សាជាប់កិច្ចសន្យា ហើយឪពុកគឺជាកសិករ។ |
| | | | | ប្រ/ ៦ឆ្នាំ | 31. សាលាពិសេស King Kids (១ ថ្ងៃក្នុងមួយសប្តាហ៍ រៀងរាល់ថ្ងៃអាទិត្យ) | 31. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៣៣ឆ្នាំ & ឪពុក(៣៧ ឆ្នាំ) | 31.ម្តាយគឺជាធ្មប ហើយឪពុកគឺជាគិលានុបដ្ឋាយិកានៅខេត្តព្រៃវែង។ |
| | | | | ប្រ/ ៥ឆ្នាំ | 32. សាលាមត្តេយ្យ (សាលារដ្ឋ) | 32. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (២២ ឆ្នាំ & ឪពុក(២១ ឆ្នាំ) | 32. ម្តាយគឺជាគ្រូ ហើយឪពុកគឺជាកសិករ។ |
| | | | | ប្រ/ ៦ឆ្នាំ | 33. សាលាបឋមសិក្សា (សាលារដ្ឋ) ក្នុងខេត្តក្រចេះ | 33. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៤១ ឆ្នាំ & ឪពុក(៥៣ ឆ្នាំ) | 33. ឪពុកម្តាយគឺជាគ្រូវិទ្យាល័យទាំងពីរនាក់ |
| | | | | ប្រ/ ៨ឆ្នាំ | 34. មិនចូលសាលា | 34. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៣៤ ឆ្នាំ & ឪពុកអាយុ ៤២ ឆ្នាំ). | 34. ម្តាយគឺ ជាអ្នកលក់ដូរនៅផ្ទះ ហើយ ឪពុកគឺជាកសិករ។ |
| ៧ | ១៩ សីហា ២០២១ | កំពង់ចាម | ៧នាក់ (ឪពុក ៥ នាក់ និង ម្តាយ២) | ប្រ/ ៦ឆ្នាំ | 35. សាលាបឋមសិក្សា ថ្នាក់ទី ១ (សាលាឯកជន) នៅខេត្តកំពង់ចាម | 35. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៤៣ ឆ្នាំ & ម្តាយ(៤០ ឆ្នាំ) | 35. ឪពុកគឺជាបុគ្គលិករដ្ឋ - ការងាររដ្ឋ ហើយម្តាយគឺជាគ្រូបង្រៀននៅវិទ្យាល័យ (អក្សរសាស្ត្រខ្មែរ)។ |
| | | | | ប្រ/ ៩ឆ្នាំ | 36. មិនចូលរៀន | 36. អ្នកផ្តល់ព័ត៌មាន៖ ម្តាយ (៤៣ ឆ្នាំ & ឪពុក (៤៨ឆ្នាំ) | 36.ឪពុកជាអ្នកលក់មាស និង ម្តាយជាស្ត្រីមេផ្ទះ |
| | | | | ប្រ/ ៦ឆ្នាំ | 37. គ្មានព័ត៌មាន | | |
| | | | | ប្រ/ ៧ឆ្នាំ | 38. គ្មានព័ត៌មាន | | |
| | | | | ប្រ/ ៧ឆ្នាំ | 39. គ្មានព័ត៌មាន | | |
| | | | | ប្រ/ ៧ឆ្នាំ | 40. គ្មានព័ត៌មាន | | |
| | | | | ប្រ/ ៥ឆ្នាំ | 41. សាលាមត្តេយ្យ (សាលាឯកជន នៅស្រុកជើងព្រៃ) | 41. អ្នកផ្តល់ព័ត៌មាន៖ ឪពុក (៣៤ ឆ្នាំ & ម្តាយ (២៩ ឆ្នាំ) | 41. ឪពុកគឺជាអ្នកលក់ទូរស័ព្ទ ហើយម្តាយគឺជាអ្នកលក់បន្លែ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | ២ កញ្ញា ២០២១ | បាត់ដំបង | ៤នាក់ (ឪពុក ១ នាក់ និង ម្ដាយ ៣នាក់) | ស្រី/ ៤.៥ឆ្នាំ | 42. សាលាពិសេស (ផ្ទះដូង NGO) | 42. អ្នកផ្ដល់ព័ត៌មាន៖ ម្ដាយ (៣៩ ឆ្នាំ & ឪពុក(៤១ ឆ្នាំ) | 42. ឪពុកម្ដាយគឺជាបុគ្គលិកក្រុមហ៊ុន |
| | | | | ប្រ/ ៧ឆ្នាំ | 43. សាលាបឋមសិក្សា (សាលាឯកជន -ថ្នាក់ទី ១ បញ្ញាសាស្ត្រ) | 43. អ្នកផ្ដល់ព័ត៌មាន៖ ឪពុក (៣៥ ឆ្នាំ & ម្ដាយ(៣០ ឆ្នាំ) | 43. ឪពុកគឺជាគ្រូបង្រៀននៅសកលវិទ្យាល័យ ហើយម្ដាយធ្វើការនៅធនាគារ |
| | | | | ប្រ/ ៧ឆ្នាំ | 44. សាលាបឋមសិក្សា (សាលារដ្ឋនៅថ្នាក់ទី ១) | 44. អ្នកផ្ដល់ព័ត៌មាន៖ ម្ដាយ (៣៩ ឆ្នាំ) & ឪពុក(៥២ ឆ្នាំ) | 44. ឪពុកគឺជាអ្នកលក់គ្រឿងទេស និងម្ដាយគឺជាគ្រូបឋមសិក្សា |
| | | | | ប្រ/ ៨ឆ្នាំ | 45. សាលាមត្តេយ្យ (សាលាឯកជនសុវណ្ណភូមិ) | 45. អ្នកផ្ដល់ព័ត៌មាន៖ ម្ដាយ៖ (៣៨ ឆ្នាំ) & ឪពុក(៤០ ឆ្នាំ) | 45. ឪពុកម្ដាយគឺជាអ្នកលក់ដូរ (បាន ឆ្នាំង) |
| ៩ | ៣ កញ្ញា ២០២១ | បាត់ដំបង | ៤នាក់ (ឪពុក ១ នាក់ និងម្ដាយ ៣ នាក់ | ប្រ/ ៧ឆ្នាំ | 46. សាលាបឋមសិក្សា (សាលារដ្ឋនៅថ្នាក់ទី ១) | 46. អ្នកផ្ដល់ព័ត៌មាន៖ បងស្រី. ឪពុក (៤៥ ឆ្នាំ) & ម្ដាយចុង: ៤៣ ឆ្នាំ) | 46. ឪពុកគឺជាជាងថតរូប ហើយម្ដាយជាអ្នកលក់ត្រី |
| | | | | ប្រ/ ៥ឆ្នាំ | 47. សាលាពិសេស (ផ្ទះដូង NGO) | 47. អ្នកផ្ដល់ព័ត៌មាន៖ ម្ដាយ (៣១ ឆ្នាំ) & ឪពុក(៣៨ ឆ្នាំ) | 47. ឪពុកគឺជាបុគ្គលិករដ្ឋ-ខាងសង្គមកិច្ចស្រុក និងម្ដាយជាស្ត្រីមេផ្ទះ) |
| | | | | ប្រ/ ៧ឆ្នាំ | 48. សាលាបឋមសិក្សា (សាលារដ្ឋនៅថ្នាក់ទី ១) | 48. អ្នកផ្ដល់ព័ត៌មាន៖ ជីដូន ឪពុក (៣១ ឆ្នាំ) និងម្ដាយ (៤០ ឆ្នាំ) – ឪពុកម្ដាយលែងលះ | 48. ឪពុកធ្វើការនៅក្រុមហ៊ុនសាងសង់ផ្លូវ ហើយម្ដាយគឺជាបុគ្គលិកក្រុមហ៊ុន (Easycom) |
| | | | | ប្រ/ ៥ឆ្នាំ | 49. សាលាមត្តេយ្យ (សាលាឯកជន- សាលាកុលបុត្រ) | 49. អ្នកផ្ដល់ព័ត៌មាន៖ ឪពុក (៣៤ ឆ្នាំ) & ម្ដាយ(៣៥ ឆ្នាំ) | 49. ឪពុកគឺជាប្រធានក្រុមហ៊ុន ហើយម្ដាយជាគ្រូ វិទ្យាល័យ (បង្រៀនរូបវិទ្យា និងគីមីវិទ្យា) |
| សរុប | ភ្នំពេញ កណ្ដាល ព្រៃវែង ក្រចេះ កំពង់ចាម បាត់ដំបង | ៤៩ | ៤៩នាក់ (ប្រុស ៤៤ និង ស្រី៥) | | | | |

### រូបភាពទី ២. កម្រងអាយុនៃកុមារនៅក្នុងសំណាកគំរូ៖




### រូបភាពទី ៣. ការចុះឈ្មោះក្នុងសាលា៖



## រូបភាពទី ៤. ប្រភេទនៃសាលាដែលបានចូលរៀន៖

ប្រភេទសាលា

សាលាពិសេស៖ កុមារ ១១ នាក់ (៣២.៤%)

សាលាឯកជន៖ ១៣ នាក់ (៣៨.២%)

សាលារដ្ឋ៖ កុមារ ១០ នាក់ (២៩.៤%)




## រូបភាពទី ៥. ស្ថានភាពសេដ្ឋកិច្ចគ្រួសារ៖

ស្ថានភាពសេដ្ឋកិច្ច

ស្ថានភាពសេដ្ឋកិច្ចខ្ពស់៖ ២ (៤.១%)

ស្ថានភាពសេដ្ឋកិច្ចកណ្ដាល៖ ៣៥ (៧១.៤%)

ស្ថានភាពសេដ្ឋកិច្ចទាប៖ ១២ (២៤.៥%)



**ការវិភាគទិន្នន័យ៖** បទសម្ភាសន៍ និងក្រុមគោលដៅត្រូវបានថតជាសំឡេង ចម្លងអត្ថបទសូរសំឡេង និងសង្ខេប។ បន្ទាប់មក ត្រូវដាក់កូដតាមប្រធានបទផ្សេងៗ និងដំណើរការកាត់បន្ថយកូដដើម្បីទទួលបានប្រភេទផ្សេងៗ និងកំណត់បញ្ហាសំខាន់ៗដែលកើតចេញពីទិន្នន័យ។ កូដដែលបានមកពីសំណួរស្រាវជ្រាវបឋម ប៉ុន្តែក៏ត្រូវបានរងផលប៉ះពាល់ដោយសារស្ថានភាពថ្មីៗ ដែលបានកើតឡើង នៅពេលដែលបានប្រមូលទិន្នន័យ។ រាល់កូដទាំងអស់មានផ្តល់ជានិយមន័យដែលត្រូវប្រកាន់ខ្ជាប់ដើម្បីផ្ទៀងផ្ទាត់មើលទំនុកចិត្តនៃការបកស្រាយ (សូមមើលខាងក្រោម)។ ដំណើរការនៃការវិភាគទិន្នន័យអ្នកឆ្លើយសំណួរច្រើនគ្នាបានផ្តល់ចម្លើយដែលបែងចែកជាត្រីកោណទៅនឹងសំណុំទិន្នន័យ។

**តារាងទី១ កូដជាមួយនឹងនិយមន័យ**

| កូដ | និយមន័យ |
|---|---|
| AR | ការលើកកម្ពស់ការយល់ដឹង៖ ចាំបាច់ត្រូវលើកកម្ពស់ការយល់ដឹងអំពីអូទីស្សឹម និងពិការភាពឱ្យកាន់តែទូលំទូលាយថែមទៀត |
| AS | ឱកាសបានចូលរៀន៖ ត្រូវផ្តោតការយកចិត្តទុកដាក់ និងចាំបាច់ត្រូវឱ្យកុមារអូទីស្សឹម/កុមារមានពិការភាពបានចូលរៀន |
| ASS | ការវាយតម្លៃ៖ ការវាយតម្លៃគឺជាផ្នែកដ៏សំខាន់មួយក្នុងការកំណត់តម្រូវការនិងផ្តល់ការគាំទ្រ |
| ATS+ | ការទទួលបានសេវាព្យាបាល៖ ផ្តល់ឱកាសទទួលបានសេវាព្យាបាល |
| ATS- | ការទទួលបានសេវាព្យាបាលមិនគ្រប់គ្រាន់៖ ការទទួលបានសេវាព្យាបាលនៅមានកម្រិត |
| BE | អាកប្បកិរិយា៖ អាកប្បកិរិយាដែលត្រូវបានកំណត់ថា ជាបញ្ហាមួយនៅក្នុងការគ្រប់គ្រង ឬការអប់រំកុមារអូទីស្សឹម |
| CBR | ការស្តារលទ្ធភាពពលកម្មតាមសហគមន៍៖ ការស្តារលទ្ធភាពពលកម្មតាមសហគមន៍អាចបានទៅដល់គ្រួសារនានា។ |
| CI | ការចូលរួមពីសហគមន៍៖ ការលើកទឹកចិត្តឱ្យសហគមន៍ចូលរួមក្នុងការគាំទ្រជនមានអូទីស្សឹម/ជនមានពិការភាព |
| COLLNGO | កិច្ចសហការរវាងអង្គការមិនមែនរដ្ឋាភិបាល៖ មានភស្តុតាងបញ្ជាក់ពីកិច្ចសហការ រវាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការគាំទ្រដល់ជនមានអូទីស្សឹម/ជនមានពិការភាព |
| CPI | បញ្ហាកិច្ចគាំពារកុមារ៖ ការរំលោភបំពានផ្លូវកាយ និងផ្លូវភេទនៅតែជាហានិភ័យសម្រាប់កុមារមានពិការភាព/អូទីស្សឹម |
| DIS | ចម្ងាយ និងឧបសគ្គ៖ ចម្ងាយជាឧបសគ្គមួយក្នុងការទទួលបានសេវាគាំទ្រផ្សេងៗ |
| DISC | ការរើសអើង៖ មានការរើសអើងលើជនមានអូទីស្សឹម/ជនមានពិការភាព |
| EMP | ការចូលបម្រើការងារ៖ មិនសូវមានឱកាសការងារសម្រាប់ជនមានអូទីស្សឹម/ជនមានពិការភាព |
| FR | សម្ភារប្រើប្រាស់ និងធនធាន៖ ឱកាសទទួលបានការអប់រំ និងសេវាផ្សេងទៀតអាស្រ័យលើសម្ភារប្រើប្រាស់ និងធនធាន |
| GOV | ការចូលរួមរបស់រដ្ឋាភិបាល៖ រដ្ឋាភិបាល/ក្រសួង/ស្ថាប័នដើរតួនាទីផ្ទាល់ក្នុងការផ្តល់ជូនជនមានអូទីស្សឹម/ជនមានពិការភាព |
| IE | ការអប់រំប្រកបដោយបរិយាបន្ន៖ ត្រូវផ្តោតការយកចិត្តទុកដាក់ ឬចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យអប់រំឱ្យកាន់តែប្រកបដោយបរិយាបន្នថែមទៀត |
| IEP | ផែនការអប់រំបុគ្គល៖ ផែនការអប់រំបុគ្គលត្រូវបានរៀបចំឡើងសម្រាប់កុមារមានពិការភាព/អូទីស្សឹម |
| LEP | កង្វះការផ្តល់ការអប់រំ៖ ការផ្តល់ការអប់រំមិនគ្រប់គ្រាន់មានន័យថា កុមារមិនមានឱកាសចូលរៀន |

| កូដ | និយមន័យ |
| --- | --- |
| LS | ការគាំទ្រផ្នែកផ្លូវច្បាប់៖ ឪពុកម្ដាយត្រូវការការគាំទ្រផ្នែកផ្លូវច្បាប់ |
| PA | ការផ្ដល់លទ្ធភាពក្នុងការទទួលបាន៖ ការផ្ដល់នេះត្រូវធានាថា បុគ្គលគ្រប់រូប រួមទាំងជនមានអូទីស្សឹម ឬជនមានពិការភាពមានឱកាសអាចទទួលបាន |
| PKR | ឪពុកម្ដាយដើរតួនាទីជាចម្បង៖ ភស្តុតាងបញ្ជាក់ពីការចូលរួមដោយផ្ទាល់ពីឪពុកម្ដាយក្នុងការគាំទ្រដល់កុមារមានអូទីស្សឹម/ជនមានពិការភាព |
| POV | ភាពក្រីក្រ៖ ភាពក្រីក្រជាកត្តាមួយនៅក្នុងគ្រួសារក្នុងការទទួលបានសេវា |
| PSEO | ឪពុកម្ដាយគាំទ្រគ្នាទៅវិញទៅមក៖ ឪពុកម្ដាយដើរតួនាទីដ៏សំខាន់ក្នុងការគាំទ្រគ្នាទៅវិញទៅមក |
| RUR/URB | ជនបទ/ទីក្រុង៖ មានភាពខុសគ្នាជាក់លាក់នៃការផ្ដល់សេវាគាំទ្រនៅក្នុងតំបន់ជនបទ និងទីក្រុងនៃប្រទេសកម្ពុជា។ |
| PL | ការរកទីកន្លែងឱ្យបុគ្គលទាំងនេះ៖ កិច្ចប្រឹងប្រែងដើម្បីរកទីកន្លែងកុមារមានអូទីស្សឹម/ជនមានពិការភាព |
| TN | ការផ្ដល់ការបណ្ដុះបណ្ដាលដោយអង្គការមិនមែនរដ្ឋាភិបាល៖ បានផ្ដល់ការបណ្ដុះបណ្ដាលមួយចំនួនដល់អ្នកមានវិជ្ជាជីវៈតាមរយៈអង្គការមិនមែនរដ្ឋាភិបាល |
| TP | ការបណ្ដុះបណ្ដាលដល់ឪពុកម្ដាយ៖ ផ្ដល់ការបណ្ដុះបណ្ដាលដល់ឪពុកម្ដាយរបស់កុមារមានពិការភាព |
| TT | ការបណ្ដុះបណ្ដាលគ្រូបង្រៀន៖ ចាំបាច់ត្រូវផ្ដល់ការបណ្ដុះបណ្ដាលដល់គ្រូបង្រៀនដោយរាប់បញ្ចូលការលើកកម្ពស់ឥរិយាបថវិជ្ជមាន និងការយល់ដឹងអំពីអូទីស្សឹម និងពិការភាព |

## បញ្ហាប្រឈមក្នុងអំឡុងពេលអនុវត្តគម្រោង និងដំណោះស្រាយ

គម្រោងនេះកំពុងត្រូវបានអនុវត្តក្នុងអំឡុងពេលមានជំងឺរាតត្បាតជាសកល។ ពេលខ្លះ គម្រោងនេះបានបង្អាក់លទ្ធភាពរបស់សមាជិកក្រុមការងារក្នុងការធ្វើដំណើរដើម្បីទទួលបានទិន្នន័យ។ ការងារចុះមូលដ្ឋានត្រូវបានធ្វើឡើងនៅតំបន់ជនបទ ប៉ុន្តែអាចធ្វើបានតែនៅពេលដកការរឹតបន្តឹងលើការធ្វើដំណើរប៉ុណ្ណោះ។ ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងពីចម្ងាយបានផ្ដល់លទ្ធភាពឱ្យសមាជិកក្រុមការងារអាចធ្វើការសម្ភាសបុគ្គលម្នាក់ៗបាន ដែលវាមានសារសំខាន់ក្នុងការបំពេញកាតព្វកិច្ចក្នុងការសម្ភាសអ្នកដែលត្រូវចូលរួម។ ការសម្ភាសដោយផ្ទាល់ជាក្រុមក៏ត្រូវបានរៀបចំផងដែរ ប៉ុន្តែពេលវេលាមានកំណត់ ដោយហេតុថាការងារនេះអនុវត្តបាននៅពេលមានការដកការរឹតបន្តឹងលើការធ្វើដំណើរ។

ការប្រមូលទិន្នន័យត្រូវបានចាត់ចែងយ៉ាងណាឱ្យមានភាពងាយស្រួលដល់អ្នកចូលរួម។ ក្រុមគោលដៅ និងបទសម្ភាសន៍មួយចំនួនត្រូវបានធ្វើឡើងដោយសមាជិកក្រុមការងារគម្រោងធ្វើជាភាសាខ្មែរ ហើយបទសម្ភាន៍ខ្លះទៀតធ្វើឡើងជាភាសាអង់គ្លេស។ ការធ្វើបែបនេះបានអនុញ្ញាតឱ្យអ្នកចូលរួមទាំងអស់អាចជ្រើសរើសភាសាដែលពួកគេចង់បាន ហើយថែមទាំងអាចឱ្យសមាជិកក្រុមការងារគម្រោងទាំងអស់ចូលរួមពេញលេញនៅក្នុងដំណើរការប្រមូលទិន្នន័យ។ ការបកប្រែអត្ថបទសូរសំឡេងពីភាសាខ្មែរទៅអង់គ្លេសបានធ្វើដោយសមាជិកក្រុមការងារដើម្បីជួយដល់អ្នកដឹកនាំគម្រោងអាចចូលប្រើប្រាស់ទិន្នន័យទាំងអស់បានពេញលេញ។

# របកគំហើញបឋម

## របកគំហើញទី១៖

រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាការធានាឱ្យមានលទ្ធភាពទទួលបានការអប់រំ សេវាសុខភាព និងសុខុមាលភាពសង្គម សមរម្យសម្រាប់ជនមានពិការភាពទាំងអស់ ហើយបានធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការបង្កើតគោលនយោបាយនានា។ ខណៈពេលដែលមានភស្តុតាងថ្មីៗនៃការអនុវត្តល្អៗមួយចំនួនក្នុងការផ្តល់ជូនជនមានពិការភាព រួមទាំងអ្នកមានអូទីស្សឹម ក៏ប៉ុន្តែគម្លាតរវាងគោលនយោបាយ និងការអនុវត្តនៅតែមានច្រើនផងដែរ។

ច្បាប់ស្តីពីកិច្ចការការពារ និងលើកកម្ពស់សិទ្ធិជនពិការ (២០០៩) កំណត់ពីការចូលរួមរបស់រដ្ឋាភិបាល ហើយក្នុងមាត្រា២ បានអះអាងពីការចូលរួមមួយដើម្បី៖

- អនុវត្តគោលនយោបាយក្នុងគោលបំណងធានា ថាសិទ្ធិជនមានពិការភាពត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅដូចជនគ្រប់រូបនៅក្នុងប្រទេសកម្ពុជា។
- ការពារសិទ្ធិ និងសេរីភាពរបស់ជនមានពិការភាព
- ការពារផលប្រយោជន៍របស់ជនមានពិការភាព
- ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងចំពោះជនមានពិការភាព
- ស្តារលទ្ធភាពពលកម្ម ទាំងផ្លូវកាយ ផ្លូវចិត្ត និងវិជ្ជាជីវៈ ដើម្បីធានាថា ជនមានពិការភាពអាចចូលរួមយ៉ាងពេញលេញ និងស្មើភាពក្នុងសកម្មភាពនៅក្នុងសង្គម។

នៅក្នុងច្បាប់នេះ ការបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ គឺជាចលនាយុទ្ធសាស្ត្រដ៏សំខាន់មួយ ហើយបានធានានូវស្ថាប័នសកម្មមួយ ដែលបានផ្តល់នូវការយល់ដឹងច្បាស់អំពីការអភិវឌ្ឍក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ស្ថាប័ននេះបានត្រួតពិនិត្យការបង្កើតផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០១៤-២០១៨ (NDSP) ហើយបានរក្សានូវទិដ្ឋភាពទូទៅនៃការអនុវត្តរបស់ខ្លួន និងបានផ្សព្វផ្សាយការពិនិត្យឡើងវិញនូវសមិទ្ធផល។ ការពិនិត្យឡើងវិញបាននាំទៅដល់ការបង្កើតផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពថ្មី ឆ្នាំ២០១៩-២០២៣ (NDSP) ដែលបញ្ជាក់ឡើងវិញនូវការប្តេជ្ញាក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងអស់ដែលមានពិការភាព។

ស្របជាមួយនឹងយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ការអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ និងគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច (២០១០) បង្ហាញពីវិធីសាស្ត្រវឌ្ឍនភាពក្នុងការដោះស្រាយការអប់រំសម្រាប់ទាំងអស់គ្នាដែលវាជាគោលដៅអប់រំប្រកបដោយនិរន្តរភាព ដែលកម្ពុជាជាហត្ថលេខី។

ខណៈពេលដែលវឌ្ឍនភាពឆ្ពោះទៅរកការបង្កើតសង្គមមួយប្រកបដោយបរិយាបន្ន និងសមធម៌បន្ថែមទៀតសម្រាប់ជនមានពិការភាព គឺជាក់ស្តែងនៅក្នុងគំនិតផ្តួចផ្តើមសំខាន់ៗទាំងនេះ គម្លាតដ៏សំខាន់នៅតែមានរវាងការចូលរួម និងការអនុវត្តគោលនយោបាយ។ចំណុចទាំងនេះត្រូវបានគូសបញ្ជាក់នៅក្នុងរបកគំហើញខាងក្រោម។

ឯកសារទាក់ទងនឹងពិការភាពក្នុងប្រទេសកម្ពុជា ច្រើនតែត្រូវបាននិយាយជាទូទៅដោយមានការលើកឡើងជាក់លាក់អំពីលក្ខខណ្ឌដែលត្រូវបានធ្វើរោគវិនិច្ឆ័យ ដូចជាបញ្ហាអូទីស្សឹមដែលគេកម្រលើកឡើង។ ភាសាដែលប្រើប្រាស់នៅក្នុងឯកសារភាគច្រើនបង្ហាញពីគំរូវេជ្ជសាស្ត្រ បើទោះបីជាមានការចង់ផ្លាស់ប្តូរទៅជាគំរូសង្គម និងបរិយាបន្នក៏ដោយ។ យុទ្ធសាស្ត្រប្រចាំតំបន់អាស៊ីអាគ្នេយ៍របស់អង្គការសុខភាពពិភពលោកស្តីពីអូទីស្សឹម (២០១៧) ទទួលស្គាល់ឱនភាពដែលមានស្រាប់ទាក់ទងនឹងការយល់ដឹងអំពីអូទីស្សឹម និងរចនាសម្ព័ន្ធដែលមាននាពេលបច្ចុប្បន្ន ដើម្បីផ្តល់ការគាំទ្រចាំបាច់ផ្សេងៗ។ នៅពេលមានការផ្តោតការយកចិត្តទុកដាក់ទៅលើអូទីស្សឹម វាជាទូទៅជាការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ឬគ្រឹះស្ថាន និង ស្ថាប័នឯកទេសដែលផ្តល់សេវាសម្រាប់ពិការភាពយ៉ាងទូលំទូលាយ។ ប៉ុន្តែ មានឆន្ទៈច្បាស់លាស់ក្នុងការដោះស្រាយស្ថានភាពនេះ នៅក្នុងរដ្ឋបាលគ្រប់ជាន់ថ្នាក់ក្នុងប្រទេសកម្ពុជា និងដោះស្រាយចំណុចខ្វះខាតផ្សេងៗ។

## របកគំហើញទី២៖

ការយល់ដឹងអំពីអូទីស្សឹម ទាំងក្នុងចំណោមប្រជាជនទូទៅ និងក្រុមអ្នកជំនាញ ព្រមទាំង ប្រធានអង្គការលើកិច្ចការជំនឿ/សាសនានៅកម្ពុជានៅមានកម្រិតនៅឡើយ។ ការកំណត់លក្ខណៈនៃអូទីស្សឹមមិនមានអ្នកយល់ដឹង ហើយឱកាសសម្រាប់អភិវឌ្ឍចំណេះដឹងវិជ្ជាជីវៈនៅក្នុងផ្នែកនេះក៏មានតិចតួចណាស់ លើកលែងតែអង្គការឯកទេសមួយចំនួនតូច។

ខណៈពេលដែលមានអង្គការ និងបុគ្គលមួយចំនួននៅក្នុងប្រទេសកម្ពុជាដែលមានបទពិសោធន៍ និងចំណេះដឹងអំពីអូទីស្សឹម ការយល់ដឹងអំពីបញ្ហានេះក្នុងចំណោមប្រជាជនទូទៅនៅមានកម្រិតនៅឡើយ។ ឪពុកម្តាយរបស់កុមារមានអូទីស្សឹមបានរាយការណ៍ថា ពួកគេមានការយល់ដឹងអំពីបញ្ហាអូទីស្សឹម បន្ទាប់ពីទទួលបានការធ្វើរោគវិនិច្ឆ័យជាផ្លូវការនៃតម្រូវការរបស់កូនរបស់ខ្លួន។ បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យ មនុស្សជាច្រើននៅតែមិនច្បាស់លាស់អំពីលក្ខណៈទូទៅនៃអូទីស្សឹម ជាពិសេស អំពីសក្តានុពលសម្រាប់ការអប់រំ និងការអភិវឌ្ឍសង្គម។ កិច្ចពិភាក្សាជាក្រុមដែលបានរៀបចំឡើងជាមួយឪពុកម្តាយកុមារមានអូទីស្សឹម បង្ហាញថា មនុស្សជាច្រើននៅតែបន្តស្វែងរកការព្យាបាលសម្រាប់កូនរបស់ពួកគេ ហើយខ្លះទៀតមិនច្បាស់ថាតើស្ថានភាពនេះអាចឆ្លង ឬមិនឆ្លង។ ឪពុកម្តាយផ្សេងទៀតបានថ្លែងថា ពួកគេមានការភ័ន្តច្រឡំអំពីលក្ខណៈនៃពិការភាព និងថាតើកូនរបស់ខ្លួនដែលមានអូទីស្សឹមមានលក្ខណៈស្រដៀងនឹងអ្នកផ្សេងទៀតដែលគេចាត់ថ្នាក់ថា មានពិការភាពដែរឬទេ។ ជាឧទាហរណ៍ ម្តាយម្នាក់បានរាយការណ៍ថា គាត់យល់ច្រឡំ អូទីស្សឹមជាមួយនឹងដោនស៊ីនដ្រូម។ ម្តាយម្នាក់ទៀតបានស្វែងយល់ពីអូទីស្សឹមតាមរយៈតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីយល់ពីតម្រូវការកូនរបស់ខ្លួន៖ "ថ្ងៃមួយ ខ្ញុំបានឃើញវីដេអូនៅលើ ហ្វេសប៊ុកដែលនិយាយអំពីជំងឺអូទីស្សឹម។ គេនិយាយថា កុមារដែលមានជំងឺនេះគឺបែបហ្នឹងឯង។ ពួកគេមិនងាកមករកអ្នកទេនៅពេលដែលអ្នកហៅពួកគេ។ ខ្ញុំមិនដែលស្គាល់ជំងឺអូទីស្សឹមនេះទេ ដូច្នេះ ខ្ញុំបានមើលវីដេអូដើម្បីឱ្យដឹងកាន់តែច្បាស់ ដើម្បីដឹងពីមូលហេតុដែលពួកគេមិនមានប្រតិកម្មនៅពេលគេហៅ។ បន្ទាប់ពីអានអត្ថបទមួយចំនួន ខ្ញុំបានដឹងថា អូ! កូនរបស់ខ្ញុំប្រហែលជាកើតជំងឺអូទីស្សឹមហើយ"។

កង្វះការយល់ដឹងក្នុងចំណោមប្រជាជនទូទៅបានបណ្តាលឱ្យកុមារ និង គ្រួសារមួយចំនួនប្រឈមនឹងការរើសអើង។ ឪពុកម្តាយមួយចំនួនបានរាយការណ៍ថា កូនរបស់ខ្លួនត្រូវបានគេហៅថា ឆ្កួត និងគ្រោះថ្នាក់ ហើយអ្នកផ្សេងទៀតត្រូវគេបំបាក់ទឹកចិត្តមិនឱ្យសេពគប់ជាមួយពួកគេ។ ឪពុកម្តាយរបស់កុមារអូទីស្សឹម ច្រើនតែគេចោទប្រកាន់ពីការមិនបានចិញ្ចឹមកូនឱ្យបានល្អ និងខ្វះការគ្រប់គ្រងលើអាកប្បកិរិយាកូនរបស់ខ្លួន។ ការពិភាក្សាជាក្រុមដែលបានរៀបចំឡើងជាមួយឪពុកម្តាយកុមារអូទីស្សឹម នៅខេត្តកំពង់ចាម និងបាត់ដំបង បានលើកឡើងថា ការផាត់ចេញនិងការរើសអើង វាជាលទ្ធផលនៃការយល់ដឹងតិចតួច ជាពិសេសបញ្ហានេះច្រើនកើតមាននៅតំបន់ជនបទ។

យុទ្ធនាការលើកកម្ពស់ការយល់ដឹងត្រូវបានរៀបចំឡើងនៅក្នុងប្រទេសកម្ពុជា ដោយមានការគាំទ្រពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដោយប្រើប្រព័ន្ធផ្សព្វផ្សាយជាច្រើន ប៉ុន្តែច្បាស់ណាស់ថា ឥទ្ធិពលនៃប្រព័ន្ធទាំងនេះនៅមានកម្រិត។ ស្ថាប័ននានា រួមទាំងវិទ្យាស្ថានជាតិអប់រំពិសេស បានរៀបចំសិក្ខាសាលា ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងទទួលស្គាល់ពីតម្រូវការ ដើម្បីពង្រីកប្រភេទសកម្មភាពនេះ។ ឪពុកម្តាយ និងអ្នកជំនាញជាច្រើននាក់ទទួលបានព័ត៌មានអំពីជំងឺអូទីស្សឹម តាមរយៈវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមជាច្រើន។ ប៉ុន្តែព័ត៌មានដែលទទួលបានពីការសម្ភាសន៍បានឆ្លើយថា ប្រភពព័ត៌មានទាំងនេះហាក់ដូចជាមិនគួរឱ្យទុកចិត្ត ដោយអ្នកខ្លះបានលើកឡើងថា គេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមមួយចំនួន ច្រើនតែជាព័ត៌មានមិនត្រឹមត្រូវ។

មានអង្គការនានាក្នុងប្រទេសកម្ពុជា ដែលមានការយល់ដឹងច្បាស់អំពីជំងឺអូទីស្សឹម។ ទាំងនេះរួមមាន អង្គការធ្វើឱ្យប្រសើរឡើងដល់សេវាព្យាបាលការប្រាស្រ័យទាក់ទង និងលេបអាហារនៅកម្ពុជា (OIC) ដែលផ្តល់ជំនួយព្យាបាលដល់កុមារ និងមនុស្សវ័យជំទង់មួយចំនួនដែលមានជំងឺអូទីស្សឹម អង្គការសេវាអភិវឌ្ឍន៍ជនពិការ (DDSP) ខេត្តពោធិ៍សាត់ អង្គការសមាគមសម្រាប់ជំនួយនឹងសង្គ្រោះនៃប្រទេស ជប៉ុន

(AAR ជប៉ុន) និងអ្នកអប់រំពិសេសនៅសាលាទន្សាយ។ មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងមនុស្សវ័យជំទង់ (CCAMH) នៅរាជធានីភ្នំពេញ បានបង្កើតជំនាញមួយកម្រិតទាក់ទងនឹងការវាយតម្លៃ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនក្នុងការគាំទ្រការលើកកម្ពស់ការយល់ដឹង។

ការយល់ដឹងអំពីជំងឺអូទីស្សឹម នៅក្នុងសាលារៀននិងតាមសេវាសុខាភិបាលជាច្រើន នៅមានភាពខ្សត់ខ្សោយនៅឡើយ។ ឪពុកម្តាយកុមារអូទីស្សឹម បានរាយការណ៍ថា ពួកគេមានការលំបាកក្នុងការទទួលបានរោគវិនិច្ឆ័យ ដោយហេតុថាគ្រូពេទ្យមួយចំនួននៅមានចំណេះដឹងនិងបទពិសោធន៍តិចតួចអំពីជំងឺអូទីស្សឹម។ នៅតាមមូលដ្ឋានសុខាភិបាលមួយចំនួន មានអ្នកជំនាញផ្នែកនេះ ប៉ុន្តែសេវាទាំងនេះច្រើនតែមានតម្លៃថ្លៃ ហើយឪពុកម្តាយដែលរស់នៅតាមខេត្តនានា ក្នុងប្រទេសមានការលំបាកក្នុងការមកទទួលសេវាទាំងនេះ។ គំរូពិការភាពតាមបែបវេជ្ជសាស្ត្រនៅតែបន្តកើតមាន ហើយត្រូវបានបន្តដោយសារតែបញ្ហាកង្វះការយល់ដឹងអំពីគំរូពិការភាពតាមបែបសង្គម ដែលត្រូវបានបង្ហាញជាអន្តរជាតិថា មានអត្ថប្រយោជន៍សម្រាប់អ្នកដែលមានអូទីស្សឹម។

សហគមន៍ និងមេសាសនានានា បង្ហាញពីការយល់ចិត្តចំពោះក្រុមគ្រួសារបុគ្គលដែលមានអូទីស្សឹម។ ប៉ុន្តែ អ្នកដឹកនាំស្ថាប័នសាសនាទទួលស្គាល់ថា ចំណេះដឹងរបស់ពួកគេអំពីអូទីស្សឹមនៅមានកម្រិត និងទទួលស្គាល់ពីតម្រូវការដើម្បីបង្កើនការយល់ដឹងរបស់ពួកគេផ្ទាល់ និងរបស់សហសេវិកដែលពួកគេធ្វើការជាមួយផងដែរ។

**របកគំហើញទី៣៖**

ការផ្តល់ការអប់រំដល់កុមារមានអូទីស្សឹមនៅមានកម្រិត។ មានសាលាឯកទេសមួយចំនួនតូចដែលធ្វើកិច្ចការនេះ ប៉ុន្តែគ្រឹះស្ថានអប់រំដែលមានចំណេះដឹងច្បាស់លាស់អំពីអូទីស្សឹមគឺនៅមានកម្រិត ហើយភាគច្រើនទំនងជាមានតែនៅក្នុងតំបន់ទីក្រុង។ នៅក្នុងសាលាពិសេសដែលផ្តល់ជូនជនមានពិការភាពផ្សេងៗ កុមារមានអូទីស្សឹមត្រូវបានគេកំណត់អត្តសញ្ញាណ ប៉ុន្តែការយល់ដឹងអំពីតម្រូវការរបស់ពួកគេ និងវិធីសាស្ត្រសមរម្យសម្រាប់ការបង្រៀនក៏នៅមានកម្រិតផងដែរ។ សមត្ថភាពក្នុងការផ្តល់ការអប់រំសមស្រប ត្រូវបានបង្អាក់បន្ថែមទៀត ដោយសារកង្វះធនធាន និងឧបករណ៍បង្រៀនសមស្រប។

រាជរដ្ឋាភិបាលកម្ពុជាគឺជាប្រទេសហត្ថលេខីនៃរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ហើយបានថ្លែងពីចេតនាធ្វើការឆ្ពោះទៅរកការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គោលដៅនេះរួមបញ្ចូលទាំងការប្តេជ្ញាចិត្តដើម្បីធានាថា កុមារី និងកុមារាទាំងអស់បញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាដោយឥតគិតថ្លៃប្រកបដោយគុណភាព និងសមធម៌ ដែលនាំទៅរកលទ្ធផលសិក្សាប្រកបដោយប្រសិទ្ធភាព។ គោលបំណងដើម្បីធានាឱ្យមានលទ្ធភាពទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់កម្រិតស្មើៗគ្នា សម្រាប់ជនងាយរងគ្រោះ រួមទាំងជនមានពិការភាពក៏ត្រូវបានបញ្ជាក់ផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ដោយមានការប្តេជ្ញាចិត្តចំពោះការអប់រំប្រកបដោយបរិយាបន្ន តាមរយៈគោលបំណងដើម្បី "ធានាបាននូវការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងការលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"។ ផែនការយុទ្ធសាស្ត្រនេះបានកំណត់នូវវឌ្ឍនភាពសំខាន់ៗ ក្នុងការដោះស្រាយការអភិវឌ្ឍវិស័យអប់រំនៅទូទាំងប្រទេស។ យុទ្ធសាស្ត្រនេះក៏ទទួលស្គាល់ផងដែរពីតម្រូវការក្នុងការធ្វើឱ្យប្រសើរឡើងនូវអត្រាចុះឈ្មោះចូលរៀន សម្រាប់កុមារដែលគ្រប់អាយុចូលរៀនដែលមិនទាន់បានចូលរៀននៅសាលាបឋមសិក្សា រួមទាំងកុមារមានពិការភាព និងកុមារដែលរស់នៅក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅឱ្យកុមារ និងយុវជនទាំងអស់ ទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត ដោយសមធម៌ និងបរិយាបន្ន ជាពិសេសកុមារមកពីគ្រួសារជួបការលំបាក និងយុវជនក្រៅសាលា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩ – ២០២៣ បង្ហាញពីកម្រិតយល់ដឹងដ៏សំខាន់អំពីបញ្ហាប្រឈមនានា ដែលជួបប្រទះក្នុងការអភិវឌ្ឍវិស័យអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន

សម្រាប់ទាំងអស់គ្នា ហើយគួរតែផ្តល់កម្លាំងរុញច្រានដើម្បីពង្រឹងការផ្តល់ដល់កុមារដែលមានពិការភាពទាំងអស់ រួមទាំងកុមារមានអូទីស្សឹមផងដែរ។ ការវិភាគស្ថានភាពស្តីពីការអប់រំកុមារមានពិការភាពនៅកម្ពុជា (២០១៨) ដែលធ្វើដោយ USAID បានកំណត់ឃើញថា កុមារមានពិការភាពចំនួន ៥២ % មិនត្រូវបានចុះឈ្មោះចូលរៀនឡើយ។ កុមារដែលមានពិការភាពធ្ងន់ធ្ងរ និងមានភាពស្មុគស្មាញ ត្រូវគេមើលឃើញថា ទំនងជាមិនសូវបានទទួលការអប់រំក្នុងប្រព័ន្ធ ដែលស្ថានភាពបែបនេះនៅតែបន្តកើតមានដល់សព្វថ្ងៃ។

ការផ្តល់ការអប់រំដល់កុមារមានអូទីស្សឹមគឺនៅតិចតួច។ ការពិភាក្សាជាមួយឪពុកម្តាយពួកគេ បង្ហាញថា កង្វះការសិក្សាសមរម្យ គឺជាប្រភពនៃការបង្អាក់ទឹកចិត្ត និងភាពតានតឹងផ្នែកអារម្មណ៍យ៉ាងខ្លាំងដល់គ្រួសារ។ ស្ថានភាពនេះមិនត្រឹមតែរារាំងឱកាសសម្រាប់កុមារដែលមានអូទីស្សឹមក្នុងការសិក្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ហិរញ្ញវត្ថុរបស់គ្រួសារនៅក្នុងស្ថានភាពដែលឪពុកម្តាយជាអ្នកថែទាំ មិនអាចទៅធ្វើការងារបាន។

ការយល់ឃើញរបស់ឪពុកម្តាយកុមារមានអូទីស្សឹម គឺថាសាលារៀនរដ្ឋ និងសាលារៀនឯកជនជាច្រើនមិនចង់ចុះឈ្មោះកុមារមានអូទីស្សឹមទេ។ ទស្សនៈនេះត្រូវបានបញ្ជាក់ដោយអ្នកផ្តល់សេវាមួយចំនួន រួមទាំងអ្នកដឹកនាំសាលា និងតំណាងមកពីរាជរដ្ឋាភិបាល និងពីទីភ្នាក់ងារមិនមែនរដ្ឋាភិបាលដែលបង្ហាញថា សាលារៀនមានបំពាក់សម្ភារមិនល្អ និងមិនមានការរៀបចំដើម្បីដោះស្រាយតម្រូវការរបស់កុមារទាំងនេះ។ ឪពុកម្តាយពួកគេជឿថា សាលារៀនព្រួយបារម្ភអំពីលទ្ធភាពគ្រប់គ្រងកូនរបស់ពួកគេដែលមានអូទីស្សឹម។ ជាពិសេស ពួកគេព្រួយបារម្ភអំពីអាកប្បកិរិយា និងលទ្ធភាពនៃការរំខាននៅក្នុងថ្នាក់រៀន។ ឧទាហរណ៍ ឪពុកម្តាយមួយក្រុមបានថ្លែងថា "នៅពេលដែលពួកគេឃើញកូនរបស់យើងឆ្លេឆ្លានៅមិនស្ងៀម ពួកគេបាននិយាយថា ថ្នាក់ពេញហើយ ហើយប្រាប់យើងឱ្យមកថ្ងៃផ្សេងទៀត។ ហាក់ដូចជាពួកគេមិនចង់ទទួលយកកូនរបស់យើង ប៉ុន្តែពួកគេមិនអាចប្រាប់យើងដោយត្រង់ៗនោះទេ"។ "ឪពុកម្តាយម្នាក់ទៀតបានអះអាងថា "សាលារៀនខ្លះពួកគេប្រាប់ខ្ញុំដោយត្រង់ៗថា កុមារប្រភេទនេះគេនឹងមិនទទួលយកនោះទេ តាមគោលការណ៍សាលា។ ពួកគេថា មានការលំបាក ពីព្រោះប្រសិនបើមានរឿងអ្វីកើតឡើង ពួកគេពិបាកទទួលខុសត្រូវ"។ សាលាពិសេសឯកជនមួយដែលផ្តល់ការអប់រំដល់កុមារមានអូទីស្សឹម បានបញ្ជាក់ថា លទ្ធភាពក្នុងការចូលរៀនសាលាផ្សេងទៀតសម្រាប់កុមារបែបនេះជាការពិបាក ហើយក្នុងនាមជាអ្នកផ្តល់សេវាឯកទេស ទីកន្លែងរបស់ពួកគេមិនមានលទ្ធភាពបំពេញតម្រូវការទាំងនេះគ្រប់គ្រាន់នោះទេ។

កន្លែងដែលមានលទ្ធភាពទទួលបាន ការអប់រំបែបនេះច្រើនតែទទួលបាននៅក្នុងសាលាពិសេស ឬតាមរយៈអង្គការមិនមែនរដ្ឋាភិបាល។ អ្នកអប់រំពិសេសម្នាក់មកពីខេត្តព្រះសីហនុបានសង្កត់ធ្ងន់លើភាពចាំបាច់សម្រាប់សាលារៀន ក្នុងការផ្តល់នូវកម្មវិធីសិក្សាដែលឆ្លើយតបបានច្រើននូវតម្រូវការរបស់កុមារមានអូទីស្សឹម មិនត្រឹមតែតម្រូវការនៃការសិក្សាតែមួយមុខរបស់កុមារនោះទេ។ "ដោយសារយើងមានសាលា យើងអនុវត្តតាមកម្មវិធីសិក្សារបស់រដ្ឋក្នុងការបង្រៀន ជាពិសេសកម្មវិធីថ្នាក់មត្តេយ្យ។ មិនមែនកុមារទាំងអស់ក្នុងថ្នាក់សុទ្ធតែមានអូទីស្សឹមនោះទេ។ យើងផ្តោតលើសកម្មភាពសម្រាប់ការរស់នៅប្រចាំថ្ងៃ។ កុមារទាំងនេះមានការលំបាកក្នុងផ្នែកទាំងនេះ ដូច្នេះយើងរួមបញ្ចូលសកម្មភាពមួយចំនួនលើការប្រើប្រាស់បង្គន់ ការងូតទឹក និងអនាម័យខ្លួនឯង។ កុមារធំជាងគេរៀនជួយធ្វើការងារផ្ទះ។ យើងលើកទឹកចិត្តអ្នកថែទាំឱ្យចូលរួមជាមួយពួកគេ។ យើងរួមបញ្ចូលអក្ខរកម្ម និងគណិតវិទ្យាមួយចំនួន។ កុមារដែលមានអូទីស្សឹមរៀនបានកាន់តែល្អតាមវិធីនេះ"។ ប៉ុន្តែ សាលារៀនមួយចំនួនតូចបានទទួលការបណ្តុះបណ្តាលចាំបាច់ ដើម្បីកែប្រែកម្មវិធីសិក្សា ក្នុងការដោះស្រាយតម្រូវការរបស់សិស្សដែលមានលក្ខណៈចម្រុះ។ នៅក្នុងសាលាទាំងនោះដែលមានជំនាញខ្លះក្នុងការអប់រំកុមារមានអូទីស្សឹម ពួកគេមានការសាទរ ការប្តេជ្ញាចិត្តទាក់ទងនឹងការថែរក្សា និងកែលម្អសេវាដែលពួកគេផ្តល់។

សាលារៀនឯកជនដែលផ្តល់ជូនកុមារមួយចំនួនមានអូទីស្សឹមត្រូវតែគិតថ្លៃសេវាថេរ។ ករណីទាំងនេះគឺជាការរារាំងចំពោះគ្រួសារជាច្រើន លើកលែងតែគ្រួសារដែលមានលទ្ធភាពតែប៉ុណ្ណោះ។ គ្រូពេទ្យម្នាក់ដែលមានបទពិសោធន៍យូរឆ្នាំ នៃមន្ទីរពេទ្យកុមារជាតិ បានមានប្រសាសន៍ថា "ថ្លៃសាលាសម្រាប់កុមារដែលមានអូទីស្សឹមគឺខ្ពស់ណាស់បើធៀបនឹងកុមារមិនមានអូទីស្សឹម។ ថ្លៃសាលាអាចមានតម្លៃ ១,000ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ប៉ុន្តែសម្រាប់កុមារដែលមានអូទីស្សឹម ថ្លៃសាលាអាចមានតម្លៃ ១,៦០០ដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ ដូច្នេះ ឪពុកម្តាយតិចតួចណាស់ដែលអាចមានលទ្ធភាពបង់ថ្លៃសាលានោះ"។ ចំណុចនេះត្រូវបានបញ្ជាក់ដោយឪពុកម្តាយជាច្រើន ដែលភាគច្រើននៃពួកគេបានទទួលស្គាល់ថា ការរៀននៅសាលានោះវាជាការចាំបាច់ ក៏ប៉ុន្តែពួកគាត់យល់ថា ការចំណាយទាំងនេះវាមិនអាចទៅរួច ក្នុងការរក្សាបាននូវតម្រូវការចាំបាច់ផ្សេងទៀត។ ស្ថានភាពនេះត្រូវបានបញ្ជាក់ដោយវេជ្ជបណ្ឌិតនៃមន្ទីរពេទ្យរដ្ឋ។ ឪពុកម្តាយម្នាក់បានបញ្ជាក់ថា "ប្រសិនបើជាសាលារៀនឯកជន ពួកគេសប្បាយចិត្តណាស់

នៅពេលដែលពួកគេឃើញឪពុកម្តាយនាំកូនៗរបស់ពួកគេដែលមានអូទីស្សឹមមករៀន។ ពួកគេនឹងគិតថ្លៃ ៣០ដុល្លារក្នុងមួយម៉ោង។ តាមពិតទៅ តម្លៃនេះគឺថ្លៃណាស់ ប៉ុន្តែដើម្បីជាអត្ថប្រយោជន៍ដល់កូនៗ ឪពុកម្តាយត្រូវតែទទួលយកតម្លៃនេះ។ ចំពោះខ្ញុំ ខ្ញុំមិនមានលទ្ធភាពបង់ថ្លៃសាលាក្នុងតម្លៃនេះទេ។ បើខ្ញុំអាចមានលទ្ធភាពបង់ ខ្ញុំក៏នឹងឱ្យកូនទៅរៀនដែរ"។ ឪពុកម្តាយម្នាក់ទៀតបានបញ្ជាក់ពីចំណុចនេះម្តងទៀតថា "សម្រាប់រយៈពេលបីខែ គាត់បានគិតថ្លៃពីខ្ញុំចំនួន ១០០ដុល្លារ។ ប្រសិនបើយើងមានស្ថានភាពសេដ្ឋកិច្ចកម្រិតមធ្យម វាមិនជាបញ្ហានោះទេ។ ប៉ុន្តែនៅពេលដែលស្ថានភាពសេដ្ឋកិច្ច ធ្លាក់ចុះ និងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩ គ្រួសារដែលមានជីវភាពក្រីក្រ នឹងមានការពិបាកក្នុងការបង់ថ្លៃសាលាក្នុងតម្លៃនេះ។ អូទីស្សឹមមិនតែងតែកើតឡើងចំពោះគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចល្អនោះទេ សូម្បីតែគ្រួសារអ្នកប្រមូលសំរាម ក៏មានកូនមានអូទីស្សឹមដែរ។ ខ្ញុំចង់ឱ្យសាលារៀនផ្សេងទៀតមានសេវាស្រដៀងគ្នានេះ"។

មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងសេវាដែលមាននៅក្នុងទីក្រុងនិងជនបទ។ ឪពុកម្តាយដែលរស់នៅក្នុងទីក្រុងភ្នំពេញទំនងជាទទួលបានសេវាព្យាបាល និងអប់រំជាងអ្នកដែលរស់នៅតាមខេត្ត។ ប្រធានសហគមន៍ពិសេសដែលផ្តល់សេវាសម្រាប់ជនមានពិការភាព បានបញ្ជាក់ថា បញ្ហានេះត្រូវបានទទួលស្គាល់នៅថ្នាក់ជាតិ។ "ក្រសួងអប់រំគ្រោងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសាលារៀនបន្ថែមទៀតនៅតាមបណ្តាខេត្ត ប៉ុន្តែនៅខ្វះសាលារៀននៅតាមស្រុក និងខេត្តនានា"។ ចំណុចនេះត្រូវបានបញ្ជាក់ដោយតំណាងមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ដែលបានទទួលស្គាល់ថា មានតម្រូវការក្នុងការលើកកម្ពស់ឱកាសទទួលបានការសិក្សានៅតាមបណ្តាខេត្តជាច្រើន។ ឪពុកម្តាយមកពីសហគមន៍ជនបទបានសម្តែងការខកចិត្តចំពោះកង្វះខាតសម្ភារសិក្សាសម្រាប់ កូនៗរបស់ពួកគេ ដែលពួកគេជឿជាក់ថា បញ្ហានេះនឹងរារាំងដល់ឱកាសការងារនិងការរស់នៅដោយឯករាជ្យរបស់កូនពួកគេនាពេលអនាគត។

ឧបសគ្គចម្បងក្នុងការកែលម្អការផ្តល់ការអប់រំដល់កុមារដែលមានអូទីស្សឹមគឺ កង្វះការបណ្តុះបណ្តាលគ្រូឧទ្ទេសដំបូង និងការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ផ្តល់ជូនគ្រូបង្រៀនទាក់ទងនឹងតម្រូវការអប់រំពិសេស។ ក្នុងនាមជាវេជ្ជបណ្ឌិតរបស់រដ្ឋ គាត់បានមានប្រសាសន៍ថា "កុមារជាច្រើនមិនអាចទៅសាលារៀនបានទេពីព្រោះយើងមិនទាន់មានអ្នកអប់រំពិសេស"។ នេះជាបញ្ហាសំខាន់មួយដែលត្រូវបានពិចារណាក្នុងរបកគំហើញទី៤ខាងក្រោម។

**របកគំហើញទី៤៖**

តម្រូវការបណ្តុះបណ្តាលគ្រូឯកទេស ដើម្បីផ្តល់នូវចំណេះដឹង ជំនាញ និងការយល់ដឹងបន្ថែមទៀតអំពីផ្នែកអូទីស្សឹមគឺជាកិច្ចការជាក់ស្តែង។ អ្នកផ្តល់បទសម្ភាសន៍នៃការសិក្សានេះ បានរាយការណ៍អំពីការយល់ដឹងអំពីអូទីស្សឹមក្នុងចំណោមអ្នកបង្រៀនដែលមានវិជ្ជាជីវៈ នៅមានកម្រិតនៅឡើយ ដែលបញ្ហានេះនាំឱ្យមានការស្ទាក់ស្ទើរក្នុងការបង្រៀនកុមារ ឬចុះឈ្មោះឱ្យពួកគេបានចូលរៀន។

ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៩-២០២៣ បានទទួលស្គាល់ពីតម្រូវការក្នុងការកំណត់អាទិភាព និងកំណែទម្រង់កម្មវិធីបណ្តុះបណ្តាលគ្រូឧទ្ទេស និងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈនៅកម្ពុជា។ ឯកសារនេះបានបញ្ជាក់ពីការប្តេជ្ញាចិត្តដើម្បី "ធ្វើទំនើបកម្មស្តង់ដារនៃកម្មវិធីបណ្តុះបណ្តាលគ្រូឧទ្ទេស ក្នុងការបំពេញតម្រូវការក្នុងប្រទេស" (ផ្នែកទី ៤.៤)។ កិច្ចការនេះនឹងមានសារសំខាន់ ខណៈដែលវឌ្ឍនភាពត្រូវបានបង្កើតឡើងឆ្ពោះទៅរកការសម្រេចបាននូវការប្តេជ្ញាចិត្តថា"សម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ (២០១៩-២០២៣) និងរហូតដល់ឆ្នាំ២០៣០ និង២០៥០ ក្រសួងអប់រំ ប្តេជ្ញាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ការអប់រំប្រកបដោយចីរភាពដំណាក់កាលទី៤ ដោយផ្អែកលើគោលការណ៍អប់រំប្រកបដោយ បរិយាបន្ន សមធម៌ និងគុណភាព និងការលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា" (បុព្វកថាចំពោះផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៩-២០២៣)។

ការវិភាគស្ថានភាពរបស់ USAID លើការអប់រំកុមារមាន

ពិការភាពនៅកម្ពុជា (ឆ្នាំ២០១៨) បានរាយការណ៍ពីការអភិវឌ្ឍវគ្គបណ្តុះបណ្តាលថ្មីៗសម្រាប់គ្រូបង្រៀនដែលធ្វើការជាមួយកុមារដែលមានការលំបាកផ្នែកញ្ញាណដឹង។ លើសពីនេះ សៀវភៅណែនាំដែលលើកកម្ពស់ការអនុវត្តប្រកបដោយបរិយាបន្នត្រូវបានបង្កើតឡើងដោយសាលារៀនទន្សាយ។ ទោះជាយ៉ាងណាក៏ដោយ កង្វះគ្រូបង្រៀនដែលបានទទួលបានការបណ្តុះបណ្តាលផ្នែកអូទីស្សឹម និងការលើកកម្ពស់ការអប់រំប្រកបដោយបរិយាបន្នគឺជាឧបសគ្គចម្បងក្នុងការផ្តល់ការអប់រំសម្រាប់ក្រុមប្រជាជននេះ។ គ្រូបង្រៀនតិចតួចប៉ុណ្ណោះដែលមានឱកាសអភិវឌ្ឍវិជ្ជាជីវៈទាក់ទងនឹងអូទីស្សឹម ហើយមិនមានលក្ខខណ្ឌតម្រូវដើម្បីដោះស្រាយបញ្ហានេះនៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូឧទ្ទេសនោះទេ។ ខណៈពេលដែលមានភស្តុតាងមួយចំនួននៃកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការបង្រៀនខុសៗគ្នា និងដើម្បីលើកកម្ពស់ការយល់ដឹងអំពីពិការភាព ដូចដែលបានឃើញឧទាហរណ៍នៅក្នុងគម្រោងបណ្តុះបណ្តាលគ្រូឧទ្ទេសនៅកម្ពុជា [CTTP] ដែលស្ថិតនៅក្នុងវិទ្យាស្ថានគរុកោសល្យកម្រិតបឋមខេត្ត កណ្តាល ពុំមានការផ្តោតជាក់លាក់លើអូទីស្សឹមឡើយ។ តំណាងមកពីផ្នែករដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល បានរាយការណ៍ថា នេះជាឧបសគ្គធំមួយដែលកំពុងប្រឈមមុខសម្រាប់គ្រួសារដែលមានកូនមានអូទីស្សឹម។ គ្រូពេទ្យម្នាក់ដែលមានបទពិសោធន៍យូរឆ្នាំនៃមន្ទីរពេទ្យកុមារជាតិបានលើកឡើងថា "សាលារៀនអាចផ្តល់សេវា ប៉ុន្តែភាគច្រើនមិនមានការបណ្តុះបណ្តាលត្រឹមត្រូវអំពីអូទីស្សឹម ឬតម្រូវការពិសេសនោះទេ។ យើងត្រូវធ្វើការជាមួយគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សា"។ តំណាងមកក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជាក់អំពីជំនឿនេះ នៅពេលលើកឡើងថា "ក្នុងកម្រិតបឋមសិក្សា និងមធ្យមសិក្សា គេមិនទាន់យល់ស៊ីជម្រៅអំពីអូទីស្សឹមនៅឡើយ ដោយសារគ្រូបង្រៀនមិនយល់ច្បាស់ និងមិនទាន់បានទទួលការបណ្តុះបណ្តាល ឬបង្កើនការយល់ដឹងនៅឡើយ។ ដូច្នេះការផ្តល់សេវាមិនទាន់ល្អនៅឡើយទ"។

ចំពោះការលើកឡើងរបស់អ្នកឯកទេស ក្នុងការផ្តល់ការអប់រំដល់កុមារមានពិការភាព មានគ្រូបង្រៀនមួយចំនួនដែលមានបទពិសោធន៍ក្នុងការធ្វើការជាមួយកុមារមានអូទីស្សឹម ដែលមួយចំនួនក្នុងចំណោមពួកគេបានទទួលការបណ្តុះបណ្តាលជំនាញ។ ក្នុងករណីខ្លះ អ្នកជំនាញទាំងនេះបានសហការជាមួយវិទ្យាស្ថានជាតិអប់រំពិសេសលើការបង្កើត និងការផ្តល់វគ្គបណ្តុះបណ្តាល។ អង្គការធ្វើឱ្យប្រសើរឡើងដល់សេវាព្យាបាលការប្រាស្រ័យទាក់ទង និងលេបអាហារនៅកម្ពុជា (OIC) បានសហការជាមួយក្រសួងអប់រំ ដើម្បីបើកវគ្គបណ្តុះបណ្តាលស្តីពីការព្យាបាលដោយការនិយាយជាមូលដ្ឋានដល់គ្រូបង្រៀននៅរាជធានីភ្នំពេញ និងខេត្តមួយចំនួន (កណ្តាល កំពត កំពង់ស្ពឺ)។

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន រួមទាំងអង្គការសមាគមសម្រាប់ជំនួយនិងសង្គ្រោះនៃប្រទេសជប៉ុន (AAR Japan) បានអនុវត្តវគ្គបណ្តុះបណ្តាលខ្លីៗសម្រាប់អ្នកជំនាញមួយចំនួនដែលចំណេះដឹងពួកគេនៅមានកម្រិត។ ទោះយ៉ាងណាក៏ដោយ មានគ្រូបង្រៀនតិចតួចប៉ុណ្ណោះដែលបានទទួលវគ្គបណ្តុះបណ្តាលនេះ។ វិទ្យាស្ថានជាតិអប់រំពិសេសក៏បានអនុវត្តវគ្គបណ្តុះបណ្តាលខ្លីៗមួយចំនួនអំពីអូទីស្សឹមផងដែរ ប៉ុន្តែស្រដៀងគ្នានេះដែរ មានតែគ្រូបង្រៀនតិចតួចប៉ុណ្ណោះដែលទទួលបានការបណ្តុះបណ្តាលទាំងនោះ។ មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារដែលមានទីតាំងនៅមន្ទីរពេទ្យបង្អែកជ័យជំនះ ក៏បានផ្តល់វគ្គបណ្តុះបណ្តាលមួយចំនួនដល់គ្រូបង្រៀន អ្នកជំនាញសុខភាព និងឪពុកម្តាយផងដែរ។

ឪពុកម្តាយរបស់កុមារដែលមានអូទីស្សឹមបានរាយការណ៍ថា កង្វះខាតគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលជាញឹកញាប់ត្រូវបានលើកឡើងថា វាជាហេតុផលសម្រាប់សាលារៀនបដិសេធមិនចុះឈ្មោះកូនរបស់ពួកគេឱ្យចូលរៀន។ ក្នុងអំឡុងពេលកិច្ចពិភាក្សាជាក្រុមជាមួយឪពុកម្តាយ ពួកគេបានប្រាប់អ្នកស្រាវជ្រាវថា "ភាគច្រើនសាលារៀនបដិសេធមិនទទួលយកពួកគេ (កូនរបស់យើង) ពីព្រោះពួកគេពិបាកបង្រៀន ឬពិបាកគ្រប់គ្រងបញ្ហាអាកប្បកិរិយារបស់កុមារ ហើយគ្រូបង្រៀនខ្វះជំនាញក្នុងការគ្រប់គ្រងកុមារដែលមានអូទីស្សឹម"។ នេះជាសារមួយដែលក្រុមឪពុកម្តាយតែងតែទទួលជាប្រចាំនៅទូទាំងប្រទេស "វាហាក់ដូចជាគ្រូបង្រៀនមិនទទួលយកកុមារប្រភេទនេះនៅឡើយ។ ពួកគេមិនចេះបង្រៀន ដូច្នេះ ពួកគេមិនអាចបង្រៀនកូនរបស់យើងបាន (កុមារដែលមានអូទីស្សឹម)"។

កង្វះខាតការបណ្តុះបណ្តាលបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ទំនុកចិត្តរបស់ឪពុកម្តាយចំពោះសមត្ថភាពរបស់សាលារៀនក្នុងការផ្តល់ការអប់រំគ្រប់គ្រាន់សម្រាប់កូនៗរបស់ពួកគេ និងស្រដៀងគ្នានេះដែរបានរារាំងសាលារៀនចំពោះសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយតម្រូវការរបស់សិស្សដែលមានអូទីស្សឹម។

### របបគំហើញទី៥៖

ការទទួលបានការគាំទ្រផ្នែកវេជ្ជសាស្ត្រ និងស្តារលទ្ធភាពពលកម្ម គឺមានការប្រែប្រួល ហើយទំនងជាអាចរកបានតែនៅក្នុងតំបន់ទីក្រុងប៉ុណ្ណោះ។ សូម្បីតែនៅក្នុងតំបន់ទីក្រុងក៏ដោយ សេវាឯកទេសដូចជា ការព្យាបាល ដោយការនិយាយ ( speech therapy ) និងការព្យាបាលផ្នែកមុខងារ ( occupational therapy ) ក៏មិនងាយរកបានដែរ។ ស្ថានភាពនេះត្រូវបានបង្អាក់បន្ថែមទៀត ខណៈដែលបច្ចុប្បន្ននេះ ការបណ្តុះបណ្តាលក្នុងវិស័យទាំងនេះមិនទាន់មាននៅក្នុងប្រទេសនៅ ឡើយ។ ឱកាសទទួលបានមួយចំនួនត្រូវបានរឹតបន្តឹង ដោយសារតែត្រូវធ្វើដំណើរទៅរកកន្លែងដែលមានជំនាញ។ ប៉ុន្តែ មានគំរូល្អៗមួយចំនួនដែលអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផ្តល់ការគាំទ្រផ្នែកមធ្យោបាយធ្វើដំណើរដើម្បីឱ្យកុមារនិង គ្រួសារពួកគេអាចទទួលបានការគាំទ្រទាំងនោះ។

ឪពុកម្តាយនិងអ្នកជំនាញបានរាយការណ៍ពីការលំបាកក្នុងការទទួលបានស្តារលទ្ធភាពពលកម្មនិងសេវាសុខភាពសម្រាប់បុគ្គលដែលមានអូទីស្សឹម។ ក្នុងករណីមួយចំនួនដែលមានអ្នកព្យាបាល ពួកគេខ្វះការយល់ដឹងអំពីលក្ខណៈនៃអូទីស្សឹម។ ឪពុកម្តាយដែលមានកូនមានអូទីស្សឹម បានរាយការណ៍ពីការលំបាករបស់ពួកគេក្នុងការកំណត់ទីតាំងសេវាគាំទ្រគ្រប់គ្រាន់ដោយបញ្ជាក់ថា "អ្នកស្វែងរកសេវាដែលមានសម្រាប់កូនរបស់អ្នក ហើយមានតែ CCAMH ប៉ុណ្ណោះដែលអាចផ្តល់សេវាល្អៗ"។ អ្នកដែលរស់នៅក្នុងតំបន់ជនបទបានបញ្ជាក់ជាថ្មីថាពួកគេជួបប្រទះការលំបាកយ៉ាងធ្ងន់ធ្ងរ ហើយថាមានតែនៅក្នុងទីក្រុងធំៗប៉ុណ្ណោះដែលទទួលបានសេវានោះយ៉ាងងាយស្រួល។ ទោះយ៉ាងណាក៏ដោយ មានឧទាហរណ៍មួយចំនួនអំពីអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការគាំទ្រជាមួយនឹងការដឹកជញ្ជូនដែលអនុញ្ញាតឱ្យគ្រួសារអាចទទួលបានសេវាមួយចំនួន។

ការទទួលបានការព្យាបាលដោយចលនានៅមានកម្រិត។ ខណៈពេលដែលសាលារៀនពិសេសមួយបានផ្តល់ឧទាហរណ៍អំពីវិធីដែលពួកគេបានព្យាយាមជួយដល់ឪពុកម្តាយឱ្យយល់ដឹងពីតម្រូវការរបស់កូនៗពួកគេ និងរបៀបដែលឪពុកម្តាយអាចធ្វើបាន បានរាយការណ៍ថា "ចំពោះកុមារដែលមានពិការចលកខួរក្បាល យើងផ្តល់ការព្យាបាលដោយចលនាតាមរយៈការសុំឱ្យឪពុកម្តាយបង្ហាញពីសកម្មភាពដែលពួកគេបានធ្វើជាមួយកូន ហើយប្រសិនបើពួកគេមិនអាចបង្ហាញយើងបានទេ យើងនឹងបង្ហាញពីបច្ចេកទេសព្យាបាលដោយចលនាដល់ពួកគេ"។ ស្រដៀងគ្នានេះដែរ អ្នកគ្រប់គ្រងអង្គការកម្មវិធីសេវាអភិវឌ្ឍន៍ជនពិការ (DDSP) នៅខេត្តពោធិ៍សាត់ បានលើកឡើងថា ពួកគេកំពុងបោះជំហានទៅមុខក្នុងការផ្តល់ជំនួយដល់ក្រុមគ្រួសារទាំងឡាយ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះឯកទេសផ្សេងទៀត បានលើកឡើងថា លទ្ធភាពទទួលបានសេវាសមស្រប និងការផ្តល់ជំនួយចាំបាច់ កំពុងមានបញ្ហាប្រឈម។ ទីប្រឹក្សាបច្ចេកទេសនៃអង្គការកុមារក្នុងគ្រួសារ (CIF) នៅរាជធានីភ្នំពេញនិងខេត្តស្វាយរៀង បានបញ្ជាក់ពីការលំបាកក្នុងការផ្តល់សេវាគ្រប់គ្រាន់ដោយរាយការណ៍ថា"គ្រូពេទ្យព្យាបាលដោយចលនាកម្ពុជា ឬអ្នកដែលបានទទួលការបណ្តុះបណ្តាលការងារនេះនៅប្រទេសកម្ពុជា នៅមានតិចតួច"។

ការព្យាបាលដោយការនិយាយគឺស្រដៀងគ្នាកំពុងត្រូវបានអភិវឌ្ឍន៍ ទោះបីជាគំរូមួយសម្រាប់ការផ្តល់ត្រូវបានបង្ហាញឱ្យឃើញនៅក្នុងការងាររបស់អង្គការធ្វើឱ្យប្រសើរឡើងដល់សេវាព្យាបាល ការប្រាស្រ័យទាក់ទង និងលេបអាហារនៅកម្ពុជា (OIC) ដែលនាយកប្រតិបត្តិរបស់ខ្លួនបានបង្ហាញនៅក្នុងចក្ខុវិស័យមួយគឺ "ផ្តោតលើសកម្មភាពដើម្បីបង្កើតវគ្គសិក្សាអំពីការព្យាបាលដោយការនិយាយ គឺត្រូវឱ្យសិស្សសិក្សាអំពីការព្យាបាលដោយការនិយាយ ដើម្បីក្លាយជាអ្នកព្យាបាលដោយការនិយាយនៅក្នុងប្រទេសកម្ពុជា។ អង្គការនេះបានបង្កើតធនធាន និងសហការជាមួយគិលានុបដ្ឋាយិកា និងគ្រូពេទ្យព្យាបាលដោយចលនា ដែលធ្វើការនៅមន្ទីរពេទ្យកុមារជាតិ (NPH) បានធ្វើការសិក្សាពីតម្រូវការនៃប្រភេទសេវានេះ។ ពួកគេមានផែនការផ្តល់សេវាព្យាបាលដោយការនិយាយនៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ស្ពឺ ដែលអាចជាវិធីសាស្ត្រដ៏មានប្រយោជន៍ក្នុងការកសាងសមត្ថភាព។ ឥទ្ធិពលវិជ្ជមាននៃការងាររបស់អង្គការនេះត្រូវបានទទួលស្គាល់ដោយទីប្រឹក្សាបច្ចេកទេសសម្រាប់អង្គការកុមារក្នុងគ្រួសារ (CIF)។

បញ្ហានៃការបណ្តុះបណ្តាលមិនគ្រប់គ្រាន់សម្រាប់អ្នកឯកទេសផ្នែកស្តារលទ្ធភាពពលកម្ម ត្រូវបានគូសបញ្ជាក់ពីប្រភពជាច្រើន។ អ្នកគ្រប់គ្រងកម្មវិធីមកពីអង្គការករុណាបាត់ដំបង (Karuna Battambong) បានប្រាប់យើងថា បុគ្គលិក "បានទទួលការបណ្តុះបណ្តាលមួយចំនួនពីអង្គការមិនមែនរដ្ឋា

ភិបាលដៃគូមួយចំនួន និងពី CCAMH និងអ្នកស្ម័គ្រចិត្តមកពីបរទេស" ប៉ុន្តែបានសង្កត់ធ្ងន់លើតម្រូវការសម្រាប់កម្មវិធីបណ្តុះបណ្តាលដ៏ទូលំទូលាយនៅក្នុងប្រទេស។ អ្នកគ្រប់គ្រងកម្មវិធីមកពីអង្គការកុមារណាបាត់ដំបង បានសង្កត់ធ្ងន់ថា ការបណ្តុះបណ្តាលផ្នែកព្យាបាលនៅមានកម្រិតដែលអាចទទួលបានពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន និងពេលខ្លះមកពីអ្នកស្ម័គ្រចិត្តមកពីបរទេស ដែលជាស្ថានភាពមួយដែលត្រូវបានគេកំណត់ស្រដៀងគ្នានៅក្នុងការសិក្សាដែលធ្វើឡើងដោយ Salter និង Yeoh នៅក្នុងឆ្នាំ២០១៧។

ទាក់ទងនឹងការលំបាកក្នុងការទទួលបានសេវា គឺជាការផ្តល់មិនគ្រប់គ្រាន់នៃនីតិវិធីវាយតម្លៃសមស្រប។ ជាទូទៅឧបករណ៍វាយតម្លៃដើម្បីកំណត់អំពីអូទីស្សឹម គឺជាឧបករណ៍ស្តង់ដាររួមមួយដែលត្រូវបានកំណត់ មិនថាធ្វើនៅសហរដ្ឋអាមេរិក ឬអឺរ៉ុប ឬក្រុមប្រជាជនដែលមានវប្បធម៌ផ្សេងគ្នានោះទេ។ ការវាយតម្លៃមួយចំនួនច្រើនជាលក្ខណៈមិនផ្លូវការ ហើយមិនបានប្រើប្រាស់ឧបករណ៍វាយតម្លៃយកមកផ្ទៀងផ្ទាត់ឡើយ។ កិច្ចការនេះត្រូវបានបញ្ជាក់ដោយតំណាងពីមន្ទីរពេទ្យកុមារជាតិដែលបានថ្លែងថា "តាមពិតទៅ យើងមិនមានការវាយតម្លៃជាផ្លូវការចំពោះអតិថិជនទេ។ ភាគច្រើនយើងធ្វើកិច្ចសម្ភាសន៍ក្រៅផ្លូវការជាមួយឪពុកម្តាយ"។ក្នុងខណៈពេលដែលការអនុវត្តនេះធ្វើដោយក្រុមវិជ្ជាជីវៈ និងមានការប្តេជ្ញាចិត្តពីសំណាក់គ្រូពេទ្យទាំងនោះការវាយតម្លៃមិនជាផ្លូវការមិនមានជាបញ្ហាមន្ទិលសង្ស័យនោះទេ។ ការងាររបស់ពួកគេអាចនឹងត្រូវបានពង្រឹងយ៉ាងខ្លាំងនៅពេលទទួលបានឧបករណ៍វាយតម្លៃសមស្របនិងមានសុពលភាពក្នុងប្រទេសកម្ពុជា និងទទួលបានការបណ្តុះបណ្តាលក្នុងការប្រើប្រាស់ឧបករណ៍វាយតម្លៃសមស្របសម្រាប់ការកំណត់អត្តសញ្ញាណ។

**របបគំហើញទី៦៖**

ភាពក្រីក្រគឺជាឧបសគ្គដ៏ចម្បងមួយក្នុងការឆ្ពោះទៅរកភាពរីកចម្រើនដើម្បីផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ដល់ជនមានអូទីស្សឹម និងគ្រួសាររបស់ពួកគេ។ សេវាទាំងនេះទំនងជាបានទៅដល់អ្នកដែលមានប្រាក់ចំណូលទៀងទាត់។

សម្រាប់គ្រួសារដែលរស់នៅក្នុងភាពក្រីក្រ ជារឿយៗមានបញ្ហាប្រឈមចម្បងក្នុងការទទួលបានសេវាសម្រាប់អ្នកដែលមានអូទីស្សឹម។ បញ្ហាប្រឈមជាក់លាក់មួយដែលគ្រួសាររបស់កុមារមានអូទីស្សឹមប្រឈមគឺទាក់ទងនឹងឱកាសរបស់ពួកគេនៅមានកម្រិតក្នុងការធានាបានប្រាក់ចំណូលទៀងទាត់។ ភាពចាំបាច់ក្នុងការផ្តល់ការថែទាំកុមារឱ្យបានជាប់លាប់ ធ្វើឱ្យមានតម្រូវការយ៉ាងច្រើនចំពោះហិរញ្ញវត្ថុគ្រួសារ បញ្ហានេះហើយត្រូវបានសង្កត់ធ្ងន់ដោយក្រុមឪពុកម្តាយទាំងពីរ ដែលពួកគេបានរាយការណ៍ថា "គ្រួសារមិនមានពេលវេលាដើម្បីថែទាំកូនៗរបស់ពួកគេផងនិងធ្វើការផង ហើយបញ្ហានេះបណ្តាលឱ្យមានកង្វះខាតប្រាក់ចំណូល"។ អង្គការដែលមានវិជ្ជាជីវៈទាក់ទងនឹងកិច្ចការនេះ និងស្ថាប័នរដ្ឋមួយចំនួន រួមទាំងតំណាងវិទ្យាស្ថានជាតិអប់រំពិសេស បានលើកឡើងថា "មានផលប៉ះពាល់លើសេដ្ឋកិច្ចគ្រួសារ ដោយសារសមាជិកក្នុងគ្រួសារខ្វះពេលវេលាក្នុងការរកប្រាក់ចំណូល ដោយត្រូវចំណាយពេលមើលថែទាំកូន។" កង្វះពេលវេលា ក៏ដូចជាកង្វះប្រាក់ចំណូល គឺជាលក្ខណៈនៃគ្រួសារដែលគាំទ្រកុមារដែលមានអូទីស្សឹម ដែលត្រូវបានអង្កេតនៅក្នុងការសិក្សានេះ។ ស្ថានភាពនេះត្រូវបានគូសបញ្ជាក់នៅក្នុងការស្រាវជ្រាវកន្លងមកដែលធ្វើឡើងដោយ Cordier (ឆ្នាំ២០១៤) ដែលយល់ឃើញថាឪពុកម្តាយ និងជាពិសេសស្ត្រីដែលកំពុងថែទាំកុមារដែលមានពិការភាពនៅក្នុងប្រទេសកម្ពុជា ទំនងជារស់នៅក្នុងភាពក្រីក្រ។

ប្រធានមជ្ឈមណ្ឌលផ្តល់សេវាឯកទេស និងការគាំទ្រដល់គ្រួសារ បានសម្តែងការព្រួយបារម្ភថាកុមារអូទីស្សឹមមួយចំនួនប្រឈមនឹងហានិភ័យនៃការមិនត្រូវបានគេយកចិត្តទុកដាក់ដោយសារសម្ពាធផ្នែកសេដ្ឋកិច្ចលើគ្រួសារ "មានគ្រួសារមួយចំនួនទទួលបានសេវាខ្លះពីមជ្ឈមណ្ឌលរបស់យើង ប៉ុន្តែពួកគេក៏លែងមកមណ្ឌលរបស់យើងទៀត ដោយសារពួកគេគ្មានពេលវេលា។ ពួកគេនិយាយថា ពួកគេត្រូវចំណាយពេលជាមួយនឹងកូនផ្សេងទៀត ឬត្រូវទៅរកប្រាក់ចំណូល។ ពួកគេត្រូវតែទុកកូនចោល។ ដោយសារខ្ញុំបានឃើញនៅពេលដែលខ្ញុំទៅជួបពួកគេ បញ្ហាចម្បងដែលពួកគេប្រឈមនោះគឺផ្នែកហិរញ្ញវត្ថុ។ ពួកគេត្រូវសងលុយធនាគារ។ គ្រួសារក្រីក្រមួយចំនួនមិនបានយកចិត្តទុកដាក់ចំពោះកូនៗរបស់ពួកគេ ប៉ុន្តែគ្រួសារមួយចំនួនទៀតក៏យកចិត្តទុកដាក់ខ្លាំងចំពោះកូនៗរបស់ពួកគេដែរ។"

កត្តាហិរញ្ញវត្ថុក្នុងការទទួលបានការអប់រំ ត្រូវបានគេមើលឃើញថាជាឧបសគ្គជាពិសេស ដោយសារការអប់រំភាគច្រើនមានតែនៅតាមវិស័យឯកជន។ ឪពុក/ម្តាយម្នាក់បានរាយការណ៍ថា នាយកសាលាអាណិតកូនរបស់ពួកគាត់ដែលមានអូទីស្សឹម គឺគេគិតថ្លៃ២០ដុល្លារក្នុងមួយម៉ោងសម្រាប់ការអប់រំ។ សាលារៀនផ្សេងទៀតនៅខេត្តសៀមរាបមានការផ្តល់ជូននូវការលើកលែងមួយចំនួន ប៉ុន្តែការគិតថ្លៃរយៈពេលពីរថ្ងៃក្នុងមួយសប្តាហ៍ក្នុងរយៈពេលបីខែគឺមានតម្លៃ ១០០ដុល្លារ ដែលជាការចំណាយលើសពីថវិការបស់គ្រួសារ។

គ្រួសារដែលរស់នៅក្នុងភាពក្រីក្រទំនងជា មិនសូវមានលទ្ធភាពទទួលបានព័ត៌មានសំខាន់ៗអំពីសេវា និងការផ្តល់ជូន។ ព័ត៌មានជាច្រើនដែលមានសម្រាប់គ្រួសារគឺអាស្រ័យទៅលើការចូលប្រើប្រាស់អ៊ីនធើណែត និងប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយសម្រាប់មនុស្សមួយចំនួនធំគឺមិនមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានតាមរយៈមធ្យោបាយទាំងនេះទេ។

អង្គការមួយចំនួនផ្តល់ការឧបត្ថម្ភជាសម្ភារដល់គ្រួសារនានា ជាឧទាហរណ៍ សាលារៀនមួយបញ្ជាក់ថា "យើងផ្តល់ការអប់រំពិសេស សេវាអប់រំប្រែកបដោយបរិយាបន្ន ម្ហូបអាហារ និងអាហារសម្រន់ អង្ករ ដល់គ្រួសារក្រីក្រ និងផ្តល់សេវាថែទាំសុខភាព និងសេវាបញ្ជូនទៅរកដៃគូដែលជាអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត។ យើងឧបត្ថម្ភដល់គ្រួសារទាំងមូល ផ្តល់ឯកសណ្ឋានសិក្សា សម្ភារនិងកន្លែងស្នាក់នៅ។" ទោះបីជាយ៉ាងណា ឧទាហរណ៍នៃការឧបត្ថម្ភទាំងនេះគឺជាករណីលើកលែងខ្លះៗ វាមិនមែនជាករណីទូទៅនោះទេ។ គ្រួសារដែលរស់នៅក្នុងសហគមន៍ជនបទមានការលំបាកខ្លាំងបំផុតក្នុងការទទួលបានសេវា ឧទាហរណ៍ ទោះបីជាមានអង្គការមួយចំនួនដូចជា អង្គការអេពិកអាតនៅក្នុងខេត្តកំពត ដែលផ្តល់ជូនមធ្យោបាយធ្វើដំណើរ ដើម្បីធានាថាគ្រួសារអាចចូលរួមបាន។ អង្គការមួយដែលស្ថិតនៅខេត្តបាត់ដំបងបានរាយការណ៍ថា "យើងឃើញមានអ្នកដែលមានអូទីស្សឹមមកគ្លីនិក ប៉ុន្តែពួកគេគឺជាអ្នកទីក្រុង។ យើងមិនសូវឃើញមានមកពីតាមខេត្តឡើយ។ ប្រជាជននៅទីនោះក្រីក្រ។ យើងមិនឃើញមានអ្នកមកពីគ្រួសារកសិករក្រីក្រទេ។"

**របបគំហើញទី៧៖**

ទីណាដែលមានការជួយជ្រោមជ្រែងពីអ្នកឯកទេស ទីនោះមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ។ អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗផ្តល់សេវាមួយចំនួនទាក់ទងនឹងការវាយតម្លៃ ការអប់រំ និងការគាំទ្រសង្គមដល់កុមារនិងគ្រួសារ ហើយក្នុងករណីខ្លះ មានការប្រាស្រ័យទាក់ទង និងការគាំទ្រយ៉ាងល្អនៅគ្រប់សេវាទាំងនេះ។ ក្នុងករណីមួយចំនួន មានប្រាស្រ័យទាក់ទងបានល្អប្រសើរ រវាងអង្គការមិនមែនរដ្ឋាភិបាលនិងដៃគូរាជរដ្ឋាភិបាល ហើយបង្កើតបានជាមូលដ្ឋានសម្រាប់ផ្តល់ការអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែក៏មានភស្តុតាងមួយចំនួនបង្ហាញថា សេវាមួយចំនួនដែលកំពុងត្រូវបានរៀបចំនិងដាក់ឱ្យដំណើរការ តម្រូវឱ្យមានការសម្របសម្រួលកាន់តែប្រសើរជាងមុន។ បច្ចុប្បន្ននេះ ការអន្តរាគមន៍ភាគច្រើនត្រូវបានផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាល ហើយអ្នកឆ្លើយសំណួរបានបង្ហាញពីតម្រូវការឱ្យមានការចូលរួមពីវិស័យសាធារណៈឱ្យបានច្រើនថែមទៀត។

អង្គការមិនមែនរដ្ឋាភិបាល (NGOs) ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់សេវាគាំទ្រដល់អ្នកមានអូទីស្សឹម និងគ្រួសាររបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ សេវាទាំងនេះរាប់បញ្ចូលតាំងពីការវាយតម្លៃបឋម និងការកំណត់អំពីតម្រូវការរបស់កុមារតាមរយៈការផ្តល់ជូននូវការព្យាបាល ការអប់រំ និងការផ្តល់ការគាំទ្រដល់គ្រួសារ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានលើកឡើងថា ការកំណត់អត្តសញ្ញាណកុមារដែលមានអូទីស្សឹមគឺ មិនមានភាពស៊ីសង្វាក់គ្នានៅឡើយ ខណៈដែលមានគោលការណ៍មួយចំនួនមានការចង្អុលបង្ហាញ ប៉ុន្តែនៅមានកុមារមានអូទីស្សឹមជាច្រើនមិនទាន់ត្រូវបានកំណត់អត្តសញ្ញាណតាមរយៈប្រព័ន្ធបច្ចុប្បន្ននៅឡើយ។ អង្គការនានា រួមទាំងអង្គការសមាគមសម្រាប់ជំនួយនិងសង្គ្រោះនៃប្រទេសជប៉ុន (AAR Japan) បានប្តេជ្ញាចិត្តថា ខ្លួននឹងគាំទ្រគ្រួសារដែលមានកុមារមានអូទីស្សឹម តាមរយៈការវាយតម្លៃ និងការកំណត់អត្តសញ្ញាណ ហើយពួកគេបានរាយការណ៍ថា "កុមារអូទីស្សឹមអាចមិនត្រូវបានសម្គាល់ដោយនីតិវិធីវាយតម្លៃបច្ចុប្បន្ន។ ប៉ុន្តែ AAR បានកំណត់កុមារម្នាក់ថា មានអូទីស្សឹមដោយបានសន្និដ្ឋានជាដំបូងថាគាត់មានការលំបាកខាងបញ្ញា។ វាជាភស្តុតាងបានបង្ហាញថា កុមារមិនត្រូវបានរាប់បញ្ចូលដោយសារតែខ្វះលក្ខណៈវិនិច្ឆ័យលើការវាយតម្លៃដើម្បីកំណត់

ពួកគេថាមានអូទីស្សឹម។"

ទំនាក់ទំនងរវាងអង្គការមិនមែនរដ្ឋាភិបាល និងស្ថានប័នសាធារណៈត្រូវបានគេមើលឃើញថា មានសារសំខាន់ក្នុងការធ្វើឱ្យបុគ្គលនិងក្រុមគ្រួសារមួយចំនួនទទួលបានការឧបត្ថម្ភ។ អ្នកតំណាងរបស់នាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងថា "យើងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាជាតិដើម្បីកុមារ ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតដែលធ្វើការជាមួយនឹងវិស័យពិការភាព។ យើងធ្វើការជាមួយ AAR Japan នៅស្រុកខ្សាច់កណ្តាល អង្គការ Save the Children អង្គការCRS និងអង្គការមិនមែនរដ្ឋាភិបាល Aide et Action។ "ការធ្វើការរួមគ្នារវាងរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលគឺជាលក្ខណៈពិសេសដ៏សំខាន់មួយក្នុងការធានាថា បុគ្គលនិងក្រុមគ្រួសារមួយចំនួនធំទទួលបានការគាំទ្រដូចដែលបានបញ្ជាក់ដោយវេជ្ជបណ្ឌិតរបស់រដ្ឋាភិបាលមួយរូបដែលបានរាយការណ៍ថា "យើងធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលអាចផ្តល់នូវសេវានានាប្រសិនបើយើងមិនអាចផ្តល់ឱ្យបាន។" មានក្តីកង្វល់មួយចំនួនដែលអាចមានការពឹងផ្អែកខ្លាំងលើសេវាដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល"។ មានការបញ្ជាក់បន្ថែមថា "ដោយសារតែខ្ញុំធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ខ្ញុំដឹងថារដ្ឋាភិបាលគឺពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាល។ ពេលខ្លះខ្ញុំគិតថា អ្វីដែលយើងធ្វើក៏អាចជា ការកំហិតដល់សកម្មភាពមួយចំនួនរបស់រដ្ឋាភិបាលដែរ" ទាំងនេះ គឺជាទស្សនៈដែលបានចែករំលែកដោយអ្នកឆ្លើយសំណួរជាច្រើនដល់ការសិក្សា។

អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងអនុវត្តការងារលើវិស័យពិការភាព និងសុខុមាលភាពកុមារ មានកិច្ចសហការយ៉ាងជិតស្និទ្ធ និងបានបង្កើតភាពជាដៃគូដ៏ល្អជាមួយអ្នកផ្តល់សេវាជាច្រើន។ ប្រធានអង្គការមួយបានរាយការណ៍ថា "យើងធ្វើការជាមួយសមាជិកអង្គការបណ្តាញអូទីស្សឹមកម្ពុជា ដែលពួកគេមានសមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាលលើសពី ១០ ហើយយើងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣០ ដែលធ្វើការលើវិស័យពិការភាព។" សារសំខាន់នៃកិច្ចសហប្រតិបត្តិការនេះពិតជាមិនអាចកាត់ថ្លៃបាន។ អ្នកគ្រប់គ្រងមកពីមជ្ឈមណ្ឌលភូមិសន្តិភាព (PVC) ក្នុងខេត្តតាកែវ បានបង្ហាញទស្សនៈថា "យើងបានរៀនសូត្រច្រើនពីអង្គការមិនមែនរដ្ឋាភិបាលជាច្រើនក្នុងប្រទេសកម្ពុជា ប៉ុន្តែជំនាញរបស់យើងមានកម្រិតនៅឡើយ។"

ដើម្បីទទួលបានការឧបត្ថម្ភរបស់អង្គការមិនមែនរដ្ឋាភិបាលគឺពឹងផ្អែកលើទីតាំងភូមិសាស្ត្រ ដោយតំបន់មួយចំនួនបានផ្តល់ជូនប្រសើរជាងតំបន់ផ្សេងទៀត។ ប្រធានរបស់អង្គការមិនមែនរដ្ឋាភិបាលមួយដែលស្ថិត នៅខេត្តបាត់ដំបងបានបញ្ចេញមតិថា "នៅភាគខាងត្បូងនៃប្រទេស មានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាព ប៉ុន្តែនៅភាគខាងជើងគឺមានអង្គការមិនមែនរដ្ឋាភិបាលតិចជាង។" ប៉ុន្តែគាត់នៅតែជឿជាក់ថា "អង្គការមិនមែនរដ្ឋាភិបាលគឺជាកត្តាជំរុញក្នុងការផ្លាស់ប្តូរនិងការផ្តល់ជូន"។ ពួកគេមើលឃើញថាស្ថានភាពសម្រាប់គ្រួសារជាច្រើនដែលរស់នៅជាមួយជនមានពិការភាព រួមទាំងជនមានអូទីស្សឹមគឺមានភាពប្រសើរឡើងក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ។

**របបគំហើញទី៨៖**

ឱកាសសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបម្រើការងារគឺនៅមានកម្រិត ដោយបង្ហាញនូវក្តីកង្វល់អំពីការផ្តល់សេវាឱ្យបានទៅដល់មនុស្សពេញវ័យដែលមានអូទីស្សឹម។ ចំណុចនេះពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងកង្វះការអប់រំនិងការបណ្តុះបណ្តាល។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនកំពុងបង្កើតការផ្តល់សេវានៅក្នុងផ្នែកនេះ ប៉ុន្តែបច្ចុប្បន្នការទទួលបានសេវានៅមានកម្រិតនៅឡើយ។

ផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាពឆ្នាំ ២០១៩-២០២៣ បានកំណត់ពីការបង្កើនការងារនិងសន្តិសុខសេដ្ឋកិច្ចសម្រាប់ជនមានពិការភាព គឺជាកិច្ចការអាទិភាព (គោលដៅជាយុទ្ធសាស្រ្តទី១)។ ប៉ុន្តែ សម្រាប់អ្នកដែលមានអូទីស្សឹម កង្វះខាតវិជ្ជាជីវៈ និងឱកាសទទួលបានការងារគឺជាកត្តារាំងស្ទះទាំងឱកាសរស់នៅរបស់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេ។

ការព្រួយបារម្ភត្រូវបានបង្ហាញដោយអ្នកជំនាញជាច្រើនដែលធ្វើការជាមួយមនុស្សវ័យក្មេងដែលមានអូទីស្សឹមថា នៅពេលពួកគេពេញវ័យ ពួកគេនឹងមានឱកាសទទួលបានការងារតិចតួច។ អ្នកគ្រប់គ្រងសាលារៀនឯកទេសសម្រាប់កុមារដែលមានពិការភាពបានបង្ហាញទស្សនៈថា ជម្រើសក្នុងការទទួលបានការងារបន្ទាប់ពីបញ្ចប់ការសិក្សាសម្រាប់អ្នកមានអូទីស្សឹមនៅមានកម្រិត។ មានការលើកឡើងថា "មានការខ្វះខាតក្នុងការផ្តល់ជំនាញសម្រាប់ឱកាសការងារដល់កុមារអូទីស្សឹម" ប៉ុន្តែគេនៅតែជឿជាក់ថា បើគ្មានការគាំទ្រជាផ្លូវការទេ លទ្ធភាពនៃការរីកចម្រើនគឺមានតិចតួច នៅក្នុងវិស័យនេះ "យើងគួរតែមានការគាំទ្រពីរដ្ឋាភិបាល ដើម្បីធានាថា កុមារ/យុវជនអូទីស្សឹមអាចមានការងារធ្វើនាពេលអនាគត នៅគ្រប់វិស័យ។" ហានិភ័យនៃការធ្លាក់ចូលទៅក្នុងភាពក្រីក្របន្ថែមទៀតត្រូវបានសង្កត់ធ្ងន់ដោយអ្នកគ្រប់គ្រងសាលារៀនពិសេសម្នាក់ទៀត ដោយបានបញ្ជាក់ដូច្នេះថា "គួរមានកន្លែងសម្រាប់កុមារទាំងនេះធ្វើការទាំងផ្នែកកសិកម្ម ឬការងារកសិដ្ឋាន ដើម្បីរកប្រាក់ចិញ្ចឹមជីវិតនៅពេលពួកគេធំឡើង។ ការងារមួយចំនួនដែលជនអូទីស្សឹមអាចធ្វើបានដើម្បីទទួលបានប្រាក់ខ្លះ។"

ឪពុកម្តាយបានគាំទ្រចំពោះកង្វល់ទាំងនេះ ហើយបានលើកឡើងថា សម្រាប់មនុស្សវ័យក្មេងដែលមានអូទីស្សឹម មានឧបសគ្គជាក់លាក់ផ្សេងៗ ដែលពួកគេបានជួបប្រទះដែលមានភាពខុសគ្នាពីជនមានពិការភាពផ្សេងទៀត "ពួកគេមិនដូចកុមារដទៃទៀតទេ។ ដូច្នេះ យើងត្រូវរៀបចំសេវាសម្រាប់ការស្តារលទ្ធភាពពលកម្ម រួមទាំងការងារជាសិប្បកម្ម ឬអ្វីផ្សេងទៀតទៅតាមទេពកោសល្យរបស់ពួកគេ។ នេះគួរតែជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល ប៉ុន្តែកិច្ចការទាំងនេះពុំទាន់មាននៅឡើយ ភាគច្រើនមានតែសម្រាប់ជនមានពិការភាពកាយសម្បទា។ ខ្ញុំគិតថារឿងនេះវាពិបាកណាស់ ហើយនៅពេលដែលនាងមានអាយុ១៥ឆ្នាំ តើនាងនឹងសិក្សាអ្វី? ព្រោះនាងមិនដូចជាក្មេងមិនមានពិការភាពផ្សេងទៀតឡើយ ដូច្នេះយើងគួរចាប់ផ្តើមអាជីវកម្មណាមួយដែលសមនឹងនាង។"

តម្រូវការសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈច្បាស់លាស់គឺជាប្រធានបទដែលលើកឡើងដោយទាំងអ្នកជំនាញ និងឪពុកម្តាយ ហើយសម្របតាមគោលបំណងដើម្បី "លើកកម្ពស់លទ្ធភាពទទួលបានការអប់រំខ្ពស់ប្រកបដោយសមធម៌ បរិយាបន្ន និងការរៀនសូត្រពេញមួយជីវិត" ដូចដែលបានបង្ហាញនៅក្នុងផែនការយុទ្ធសាស្រ្តអប់រំឆ្នាំ២០១៩-២០២៣ (ទំព័រទី៥៦)។ អ្នកតំណាងនៃកម្មវិធីសេវាអភិវឌ្ឍន៍ជនមានពិការភាព (DDSP) ក្នុងខេត្តពោធិ៍សាត់ បានលើកឡើងអំពីតម្រូវការដើម្បីអភិវឌ្ឍន៍ "សេវាផ្តល់ឱកាសការងារ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់បុគ្គលដែលមានអូទីស្សឹម។" ទស្សនៈស្រដៀងគ្នាមួយទៀតដែលបានបង្ហាញដោយអ្នកឯកទេសមកពីអង្គការ អេពិកអាត ក្នុងខេត្តកំពត និងដោយថ្នាក់ដឹកនាំមកពីសាលាឯកទេសនានា។ ថ្នាក់ដឹកនាំមកពីមជ្ឈមណ្ឌលភូមិសន្តិភាពក្នុងខេត្តតាកែវបានសួរថា "តើយើងគួរបន្តជួយពួកគេដល់ពេលណាទៀត? បន្ទាប់ពីនោះ តើអ្នកណានឹងជួយពួកគេ? យើងគួរតែផ្តល់ការបណ្តុះបណ្តាលអាជីព ឬឱកាសសម្រាប់ពួកគេ។ ពួកគេគួរតែអាចរកប្រាក់បាន។ តើយើងគួរជួយគេពេញមួយជីវិត ឬត្រូវធ្វើយ៉ាងណា? ចំពោះអ្នកជំនាញទាំងអស់នេះ យល់ថាពេលដែលបុគ្គលម្នាក់មានអូទីស្សឹមមិនបានសិក្សា ពួកគេទំនងជានៅផ្ទះ ហើយគ្មានការងារធ្វើ។ ទស្សនៈនេះត្រូវបានបន្ទរដោយឪពុកម្តាយមួយក្រុមដោយបញ្ជាក់បន្ថែមយ៉ាងដូច្នេះថា "កុមារដែលមានអាយុច្រើនចាំបាច់ត្រូវមានការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសអ្នកដែលមកពីគ្រួសារក្រីក្រ។ ក្រោយពីហ្វឹកហាត់នៅទីនេះ កុមារខ្លះនៅតែនៅផ្ទះដដែល ហើយគ្រួសារមិនសប្បាយចិត្ត។ បើយើងមានកម្មវិធីទាំងនេះ គ្រួសារនឹងមានការសប្បាយចិត្ត។" មានការលើកឡើងស្រដៀងគ្នានេះដែរ ពីសំណាក់តំណាងមកពីសមាគមមាតាបិតាសម្រាប់អ្នកមានពិការភាពសតិបញ្ញាដែលជឿថា មានភាពសមស្របក្នុងការផ្តល់ការបណ្តុះបណ្តាលជាក់លាក់ដូចជា "ធ្វើការជាអ្នករត់តុក្នុងភោជនីយដ្ឋាន ឬបើកហាងដើម្បីឱ្យពួកគេចូលរួមបម្រើការងារ" អ្នកឆ្លើយសំណួរទាំងនេះក៏មានអារម្មណ៍ថា ឪពុកម្តាយគួរតែទទួលខុសត្រូវបន្ថែមទៀតសម្រាប់ការរៀបចំទុកដាក់កូនចៅរបស់ពួកគេឱ្យរស់នៅឯករាជ្យនិងមានការងារ។

ការផ្តល់យោបល់ទូទៅមួយគឺថា គួរតែផ្តោតទៅលើការ

បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានវគ្គសិក្សាដែលសក្តិសមសម្រាប់មនុស្សវ័យក្មេងដែលមានអូទីស្សឹម។ អ្នកតំណាងម្នាក់នៃកម្មវិធីសេវាអភិវឌ្ឍន៍ជនពិការ (DDSP) ខេត្តពោធិ៍សាត់ យល់ថាគួរមាន "សាលាជំនាញវិជ្ជាជីវៈសម្រាប់អ្នកដែលមានអូទីស្សឹមនៅថ្នាក់ជាតិ។" តម្រូវការនេះត្រូវបានគេមើលឃើញថាជារឿងល្អ ដែលប្រធានសាលាឯកទេសបានលើកឡើងថា "នៅតាមខេត្តនីមួយៗ យើងគួរតែមានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមួយ ដើម្បីផ្តល់ឱកាសការងារដល់ពួកគេ"។ តម្រូវការនេះត្រូវបានទទួលស្គាល់ដោយអ្នកតំណាងរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ដែលជឿថា ប្រទេសកម្ពុជាចាំបាច់ត្រូវ "មានសាលារៀនសម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់យុវជនដែលមានអូទីស្សឹម ហើយចាំបាច់ត្រូវមានអ្នកឯកទេស/អ្នកជំនាញដើម្បីបង្រៀនពួកគេក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងស្វែងរកការងារឱ្យពួកគេ"។ ការបញ្ជាក់បន្ថែមអំពីគម្លាតក្នុងការផ្តល់ជូននេះបានមកពីតំណាងពីនាយកដ្ឋានអប់រំពិសេសរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ប៉ុន្តែតំណាងរូបនេះក៏បានភ្ជាប់មកជាមួយនឹងការក្រើនរំឭកថា "កិច្ចការនេះគឺហួសពីសមត្ថភាពនៃវិស័យអប់រំ វាទាក់ទងនឹងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ" ដែលជាការបង្ហាញយ៉ាងច្បាស់អំពីតម្រូវការសម្រាប់ការទំនាក់ទំនង និងកិច្ចសហការប្រកបដោយប្រសិទ្ធភាពនៅទូទាំងស្ថាប័នរដ្ឋាភិបាល។

កង្វះឱកាសវិជ្ជាជីវៈនិងឱកាសការងារដែលចៀសមិនរួចនាំឱ្យភាពក្រីក្រមានការកើនឡើង និងការពឹងផ្អែកលើសហគមន៍មូលដ្ឋាននិងរដ្ឋាភិបាល។ ការស្រាវជ្រាវកន្លងមកដែលបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាដោយលោក Gartrell (២០១០) បានបង្ហាញពីរបៀប "ជនមានពិការភាពទំនងជាពុំមានការងារធ្វើច្រើនជាងដៃគូរបស់ពួកគេដែលជាជនមិនមានពិការភាព មានឋានៈក្នុងការងារទាបជាង ទទួលបានប្រាក់ចំណូលតិចជាង ឬស្ថិតក្រៅទីផ្សារការងារ"។ របកគំហើញទាំងនេះបានមកពីការសិក្សាលើប្រជាជនដែលមានពិការភាពជាច្រើននាក់។ កិច្ចការនេះបង្ហាញឱ្យឃើញពីការវិភាគស្ថានភាពនេះថា ឱកាសវិជ្ជាជីវៈ និងឱកាសការងារសម្រាប់ជនមានពិការភាពនៅតែជាបញ្ហាប្រឈមនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែថាលក្ខណៈជាក់លាក់នៃជនមានអូទីស្សឹម គឺទាមទារឱ្យមានការគិតគូរទាក់ទងនឹងប្រភេទនៃការផ្តល់ជូនដែលត្រូវធ្វើ។

# អនុសាសន៍

១. **ការលើកកម្ពស់ការយល់ដឹង**

ការយល់ដឹងអំពីអូទីស្សឹមគួរតែត្រូវបានលើកឡើងតាមរយៈព្រឹត្តិការណ៍ឬសិក្ខាសាលាផ្សេងៗដែលធ្វើឡើងនៅក្នុងប្រទេស។ ទាំងនេះសំដៅលើការបង្កើនការយល់ដឹងដល់អ្នកជំនាញដែលធ្វើការក្នុងវិស័យអប់រំ សុខាភិបាល ការងារ និងសង្គម ហើយគួរតែភ្ជាប់ទៅជាមួយនឹងការផ្តល់ខិត្តប័ណ្ណ និងសម្ភារអប់រំផ្សេងៗសម្រាប់ការប្រើប្រាស់នៅទូទាំងប្រទេស។ វិធីសាស្ត្រនេះគួរតែមានការចូលរួមទាំងស្រុងដោយជនមានអូទីស្សឹម និងក្រុមគ្រួសាររបស់ពួកគេ។

ឯកសាររបស់រាជរដ្ឋាភិបាលនាពេលអនាគត និងឯកសារមកពីអង្គការមិនមែនរដ្ឋាភិបាលដែលដោះស្រាយបញ្ហាពិការភាព គួរតែបង្កើតបានជាសេចក្តីយោងនិងលក្ខណៈពិសេសរបស់អូទីស្សឹម ដើម្បីបង្កើនការយល់ដឹងនៅថ្នាក់ជាតិ។

គ្រប់ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកជំនាញទាំងអស់គួរតែបង្កើតខិត្តប័ណ្ណដែលពន្យល់ពីលក្ខណៈនៃអូទីស្សឹម។ លើសពីនេះ ខិត្តប័ណ្ណទាំងនេះគួរតែកំណត់អត្តសញ្ញាណសេវាដែលមានផ្តល់ព័ត៌មានទំនាក់ទំនងលម្អិត និងពន្យល់អំពីសេវាទាំងនោះដែលមាន ដល់អ្នកដែលមានអូទីស្សឹម និងគ្រួសាររបស់ពួកគេ។

គួរពិចារណាលើយុទ្ធនាការលើកកម្ពស់ការយល់ដឹងដោយប្រើប្រាស់ការផ្សព្វផ្សាយថ្នាក់ជាតិ និងបោះពុម្ពផ្សាយ។ នេះគួរតែរួមបញ្ចូលការបង្ហាញគំរូនៃបុគ្គលដែលមានអូទីស្សឹម ដែលកំពុងរួមចំណែកជាវិជ្ជមានដល់សហគមន៍របស់ពួកគេ។

ប្រព័ន្ធផ្សព្វផ្សាយសង្គមត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីទទួលបានព័ត៌មានអំពីអូទីស្សឹម ហើយវាអាចមានអត្ថប្រយោជន៍ ប៉ុន្តែចាំបាច់ត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្ន។ គួរតែផ្តល់ជូនឪពុកម្តាយនូវព័ត៌មានលម្អិតនៃប្រភពអ៊ីនធើណែតដែលមានសុវត្ថិភាព និងព័ត៌មានល្អៗពីកន្លែងដែលពួកគេអាចទទួលបានព័ត៌មានដែលអាចទុកចិត្តបាន។ អង្គការក្នុងស្រុកគួរ

តែពិនិត្យឡើងវិញនូវវិធីដែលពួកគេផ្តល់ព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីប្រាប់ដល់ឪពុកម្តាយ និងអ្នកជំនាញក្នុងការចូលទៅកាន់ប្រភពព័ត៌មានដែលអាចទុកចិត្តបាន។

គួរតែបង្កើតកញ្ចប់សម្ភារបណ្តុះបណ្តាល ដែលអាចជួយដល់គំនិតផ្តួចផ្តើមជាច្រើនដែលបានស្នើឡើងនៅក្នុងអនុសាសន៍ទាំងនេះ។ កិច្ចការនេះគួររាប់បញ្ចូលនូវសម្ភារដើម្បីធ្វើបទបង្ហាញ កញ្ចប់ព័ត៌មាន និងព័ត៌មានលម្អិតនៃគេហទំព័រ ដែលសមស្របនិងអាចចូលប្រើបាន។

ស្ថានប័នផ្នែកសាសនា នៅក្នុងប្រទេសកម្ពុជាក៏មានឥទ្ធិពលលើកិច្ចការនេះផងដែរ។ គួរពិចារណាការលើកកម្ពស់ការយល់ដឹង អំពីអូទីស្សឹមក្នុងថ្នាក់ដឹកនាំនៃស្ថាប័នសាសនា ដើម្បីឱ្យពួកគេអាចក្លាយជាប្រភពនៃការបង្កើនការ គាំទ្រ និងព័ត៌មានសម្រាប់គ្រួសារ។

ជារៀងរាល់ឆ្នាំ នៅថ្ងៃទី០២ ខែមេសា គឺជាទិវាការយល់ដឹងអំពីអូទីស្សឹមពិភពលោក។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួនតូចបានអនុវត្តការផ្សព្វផ្សាយប្រចាំសប្តាហ៍/ខែ ដែលមានជនមានអូទីស្សឹម និងក្រុមគ្រួសាររបស់ពួកគ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអូទីស្សឹមក្នុងអំឡុងសប្តាហ៍នៃទិវានេះ។ ទាំងស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលគួរតែរួមគ្នាក្នុងធ្វើ "ទិវា/សប្តាហ៍យល់ដឹងអំពីអូទីស្សឹមពិភពលោក ដើម្បីបង្កើនការយល់ដឹងនិងពង្រឹងចលនាមាតាបិតា"។

២. **ការពង្រឹងការអប់រំ**

ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ធ្វើការជាមួយជនដែលមានអូទីស្សឹម គួរតែបង្កើតផែនការយុទ្ធសាស្ត្រជាតិ ដើម្បីពង្រឹងលទ្ធភាពទទួលបានការអប់រំសម្រាប់កុមារ និងយុវជនដែលមានអូទីស្សឹម នៅក្នុងរបៀបវារៈនៃការអប់រំប្រកបដោយបរិយាបន្ន។ ផែនការនេះគួរតែត្រូវបានភ្ជាប់មកជាមួយតារាងពេលវេលាលម្អិត ហើយគួរតែបញ្ចូលប្រព័ន្ធតាមដានត្រួតពិនិត្យទៅក្នុងផែនការនេះ ទាំងលើការអនុវត្តនិងលទ្ធផលនៅកម្រិតផលជះ។

វិធីសាស្ត្រតាមបែបសម្របសម្រួល ក្នុងការបង្កើនការយល់ដឹងអំពីអូទីស្សឹម រួមជាមួយនឹងសម្ភារគំរូដែលបង្ហាញពីវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាព គួរតែត្រូវបានដាក់ឱ្យអនុវត្តនៅសាលារៀនទូទាំងប្រទេស។ កិច្ចការនេះគួរតែរួមបញ្ចូលឱកាសដើម្បីការអភិវឌ្ឍការយល់ដឹងនិងអាកប្បកិរិយាវិជ្ជមានចំពោះកុមារដែលមានអូទីស្សឹម និងក្រុមគ្រួសាររបស់ពួកគេ និងឧទាហរណ៍ជាក់ស្តែងអំពីធនធាននិងវិធីសាស្ត្របង្រៀនដែលបានបង្ហាញឱ្យឃើញពីអត្ថប្រយោជន៍សម្រាប់អ្នកសិក្សាដែលមានអូទីស្សឹមនៅតាមទីកន្លែងនានា។ កម្មវិធីបែបនេះគួរតែត្រូវបានអនុវត្តនៅទូទាំងប្រទេស ដើម្បីធានាថា អ្នកជំនាញដែលធ្វើការនៅក្នុងសហគមន៍ទទួលបានឱកាសបណ្តុះបណ្តាលស្មើគ្នាដូចអ្នកនៅទីប្រជុំជនដែរ។

អង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នផ្សេងទៀត ដោយមានការគាំទ្រពីក្រសួងពាក់ព័ន្ធ គួរតែធ្វើការជាមួយអ្នកផ្តល់ការអប់រំវិជ្ជាជីវៈ ដើម្បីកំណត់ឱកាសក្នុងការកែប្រែវគ្គសិក្សាដែលមានស្រាប់ និងបង្កើតវគ្គសិក្សាថ្មីដែលអ្នកមានអូទីស្សឹមអាចរៀនបាន។ ការយល់ដឹងនិងជំនាញរបស់ក្រុមអ្នកវិជ្ជាជីវៈ ដែលធ្វើការលើវគ្គសិក្សាជំនាញវិជ្ជា ជីវៈគួរត្រូវបានលើកកម្ពស់តាមរយៈសិក្ខាសាលាដែលរៀបចំជាបន្តបន្ទាប់។

គួរផ្តល់ការគាំទ្រដល់អ្នកផ្តល់ការបណ្តុះបណ្តាលគ្រូឧទ្ទេសដំបូងទាំងអស់ ដើម្បីធ្វើការអភិវឌ្ឍសំខាន់ៗចំពោះកម្មវិធីបង្រៀនដែលនឹងធានាថា គ្រូបង្រៀនថ្មីទាំងអស់មានវិជ្ជាជីវៈដោយមានការយល់ដឹងអំពីអូទីស្សឹមនិងមានយុទ្ធសាស្ត្របង្រៀនជាច្រើន ដែលសមស្របទៅនឹងតម្រូវការរបស់ពួកគេ។ នាយកដ្ឋានអប់រំពិសេសគួរពិចារណាធ្វើការយ៉ាងជិតស្និទ្ធជាមួយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដើម្បីបង្កើតឯកសារកម្មវិធីសិក្សាជាក់លាក់ដែលផ្តោតលើការបង្រៀនកុមារដែលមានអូទីស្សឹម។

ស្ថាប័នផ្តល់ការអប់រំថ្នាក់ឧត្តមសិក្សាគួរតែពិចារណាពីរបៀបបង្កើតវគ្គសិក្សានៃការអភិវឌ្ឍវិជ្ជាជីវៈ និងការបណ្តុះ បណ្តាលក្នុងសេវាសម្រាប់អ្នកជំនាញផ្នែកអប់រំនិងការថែទាំដោយផ្តោតលើអូទីស្សឹម។

សម្រាប់គំនិតផ្តួចផ្តើមទាំងអស់ដែលមានបំណងធ្វើឱ្យការអប់រំមានភាពប្រសើរឡើង គួរតែមានវិធីសាស្ត្រ

ដែលពិចារណាក្នុងការត្រួតពិនិត្យតាមដានការផ្លាស់ប្តូរនិងលទ្ធផលកម្រិតផលជះ។ កិច្ចការនេះគួរតែត្រូវបានភ្ជាប់មកជាមួយនូវយុទ្ធសាស្ត្រស្រាវជ្រាវថ្នាក់ជាតិដែលមានគោលបំណងផ្តល់នូវភស្តុតាងជាក់ស្តែងនៃប្រសិទ្ធភាពនៃការបង្រៀន និងការសិក្សាសម្រាប់កុមារ និងមនុស្សវ័យជំទង់ដែលមានអូទីស្សឹម។ ស្ថាប័នមានសមត្ថកិច្ចដូចជា វិទ្យាស្ថានជាតិអប់រំ អាចដឹកនាំស្រាវជ្រាវអំពីប្រភេទនៃការអប់រំ/អន្តរាគមន៍ នៅក្នុងបរិបទប្រទេសកម្ពុជា ដោយមានកិច្ចសហការយ៉ាងសកម្មពីនាយកដ្ឋានអប់រំពិសេស។

៣. **ការធ្វើឱ្យប្រសើរឡើងនូវការគាំទ្រផ្នែកសុខភាព និងការស្តារលទ្ធភាពពលកម្ម**

រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលគួរធ្វើការរួមគ្នាដើម្បីផ្តល់នូវវិធីសាស្ត្ររួមមួយក្នុងការបង្កើនការយល់ដឹងអំពីអូទីស្សឹម ក្នុងចំណោមអ្នកជំនាញផ្នែកសេវាសុខភាពនិងសង្គមទាំងអស់។ នេះគួរបញ្ចូលទាំងឱកាសក្នុងការអភិវឌ្ឍការយល់ដឹង និងអាកប្បកិរិយាវិជ្ជមានចំពោះអ្នកដែលមានអូទីស្សឹម និងគ្រួសាររបស់ពួកគេ។ គួរតែអនុវត្តកម្មវិធីទាំងនេះនៅទូទាំងប្រទេស ដើម្បីធានាថា អ្នកជំនាញដែលធ្វើការនៅក្នុងសហគមន៍ជនបទទទួលបានឱកាសបណ្តុះបណ្តាលស្មើគ្នាដូចអ្នកនៅក្នុងទីក្រុងដែរ។

គួរផ្តល់អាទិភាពទៅលើការពិនិត្យឡើងវិញអំពីវិធីនៃការព្យាបាលដោយចលនា ការព្យាបាលដោយមុខងារ និងការព្យាបាលដោយការនិយាយ រួមជាមួយនឹងការប្រឹក្សាជាមួយគ្រួសារ។ កិច្ចការទាំងនេះរួមបញ្ចូលទាំងការវិភាគអំពីការដែលអាចរកបាននូវអ្នកជំនាញដែលធ្វើការនៅក្នុងវិស័យទាំងនេះ និងការបង្កើតផែនការដើម្បីបង្កើនសមត្ថភាពនៅក្នុងសេវានានា។ ភាពចាំបាច់នេះ ទាមទារឱ្យមានការពិនិត្យឡើងវិញនូវវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចុប្បន្ន និងឱកាសសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈក្នុងប្រទេស ដែលអាចរកបានពីសាលាបច្ចេកទេសវេជ្ជសាស្ត្រ ដែលត្រួតពិនិត្យលើវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជាជំនួយការដូចជាគិលានុបដ្ឋាយិកានិងគ្រូពេទ្យព្យាបាលដោយចលនា ។ ក្រសួងសុខាភិបាលគួរតែពិនិត្យឡើងវិញនូវវគ្គបណ្តុះបណ្តាលដែលមានស្រាប់ ដើម្បីធានាថាមានខ្លឹមសារដែលអាចឱ្យបុគ្គលិកសុខាភិបាលថ្នាក់មូលដ្ឋានដែលធ្វើការផ្នែកសេវាថែទាំនិងព្យាបាល ទទួលបានការយល់ដឹងកាន់តែច្បាស់អំពីអូទីស្សឹម អំពីការកំណត់អត្តសញ្ញាណអូទីស្សឹម និងមធ្យោបាយដើម្បីផ្តល់ជំនួយសមស្រប។ វគ្គសិក្សានេះគួរតែសង្កត់ធ្ងន់លើគំរូពិការភាពបែបសង្គមនៃអូទីស្សឹម និងជៀសវាងនូវគំរូពិការភាពបែបវេជ្ជសាស្ត្រ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការការីតាស់ (Caritas-CCAMH) កំពុងផ្តល់វគ្គសិក្សាខ្លីៗអំពីអូទីស្សឹមរួចមកហើយដល់ឪពុកម្តាយ គិលានុបដ្ឋាយិកា គ្រូពេទ្យ គ្រូពេទ្យឯកទេសផ្នែកកុមារ និងអ្នកជំនាញសុខភាពផ្លូវចិត្តផ្សេងទៀត ដែលពួកគេត្រូវបានទទួលស្គាល់ និងជាអ្នកផ្តល់សេវាសុខាភិបាលជូនដល់ប្រជាជនទូទៅ។

ការស្វែងរកទាន់ពេលវេលានិងការអប់រំចិត្តសាស្ត្រនៅកម្រិតថែទាំបឋម ការផ្តល់សេវាកម្រិតខ្ពស់នៅថ្នាក់ស្រុកនិងខេត្តសម្រាប់អូទីស្សឹម-"គំរូថែទាំមួយជំហានឡើង-a stepped-up care model" អាចត្រូវបានសាកល្បងនៅក្នុងខេត្តដែលបានជ្រើសរើសមុនពេលការពង្រីក។ នាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន (DMHSA) នៃក្រសួងសុខាភិបាល គួរតែបញ្ចូលសេវាថែទាំ/ការព្យាបាលអូទីស្សឹម នៅក្នុងផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២១-២០៣០។

៤. **ការផ្តល់ឱកាសការងារ**

កង្វះឱកាសការងារបានផ្តល់ផលប៉ះពាល់អវិជ្ជមានដល់គ្រួសារនិងជាមូលហេតុចម្បងនៃភាពក្រីក្រ។ ដូច្នេះវាមានសារសំខាន់ណាស់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីអូទីស្សឹមក្នុងចំណោមនិយោជកទូទាំងប្រទេស។ កិច្ចការនេះគួរតែរួមបញ្ចូលការផ្តល់ករណីសិក្សានៃការងារទទួលបានជោគជ័យរបស់អ្នកដែលមានអូទីស្សឹម និងឱកាសសម្រាប់និយោជកដើម្បីចូលរួមជាមួយបុគ្គល និងក្រុមគ្រួសាររបស់ពួកគេ។ ការយល់ដឹងទាំងនេះអាចត្រូវបានផ្តល់ជូនតាមរយៈកម្មវិធីសិក្ខាសាលាដែលត្រូវអនុវត្តនៅទូទាំងប្រទេស។

គួរតែពិចារណាទៅលើការបណ្តុះបណ្តាលគ្រូបង្វឹកការងារដែលនឹងទទួល បានការកោតសរសើរលើកិច្ចការអូទីស្សឹម និងបុគ្គលផ្សេងទៀតដែលមានសក្តានុពលក្នុងការរួមចំណែកប្រកបដោយប្រសិទ្ធភាពដល់ផ្នែកធនធានមនុស្ស។ នៅក្នុងតួនាទីរបស់អ្នកជំនាញទាំងនេះនឹងមានតម្រូវការដើម្បីបង្កើតឱកាសការងារ ការ

ណែនាំ និងការវាយតម្លៃផ្ទាល់ខ្លួន ដែលធ្វើឱ្យមានការអភិវឌ្ឍជំនាញមួយផ្នែកនៃបុគ្គល ដែលមានអូទីស្សឹម។

គួរតែបង្កើតក្រុមអ្នកតំណាងរបស់និយោជក ដើម្បីធ្វើការជាមួយអ្នកផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមតូចមួយនៃជនដែលមានអូទីស្សឹមនិងក្រុមគ្រួសាររបស់ពួកគេ ដើម្បីផ្តល់ការប្រឹក្សាអំពីជំនាញដែលនិយោជកត្រូវការ ដែលអាចដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាល។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) គួរពិនិត្យមើល ការអនុវត្តគោលនយោបាយនាពេលបច្ចុប្បន្នទាក់ទងនឹងការងាររបស់ជនមានពិការភាពជាពិសេសអ្នកមានអូទីស្សឹមដើម្បីផ្តល់ជាអនុសាសន៍ផ្សេងៗ។ គួរតែធ្វើសិក្ខាសាលាផ្សេងៗ និងការបណ្តុះបណ្តាលការងារសម្រាប់ជនដែលមានអូទីស្សឹម តាមរយៈភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន មុននឹងធ្វើការពង្រីកការងារនេះ។

៥. **ការធ្វើផែនការ គោលនយោបាយ និងយុទ្ធសាស្ត្រដោយផ្តោតលើជនមានអូទីស្សឹម**

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពថ្មី ឆ្នាំ២០១៩-២០២៣ (NDSP) ដែលអះអាងពីការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងអស់ដែលមានពិការភាព គួរត្រូវបានពិនិត្យឡើងវិញ ដោយភាគីពាក់ព័ន្ធសំខាន់ៗ ដូចជាក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ក្នុងភាពជាដៃគូជាមួយក្រសួងពាក់ព័ន្ធ រួមទាំងក្នុងវិស័យសុខាភិបាល វិស័យ អប់រំ វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតំណាងអង្គការជនពិការកម្ពុជា (CDPOs) ក្នុងគោលបំណងបង្កើតគោលនយោបាយ និងការអនុវត្តប្រកបដោយបរិយាបន្នស្តីពីអូទីស្សឹម។

៦. **កិច្ចសហការអន្តរវិស័យ និងភាពជាដៃគូនៅទូទាំងក្រសួងពាក់ព័ន្ធ ដើម្បីបំពេញសិទ្ធិរបស់ជនមានអូទីស្សឹម**

ជនមានអូទីស្សឹមមានតម្រូវការច្រើន និង បញ្ហាប្រឈមផ្សេងៗគ្នា នៅក្នុងអាយុកាលរស់នៅរបស់ពួកគេ តាំងពីកំណើតរហូតដល់ពេញវ័យ នៅពេលដែលពួកគេឆ្លងកាត់ខ្សែកោងនៃការលូតលាស់របស់ពួកគេ ដូច្នេះហើយក្រុមអ្នកវិជ្ជាជីវៈពហុជំនាញនៅក្នុងវិស័យផ្សេងៗគ្នា ដូចជា វិស័យសុខាភិបាល អប់រំ ការងារ និងវិស័យសេវា សង្គម ពិតជាមានតម្រូវការចាំបាច់។ ជាការចាំបាច់ដែលស្ថាប័នអន្តរក្រសួងរបស់រាជរដ្ឋាភិបាលកម្ពុជា សម្របសម្រួលជាមួយអ្នកផ្តល់សេវាផ្សេងៗនៅទូទាំងក្រសួងពាក់ព័ន្ធ និងក្នុងវិស័យឯកជន និងវិស័យមិនមែនរដ្ឋាភិបាល ដើម្បីណែនាំ ត្រួតពិនិត្យ និងតាមដានក្នុងការធានាបាននូវសេវាប្រកបដោយគុណភាពដល់ជនមានអូទីស្សឹម។

៧. **ការចូលរួមពីវិស័យឯកជន និងវិស័យសាជីវកម្ម ដើម្បីបំពេញតម្រូវការរបស់ជនមាន អូទីស្សឹម**

ប្រទេសជាច្រើននៅក្នុងតំបន់និងក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ អនុវត្តបានជោគជ័យដោយមានការចូលរួមពីវិស័យឯកជននិងវិស័យសាជីវកម្ម ដើម្បីបង្កើតសេវាជាក់លាក់ទាក់ទងនឹងអូទីស្សឹម។ នៅក្នុងប្រទេសកម្ពុជា អ្នកផ្តល់សេវាឯកជនជាច្រើនក្នុងវិស័យអប់រំនិងសុខាភិបាល កំពុងធ្វើការយ៉ាងសកម្មលើកិច្ចការនេះ ដែលវាជាសក្តានុពលមិនទាន់បានយកមកប្រើប្រាស់។ សហគ្រិនដែលមានភាពជោគជ័យក្នុងវិស័យឯកជនគួរតែត្រូវបានគាំទ្រ ហើយគំរូ/អន្តរាគមន៍ដែលផ្អែកលើភស្តុតាង គួរតែត្រូវបានពង្រីកតាមរយៈភាពជាដៃគូនៃវិស័យសាធារណៈនិង វិស័យឯកជន។

៨. **ចលនាមាតាបិតា ដើម្បីឱ្យស្ថានភាពជនមានអូទីស្សឹមកាន់តែប្រសើរឡើង**

ដូចគ្នានឹងឪពុកម្តាយនៅទូទាំងពិភពលោកដែរ អ្នកថែទាំនិងឪពុកម្តាយ នៅក្នុងប្រទេសកម្ពុជាមានភាពតានតឹង និងព្រួយបារម្ភអំពីការធ្វើឱ្យស្ថានភាពកូនប្រុស/ស្រីរបស់ពួកគេមានភាពប្រសើរឡើង ហើយពួកគេដើរតួនាទីយ៉ាងសកម្ម ក្នុងការកំណត់គោលនយោបាយ កម្មវិធី និងសេវាសម្រាប់ជនមានអូទីស្សឹម។ បណ្តាញអូទីស្សឹមកម្ពុជា (CAN) ដែលជាសម្ព័ន្ធទូលំទូលាយនៃឪពុកម្តាយ អ្នកថែទាំ និងអ្នកផ្តល់សេវា គួរតែត្រូវបានពង្រឹងផងដែរ ដើម្បីចូលរួមជាមួយបណ្តាញអូទីស្សឹមក្នុងតំបន់ ដែលមានការសម្របសម្រួលដោយមជ្ឈមណ្ឌលជនពិការអាស៊ីប៉ាស៊ីហ្វិក (APCD) ប្រចាំនៅទីក្រុងបាងកក។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ សមាជិកក្រុម

| | |
|---|---|
| សាស្ត្រាចារ្យ Richard Rose<br>ប្រធានក្រុមការងារស្រាវជ្រាវ | ទទួលបន្ទុកជាថ្នាក់ដឹកនាំនិងគណៈគ្រប់គ្រងទូទៅនៃការសិក្សា ការទំនាក់ទំនងជាមួយជនបង្គោលរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ( DAC-SG ) និងជាមួយតំណាងកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាពនិងសមធម៌ ( ACCESS )<br>រៀបចំនិងបង្កើតឧបករណ៍ស្រាវជ្រាវ<br>គ្រប់គ្រងនិងវិភាគទិន្នន័យ |
| វេជ្ជបណ្ឌិត Bhoomikumar Jegannathan<br>សមាជិកទី ១ នៃក្រុមការងារស្រាវជ្រាវ | ទទួលបន្ទុកក្នុងការសម្របសម្រួលនៃសកម្មភាពក្នុងប្រទេស<br>ទំនាក់ទំនងជាទៀងទាត់ជាមួយសាស្ត្រាចារ្យ Rose<br>ទំនាក់ទំនងជាមួយក្រុមការងារក្នុងប្រទេសនិងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងគ្រប់គ្រងថវិកាសម្រាប់ការសិក្សាស្រាវជ្រាវ |
| កញ្ញាវេជ្ជបណ្ឌិត ម៉ុង ដាលីន<br>សមាជិកទី ២ នៃក្រុមការងារស្រាវជ្រាវ | ទទួលបន្ទុកអនុវត្តការងារតាមមូលដ្ឋាន<br>ការបែងចែកក្រុមការងារតាមមូលដ្ឋាន |
| លោកស្រី សុខ ឡៀវហៀត<br>សមាជិកទី ៣ នៃក្រុមការងារស្រាវជ្រាវ | ទទួលបន្ទុកអនុវត្តការងារតាមមូលដ្ឋាន<br>ត្រួតពិនិត្យការងារបកប្រែ |
| លោក ប៉ាត ពុទ្ធី<br>សមាជិកទី ៤ នៃក្រុមការងារស្រាវជ្រាវ | ទទួលបន្ទុកអនុវត្តការងារតាមមូលដ្ឋាន<br>ការសម្ភាតនិងការរៀបចំទិន្នន័យដំបូង |

## ឧបសម្ព័ន្ធទី២៖ ឯកសារដែលត្រូវបានពិនិត្យ សិក្សា និងវិភាគ

| ឯកសារ | ប្រភេទឯកសារ |
| --- | --- |
| ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ (NDSP) និង២០១៩-២០២៣ ភ្នំពេញ៖ ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) | ឯកសារផែនការគោលនយោបាយជាតិ |
| ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០១៩) ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣។ ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា | ឯកសារផែនការគោលនយោបាយជាតិ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (២០០៨) ផែនការសកម្មភាពជាតិស្តីពីជនពិការ រួមទាំងជនរងគ្រោះដោយសារគ្រាប់មីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ។ ភ្នំពេញ៖ (MoSVY) | ឯកសារគោលនយោបាយជាតិ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (២០០៩) ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ ភ្នំពេញ៖ (MoSVY) | ឯកសារគោលនយោបាយជាតិ |
| ក្រសួងអប់រំ យុវជន និងកីឡា (២០១០) គោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍន៍កុមារតូច។ ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា | ឯកសារគោលនយោបាយជាតិ |
| Salter, C, & Yeoh, W. (២០១៧) ជំហានតូចៗឆ្ពោះទៅរកវិជ្ជាជីវៈជាអ្នកព្យាបាលអ្នកមានការពិបាកក្នុងនិយាយនៅក្នុងប្រទេសកម្ពុជា៖ បទពិសោធន៍ដែលទទួលកន្លងមក។ ទស្សនវិស័យ ២ (១៧), ១០៤-១១៣ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Mak, M, & Nordtveit, B.H. (២០១១) "ការសម្របសម្រួលសមស្រប" ឬការអប់រំសម្រាប់ទាំងអស់គ្នា? ករណីកុមារមានពិការភាពនៅក្នុងប្រទេសកម្ពុជា។ ទិនានុប្បវត្តិនៃការសិក្សាគោលនយោបាយស្តីពីពិការភាព ២២ (១), ៥៥-៦៤ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Hackett, J.D., Hudson, R.F., West, E.A, & Brown, S.E. (២០១៦) ការអប់រំប្រកបដោយបរិយាបន្ននៅកម្ពុជាសម្រាប់ប្រជាជនដែលងាយរងគ្រោះ៖ ឆ្ពោះទៅរកគោលនយោបាយទស្សនវិស័យអេកូឡូស៊ី។ ទិនានុប្បវត្តិនៃការអប់រំពិសេសអន្តរជាតិ (២០១៦) ១៩ (១), ៣–១៤ ។ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Gartrell, A. (២០១០) "កង្កែបក្នុងអណ្តូង"៖ ការផាត់ជនមានពិការភាពចេញពីការងារក្នុងប្រទេសកម្ពុជា ពិការភាព និងសង្គម, ២៥ (៣), ២៨៩-៣០១ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Ravet, J, & Mtika, P. (២០២១)៖ បរិយាបន្នការអប់រំនៅក្នុងបរិបទដែលធនធានមានកម្រិត៖ ការសិក្សាអំពីសាលាបឋមសិក្សានៅជនបទក្នុងប្រទេសកម្ពុជា ទិនានុប្បវត្តិអន្តរជាតិនៃការអប់រំប្រកបដោយបរិយាបន្ន។ DOI: ១០.១០៨០/១៣៦០៣១១៦.២០២១.១៩១៦១០៤ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Burkhardt, J.A. (២០១៥) ប្រទេសកម្ពុជា និងពិការភាព។ The McMaster Journal Fall, ៣៦ - ៤០ | របាយការណ៍ |
| Hayes, A, & Bulat, J. (២០១៨) របាយការណ៍វិភាគស្ថានភាពការអប់រំរបស់កុមារមានពិការភាពនៅកម្ពុជា។ Washington D.C.: USAID | របាយការណ៍ស្រាវជ្រាវ |

| | |
|---|---|
| Bailey, S, & Nguon, S.K. (២០១៤) ការវិភាគស្ថានភាពសម្រាប់អភិបាលកិច្ចប្រកបដោយបរិយាបន្នពិការភាព និងការអភិវឌ្ឍសហគមន៍ នៅកម្ពុជា។ ភ្នំពេញ៖ UNICEF | របាយការណ៍ស្រាវជ្រាវ |
| ក្រុមប្រឹក្សាសកម្មភាពជនពិការ។ (២០០១)។ ប្រវត្តិសង្ខេបរបស់ប្រទេស៖ ការសិក្សាអំពីជនមានពិការភាព (កម្ពុជា)។ ភ្នំពេញ៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ និងអង្គការ JICA កម្ពុជា។ | របាយការណ៍ពិនិត្យឡើងវិញ |
| Shoemaker, D., Chhim, S,, Dom, S,, Ngov, C,, Kennedy, R,, Peach, D, & Rowland, A. (២០២០) ទស្សនៈរបស់ឪពុកម្តាយ៖ ការវាយតម្លៃរបស់កម្មវិធីអប់រំពិសេសនៃអង្គការម្លប់តាប៉ាង ប្រទេសកម្ពុជា។ Manchester៖ សាកលវិទ្យាល័យ Salford | របាយការណ៍ពិនិត្យឡើងវិញ |
| Kalyanpur, M. (២០១៦) គោលនយោបាយស្តីពីការអប់រំប្រកបដោយបរិយាបន្ន និងការអនុវត្តក្នុងបរិបទនៃការអភិវឌ្ឍអន្តរជាតិ។ មេរៀនពីប្រទេសកម្ពុជា - Zeitschrift für internationale Bildungsforschung und Entwicklungspädagogik ៣៩ ( ៣), ១៦-២១ - URN: urn:nbn:de:០១១១-pedocs-១៥៤៥២៦ - DOI: ១០.២៥៦៥៦/០១:១៥៤៥២ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Ilias, K., Cornish, K., Kummar, K., Park, M.S, & Golden, K. (២០១៨) ភាពតានតឹងក្នុងការចិញ្ចឹមបីបាច់កូន និងភាពធន់មាំរបស់ឪពុកម្តាយដែលមានកូនមានជំងឺអូទីស្សឹម នៅអាស៊ីអាគ្នេយ៍៖ ការវាយតម្លៃជាប្រព័ន្ធ។ Frontiers in Psychology. ៩. doi.org/១០.៣៣៨៩/fpsyg.២០១៨.០០២៨០ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Palmer M., Williams, J, & McPake, B. (២០១៩) ស្តង់ដារនៃការរស់នៅ និងពិការភាពនៅក្នុងប្រទេសកម្ពុជា, ទិនានុប្បវត្តិនៃការសិក្សាអភិវឌ្ឍន៍ ៥៥ (១១), ២៣៨២-២៤០២ ។ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Prigent, S. (២០១៩) "ការអប់រំសម្រាប់ទាំងអស់គ្នា" នៅកម្ពុជា៖ ការអប់រំតាមបែបប្រជាធិបតេយ្យ និងការផ្តល់សិទ្ធិអំណាចដល់កុមារដែលប្រឈមនឹងតម្លៃជាសាកលចំពោះការឧបត្ថម្ភរបស់រដ្ឋ ទិនានុប្បវត្តិអាស៊ីប៉ាស៊ីហ្វិកនៃនវិទ្យា, ២០: (១), ១-២១ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Morgan, F. & Tan, B-K. (២០១១) ការស្តារលទ្ធភាពពលកម្មកាយសម្បទាសម្រាប់កុមារពិការចលករខួរក្បាលនៅជនបទនៃប្រទេសកម្ពុជា៖ ការយល់ឃើញរបស់ឪពុកម្តាយចំពោះការអនុវត្តដែលផ្តោតលើគ្រួសារ។ ការថែទាំកុមារ សុខភាព និងការអភិវឌ្ឍ។ ៣៧(២), ១៦១-១៦៧។ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Zook, D.C. (២០១០) ពិការភាព និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា៖ វិធីសាស្ត្ររួមបញ្ចូលក្នុងការកសាងសហគមន៍ និងការចូលរួមរបស់ពលរដ្ឋពិការភាព និងសង្គម។ ២៥ (២), ១៤៩-១៦១ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| Cordier, S. (២០១៤) ការថែទាំជនមានពិការភាពសតិបញ្ញានៅក្នុងសហគមន៍ជនបទក្រីក្រក្នុងប្រទេសកម្ពុជា៖ បទពិសោធន៍ពីអង្គការ ADDអន្តរជាតិ យេនឌ័រ និងការអភិវឌ្ឍ, ២២ (៣), ៥៤៩-៥៦១ | ឯកសារស្រាវជ្រាវដែលត្រូវបានពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត |
| អង្គការសុខភាពពិភពលោក (២០១៧) WHO យុទ្ធសាស្ត្រប្រចាំតំបន់អាស៊ីអាគ្នេយ៍ស្តីពីវិបត្តិជំងឺអូទីស្សឹម។ ញូវដេលី៖ WHO | ឯកសារយុទ្ធសាស្ត្រ |

# ឧបសម្ព័ន្ធទី៣៖ ក្រមសីលធម៌ និងទម្រង់នៃកិច្ចព្រមព្រៀង

**ការវិភាគស្ថានភាព៖** ការផ្តល់ជូនជនមាន អូទីហ្សឹម( Autistic Spectrum Disorders ) នៅកម្ពុជា

### ក្រមសីលធម៌ក្នុងការអនុវត្តការងារ

ការវិភាគស្ថានភាពនៃការផ្តល់ជូនសម្រាប់ជនអូទីស្សឹមនៅកម្ពុជា (ហៅកាត់ថា គម្រោង) នឹងត្រូវធ្វើឡើងដោយអនុលោមពេញលេញទៅតាមក្រមសីលធម៌ក្នុងការស្រាវជ្រាវ។ ការសិក្សានេះនឹងប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំសីលធម៌ដែលបានកែប្រែ សម្រាប់ការស្រាវជ្រាវផ្នែកអប់រំរបស់សមាគមអ្នកស្រាវជ្រាវប្រទេសអង់គ្លេស និងស្តង់ដារសីលធម៌សម្រាប់ការស្រាវជ្រាវក្នុងអំឡុងពេលហានិភ័យខ្ពស់ផ្នែកសុខភាពសាធារណៈ ដែលចេញដោយអង្គការសុខភាពពិភពលោក។ អ្នកស្រាវជ្រាវទាំងអស់ និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការគ្រប់គ្រងគម្រោងនេះត្រូវចុះហត្ថលេខាលើកិច្ចសន្យា ដែលបង្ហាញពីការអនុវត្តតាមក្រមសីលធម៌នេះ។ ប្រធានក្រុមការងារស្រាវជ្រាវនឹងទទួលខុសត្រូវគ្រប់ចំណុចនៃការគ្រប់គ្រងប្រកបដោយក្រមសីលធម៌។

សមាជិកគម្រោងទាំងអស់ត្រូវធានាថា អ្នកចូលរួមទាំងអស់បានយល់យ៉ាងលម្អិតអំពីគោលបំណង និងលទ្ធផលរំពឹងទុកនៃគម្រោងស្រាវជ្រាវនេះ។ "ឯកសារសង្ខេបព័ត៌មានរបស់គម្រោង" ជាភាសាសាមញ្ញនឹងត្រូវបានផ្តល់ជូនជាភាសាខ្មែរ និងភាសាអង់គ្លេសសម្រាប់អ្នកចូលរួមទាំងអស់។ នៅពេលដែលចំណេះដឹងអក្ខរកម្មរបស់អ្នកត្រូវសម្ភាសន៍មានកម្រិតក្រុមការងារស្រាវជ្រាវត្រូវពន្យល់ដោយផ្ទាល់មាត់អោយច្បាស់មុនពេលប្រមូលទិន្នន័យ។ ព័ត៌មានដែលបានផ្តល់ជូននឹងសរសេរចូលក្នុងផ្នែកព័ត៌មានលម្អិតទំនាក់ទំនងនៃក្រុមការងារ។ អ្នកចូលរួមនឹងត្រូវបានណែនាំអំពីសិទ្ធិរបស់ពួកគេក្នុងការដកយកព័ត៌មានមកវិញ ឬដកយកចំណុចណាមួយ ហើយនឹងត្រូវបានជូនដំណឹងអំពីរបៀបរក្សាការសម្ងាត់ និងឯកជនភាព។

ការបណ្តុះបណ្តាលនឹងត្រូវបានផ្តល់ជូនដល់បុគ្គលិកមូលដ្ឋាន រួមទាំង កិច្ចប្រជុំស្តីពីក្រមសីលធម៌រួមគ្នា ធ្វើឡើងដោយប្រធានក្រុមការងារស្រាវជ្រាវ។ បុគ្គលិកមូលដ្ឋាននឹងត្រូវបានដាក់ពង្រាយ បន្ទាប់ពីពួកគេបានបញ្ចប់ការបណ្តុះបណ្តាល និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការអនុលោមតាមក្រមសីលធម៌។

ការចូលរួមក្នុងការស្រាវជ្រាវនឹងធ្វើឡើងដោយស្ម័គ្រចិត្ត ហើយការព្រមព្រៀង ដោយមានការជូនដំណឹងនឹងត្រូវបានទទួលយកជាលាយលក្ខណ៍អក្សរដោយប្រើទម្រង់ជាភាសាដែលមានភាពងាយស្រួលដល់អ្នកឆ្លើយសំណួរ។ ត្រូវសុំការព្រមព្រៀងផ្ទាល់មាត់ពីកុមារ ឬជនមានសមត្ថភាពយល់ដឹងនៅមានកម្រិតដោយទទួលបានការព្រមព្រៀងពីមាតាបិតា/អាណាព្យាបាល។

រាល់ទិន្នន័យនឹងត្រូវដាក់កូដដែលមានសម្រាប់តែសមាជិករបស់ក្រុមការងារស្រាវជ្រាវ ហើយនឹងត្រូវបានធានានៅគ្រប់ដំណាក់កាលទាំងអស់ ដំណាក់កាលប្រមូលទិន្នន័យ ការរក្សាទុក ការទាញយក និងការប្រើប្រាស់។

ប្រធានក្រុមការងារស្រាវជ្រាវនឹងចេញរបាយការណ៍ស្តីពីការគ្រប់គ្រងគម្រោងប្រកបដោយក្រមសីលធម៌ នៅក្នុងរបាយការណ៍សំខាន់ៗចុងក្រោយដែលផ្តល់ជូនដល់កម្មវិធី ACCESS។

ក្រុមការងារស្រាវជ្រាវនឹងរាយការណ៍យ៉ាងត្រឹមត្រូវ និងមានការបកស្រាយដោយយុត្តិធម៌ ដោយអនុវត្តតាមវិធីសាស្ត្រស្រាវជ្រាវ និងការវិភាគយ៉ាងម៉ត់ចត់។

ការព្រមព្រៀងគោរពតាមក្រមសីលធម៌ ដែលបានបង្កើតឡើងសម្រាប់គម្រោងនេះ៖ ការវិភាគស្ថានភាព៖ ការផ្តល់ជូនជនមានអូទីហ្សឹម( Autistic Spectrum Disorders ) នៅកម្ពុជា

**សូមចំណាំ៖** រាល់សមាជិកក្រុមការងារគម្រោងត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ដោយមានការទទួលដឹងឮដោយតតិយជន និងមានការឯកភាពពីប្រធានក្រុមការងារស្រាវជ្រាវ

ខ្ញុំបាទ/នាងឈ្មោះ ______________________________

បានអាន និងយល់ដឹងអំពីក្រមសីលធម៌ដែលបានរៀបចំឡើងសម្រាប់គម្រោងនេះ និងព្រមព្រៀងគោរពតាមក្រមសីលធម៌នេះក្នុងអំឡុងពេលអនុវត្តគម្រោង។

ខ្ញុំនឹងមិនលាតត្រដាងព័ត៌មានពាក់ព័ន្ធនឹងកម្មវត្ថុនៃការស្រាវជ្រាវនេះ ក្រៅពីក្រុមការងារគម្រោងឡើយ ហើយនឹងការពារសិទ្ធិ និងរក្សាភាពសុចរិតរបស់អ្នកចូលរួមគ្រប់រូប។

ខ្ញុំនឹងរាយការណ៍ភ្លាមៗជូនប្រធានក្រុមការងារស្រាវជ្រាវប្រសិនបើខ្ញុំមានក្តីកង្វល់ទាក់ទងនឹងសុខុមាលភាពរបស់បុគ្គលណាម្នាក់ដែលបានចូលរួមក្នុងគម្រោងនេះ ឬបញ្ហាណាមួយដែលអាចប៉ះពាល់ដល់សិទ្ធិសីលធម៌របស់បុគ្គលឡើយ។

ចុះហត្ថលេខា ______________________________

ទទួលដឹងឮដោយ ______________________________

កាលបរិច្ឆេទ______________________________

# ឧបសម្ព័ន្ធទី៤៖ ឧបករណ៍ស្រាវជ្រាវសម្រាប់អ្នកផ្តល់ និងអ្នកប្រើប្រាស់សេវា

## ការវិភាគស្ថានភាពជនអូទីស្សឹមនៅកម្ពុជា
## កាលវិភាគសម្ភាសន៍ – អ្នកផ្តល់សេវាដល់កុមារ/ក្មេងពេញវ័យដែលមានអូទីស្សឹម

មុនពេលចាប់ផ្តើមកិច្ចសម្ភាសន៍ សូមប្រាកដថា អ្នកផ្តល់កិច្ចសម្ភាសន៍យល់ពីគោលបំណងនៃការសិក្សានេះ និងក្រមសីលធម៌ដែលក្រុមការងារកំពុងអនុវត្ត។

សូមប្រាកដថា អ្នកទទួលបានការយល់ព្រម/ការព្រមព្រៀងជាលាយលក្ខណ៍អក្សរ ឬថតជាសំឡេង មុននឹងចាប់ផ្តើមសម្ភាសន៍។

**ទិន្នន័យប្រជាសាស្ត្រមុនសម្ភាសន៍ដែលត្រូវប្រមូល និងកត់ត្រា មុនធ្វើកិច្ចសម្ភាសន៍**

ឈ្មោះអ្នកសម្ភាស៖

ទីកន្លែងសម្ភាសន៍៖ (ឧ.ខេត្តកំពង់ចាម)

ឈ្មោះបុគ្គលដែលកំពុងផ្តល់កិច្ចសម្ភាសន៍៖

ឈ្មោះអង្គការដែលតំណាងដោយអ្នកឆ្លើយសំណួរសម្ភាសន៍៖

តួនាទីអ្នកឆ្លើយសំណួរសម្ភាសន៍នៅក្នុងអង្គការ៖

សូមព្យាយាមប្រមូលឯកសារណាមួយទាក់ទងនឹងអង្គការ។ ឧ. ខិត្តប័ណ្ណ គោលនយោបាយ និងព្រឹត្តិបត្រព័ត៌មាន។

សូមកត់ត្រាព័ត៌មានលម្អិត ប្រសិនបើអង្គការនោះមានគេហទំព័រ។

### ផ្នែកទី១៖ ព័ត៌មានសាវតារ

១. សូមប្រាប់ខ្ញុំអំពីខ្លួនអ្នក និងសាវតាររបស់អ្នក (គុណវុឌ្ឍិ បទពិសោធន៍)
២. តើអ្នកបាននឹងកំពុងធ្វើការនៅ (សូមបញ្ចូលឈ្មោះអង្គការ) អស់រយៈពេលប៉ុន្មាន?
៣. ចូររៀបរាប់ថា តើការងាររបស់អ្នកមានអ្វីខ្លះ (តើមួយសប្តាហ៍នេះការងារយ៉ាងម៉េចដែរ?)
៤. តើ (សូមបញ្ចូលឈ្មោះអង្គការ) បាននឹងកំពុងប្រតិបត្តិការនៅកម្ពុជាអស់រយៈពេលប៉ុន្មាន?
៥. តើនរណាជាអ្នកដែលកំពុងធ្វើការឱ្យ (សូមបញ្ចូលឈ្មោះអង្គការ), តើពួកគាត់មានតួនាទីអ្វី?

### ផ្នែកទី២៖ សេវាដែលបានផ្តល់ជូន

៦. តើ (សូមបញ្ចូលឈ្មោះអង្គការ) ផ្តល់សេវាអ្វីខ្លះដល់កុមារ/កូនក្មេងមានអូទីស្សឹម?
៧. តើអ្នកផ្តល់សេវានេះនៅតំបន់ណាខ្លះ?

៨. តើសេវារបស់អ្នកទទួលមូលនិធិដោយរបៀបណា?
៩. តើគ្រួសារដែលមានកុមារ/កូនក្មេងមានអូទីស្សឹមចាប់ផ្តើមដឹងអំពីសេវារបស់អ្នកដោយរបៀបណា?
១០. តើនរណាបញ្ជូនកុមារ/កូនក្មេងមានអូទីស្សឹមមកឱ្យអ្នក?
១១. តើមានអ្វីកើតឡើង នៅពេលដែលអ្នកទទួលបានការបញ្ជូន? (ស្វែយល់ពីតារាងពេលវេលា និងនរណាជាអ្នកពាក់ព័ន្ធ)
១២. តើអ្នកទទួលបានការបញ្ជូនប៉ុន្មានដងក្នុងមួយខែ?
១៣. តើអ្នកមិនផ្តល់សេវា ដែលអ្នកចង់ផ្តល់ដែរឬទេ?
១៤. តើអ្នកធ្វើការងារជិតស្និទ្ធជាមួយនាយកដ្ឋាន/ទីភ្នាក់ងាររដ្ឋាភិបាលដែរឬទេ?
១៥. តើអ្នកធ្វើការងារជិតស្និទ្ធជាមួយទីភ្នាក់ងារណាមួយដែលមានការងារស្រដៀងនឹងស្ថាប័នរបស់អក្នដែរឬទេ?
ជជីកសួរបន្ថែមបន្ថែម៖ តើអ្នកអាចផ្តល់ជាឧទាហរណ៍បានទេ?
តើអ្នកជួបប្រទះបញ្ហាប្រឈមអ្វីខ្លះក្នុងការដោះស្រាយតម្រូវការរបស់កុមារ/កូនក្មេងមានអូទីស្សឹម?

## ផ្នែកទី៣៖ ការចូលរួមជាមួយគ្រួសារ

១៦. តើឪពុកម្តាយ/គ្រួសារ/អ្នកមើលថែសង្ឃឹមទទួលបានអ្វីខ្លះពីសេវារបស់អ្នក?
ជជីកសួរបន្ថែម៖ តើអ្នកដឹងដោយរបៀបណា?
១៧. តើគ្រួសារដែលអ្នកធ្វើការជាមួយនោះស្គាល់ច្បាស់ប៉ុនណាអំពីលក្ខណៈនៃអូទីស្សឹម?
ជជីកសួរបន្ថែម៖ តើអ្នកដឹងដោយរបៀបណា?
១៨. តើឪពុកម្តាយទៅរកសេវារបស់អ្នកដោយរបៀបណា (សួរពីមធ្យោបាយដឹកជញ្ជូន)?
១៩. តើអ្នកស្គាល់គ្រួសារដែលនឹងទទួលផលពីសេវារបស់អ្នកដែរឬទេ ប៉ុន្តែតើនរណាខ្លះមិនបាន/មិនអាចទទួលសេវាទាំង នេះ? ជជីកសួរបន្ថែម៖ ប្រសិនបើមែនហេតុអ្វី?

## ផ្នែកទី៤៖ ស្ថានភាពកាន់តែទូលំទូលាយ

២០. តើការផ្តល់ជូនសម្រាប់កុមារ/កូនក្មេងមានអូទីស្សឹមនៅកម្ពុជាមានលក្ខណៈល្អប្រសើរប៉ុនណា?
២១. តើសេវាអ្វីខ្លះដែលអ្នកគិតថា ត្រូវផ្តល់ដែលបច្ចុប្បន្នមិនទាន់មាន?
២២. តើអ្វីជាបញ្ហាប្រឈមដ៏ធំបំផុតដែលគ្រួសារកុមារ/កូនក្មេងមានអូទីស្សឹមនៅកម្ពុជាជួបប្រទះក្នុងពេលបច្ចុប្បន្ន នេះ?
២៣. តើអ្វីទៅជាអាទិភាពរបស់អ្នកក្នុងការអភិវឌ្ឍការផ្តល់ជូនគ្រួសារដែលមានកុមារ/កូនក្មេងមានអូទីស្សឹមនៅកម្ពុជានាពេលបច្ចុប្បន្ន?
ជជីកសួរបន្ថែម៖ តើនរណាគួរផ្តល់សេវានេះ?
២៤. តើអ្វីទៅជាឧបសគ្គដ៏ធំបំផុតក្នុងការលើកកម្ពស់ជីវិតរស់របស់ជនមានអូទីស្សឹម និងគ្រួសាររបស់ពួកគេនៅកម្ពុជា?
២៥. តើអ្នកមានមតិយោបល់អំពីរបៀប ឬវិធីដែលអាចកែលម្អស្ថានភាពរបស់កុមារ/កូនក្មេង និងគ្រួសាររបស់ពួកគេដែរឬទេ?

## ផ្នែកទី៥៖ បិទការអង្កេត

តើមានអ្វីផ្សេងទៀតដែលអ្នកចង់ប្រាប់យើងអំពីអង្គការ ឬបទពិសោធន៍របស់អ្នកក្នុងការធ្វើការជាមួយជនមាន អូទីស្សឹមដែរឬទេ?

**សូមកុំភ្លេចថ្លែងអំណរគុណឪពុកម្តាយ /អ្នកមើលថែ និងផ្តល់ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងដល់ពួកគាត់ផង**

## កាលវិភាគសម្ភាសន៍ – ឪពុកម្ដាយរបស់អ្នកមើលថែកុមារ/ក្មេងពេញវ័យដែលមានអូទីស្សឹម

មុនពេលចាប់ផ្ដើមកិច្ចសម្ភាសន៍ សូមប្រាកដថា អ្នកផ្ដល់កិច្ចសម្ភាសន៍យល់ពីគោលបំណងនៃការសិក្សានេះ និងក្រមសីលធម៌ដែលក្រុមការងារកំពុងអនុវត្ត។

សូមប្រាកដថា អ្នកទទួលបានការយល់ព្រម/ការព្រមព្រៀងជាលាយលក្ខណ៍អក្សរ ឬថតជាសំឡេង មុននឹងចាប់ផ្ដើមសម្ភាសន៍។

**ទិន្នន័យប្រជាសាស្ត្រមុនសម្ភាសន៍ដែលត្រូវប្រមូល និងកត់ត្រា មុនធ្វើកិច្ចសម្ភាសន៍**

ឈ្មោះអ្នកសម្ភាស៖

ទីកន្លែងសម្ភាសន៍៖ (ឧ.ខេត្តកំពង់ចាម)

ឈ្មោះឪពុកម្ដាយ/អ្នកមើលថែ៖

តើឪពុកម្ដាយ/អ្នកមើលថែនោះជាភេទ ប្រុស ឬស្រី?

ឈ្មោះកុមារ/ក្មេងពេញវ័យ៖

តើកុមារ/ក្មេងពេញវ័យនោះភេទប្រុស ឬស្រី?

អាយុកុមារ/ក្មេងពេញវ័យ៖

តើគេធ្វើរោគវិនិច្ឆ័យជាផ្លូវការលើជំងឺអូទីស្សឹមនៅពេលណា?

តើពីមុនមកឪពុកម្ដាយ/អ្នកមើលថែធ្លាប់ឮជំងឺអូទីស្សឹមដែរឬទេ?

### ផ្នែកទី១៖ ព័ត៌មានសាវតារ

១. ប្រាប់ខ្ញុំអំពី (សូមបញ្ចូលឈ្មោះកុមារ/ក្មេងពេញវ័យ) – អនុញ្ញាតឱ្យឪពុក ឬម្ដាយ/អ្នកមើលថែជជែកដោយសេរី និងលើកទឹកចិត្តឱ្យពួកគាត់និយាយទៅតាមអារម្មណ៍ដែលខ្លួនចង់ចែករំលែក។

២. តើ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) មានបងប្អូនប្រុស ឬបងប្អូនស្រីដែរឬទេ?

៣. តើអ្នកកត់សម្គាល់លើកដំបូងឃើញថា (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) មិនមានការលូតលាស់ដូចកុមារផ្សេងទៀតនៅពេលណា?

៤. តើអ្នកបានកត់សម្គាល់លើកដំបូងឃើញមានអ្វីខុសប្លែក?

៥. តើនរណាបានចូលរួមក្នុងការវាយតម្លៃ /ធ្វើរោគវិនិច្ឆ័យ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ)?

៦. តើអ្នកបានទៅទទួលការវាយតម្លៃនេះនៅកន្លែងណា?

៧. តើអ្នកទទួលបានព័ត៌មានអ្វីខ្លះ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យបឋមនេះ?

៨. តើអ្នកបានទទួលដំបូន្មានអំពីអ្នកដែលអាចជួយអ្នកបាន និង (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) ដែរឬទេ?

៩. តើ(សូមប្រើប្រាស់ឈ្មោះកុមារ ក្មេងពេញវ័យ)បានផ្លាស់ប្ដូរច្រើនដែរឬទេ ចាប់តាំងពីធ្វើរោគវិនិច្ឆ័យ/ការវាយតម្លៃដំបូង? ប្រសិនបើមែន៖ ដោយរបៀបណា?

### ផ្នែកទី២៖ ការផ្តល់សេវា

១០. តើ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) បានជួបជាមួយអ្នកចិត្តសាស្ត្រដែរឬទេ?
ប្រសិនបើបាន៖ សាកសួរព័ត៌មានលម្អិតអំពីពេលវេលា? នៅកន្លែងណា? ហេតុអ្វី? និងតើបានលទ្ធផលអ្វីខ្លះ?

១១. តើ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) បានជួបជាមួយអ្នកព្យាបាលការនិយាយ និងភាសា ដែរឬទេ?
ប្រសិនបើបាន៖ សាកសួរព័ត៌មានលម្អិតអំពីពេលវេលា? នៅកន្លែងណា? ហេតុអ្វី? និងតើបានលទ្ធផលអ្វីខ្លះ?

១២. តើ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) បានជួបជាមួយអ្នកព្យាបាលដោយចលនា ដែរឬទេ?
ប្រសិនបើបាន៖ សាកសួរព័ត៌មានលម្អិតអំពីពេលវេលា? នៅកន្លែងណា? ហេតុអ្វី? និងតើបានលទ្ធផលអ្វីខ្លះ?

១៣. តើ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) បានជួបជាមួយគ្រូពេទ្យជំនាញ ដែរឬទេ?
ប្រសិនបើបាន៖ សាកសួរព័ត៌មានលម្អិតអំពីពេលវេលា? នៅកន្លែងណា? ហេតុអ្វី? និងតើបានលទ្ធផលអ្វីខ្លះ?

១៤. តើ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) បានចូលរៀន/ធ្វើការ/ទៅមជ្ឈមណ្ឌលឯកទេសណាមួយដែរឬទេ?
ប្រសិនបើបាន៖ សាកសួរព័ត៌មានលម្អិត ប្រសិនបើបាន៖ តើ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ) ចង់ចូលរួមនៅមណ្ឌលនោះ ដែរឬទេ?

១៥. តើអ្នកទទួលការគាំទ្រពីអង្គការឯកទេសណាមួយដែលមានមុខជំនាញខាងអូទីស្សឹមដែរឬទេ?
ប្រសិនបើបាន៖ សាកសួរព័ត៌មានលម្អិត (តើពួកគាត់ផ្តល់ការគាំទ្រអ្វីខ្លះ? នៅកន្លែងណា? ញឹកញាប់ប៉ុនណា?)
ប្រសិនបើមិនបាន៖ តើអ្នកចង់បានការគាំទ្របែបនេះដែរឬទេ?

១៦. តើអ្នកស្គាល់អង្គការឯកទេសណាមួយនៅក្នុងតំបន់របស់អ្នកដែរឬទេ?
ប្រសិនបើស្គាល់៖ សាកសួរព័ត៌មានលម្អិត

១៧. តើអ្វីដែលជាបញ្ហាប្រឈមដ៏ធំបំផុតដែលអ្នកធ្លាប់ជួបប្រទះក្នុងនាមជាឪពុកម្តាយ/អ្នកមើលថែរបស់ (សូមប្រើប្រាស់ឈ្មោះកុមារ ក្មេងពេញវ័យ)?

១៨. តើអ្នកទទួលបានការគាំទ្រអ្វីខ្លះពីគ្រួសាររបស់អ្នក?

### ផ្នែកទី៣៖ បំណងប្រាថ្នា

១៩. តើអ្នក ចង់ឃើញគេផ្តល់អ្វីខ្លះនាពេលអនាគត សម្រាប់ (សូមប្រើប្រាស់ឈ្មោះកុមារ/ក្មេងពេញវ័យ)?

២០. តើអ្នកគិតថា នរណាគួរតែផ្តល់សេវាទាំងនោះ?

២១. តើនរណាជាបុគ្គលដែលអ្នកគិតថា អាចផ្តល់ការគាំទ្រដ៏ធំជេងបំផុតដល់ឪពុកម្តាយ/អ្នកមើលថែកុមារ ឬកូនក្មេងមានអូទីស្សឹម?

### ផ្នែកទី៤៖ បិទការអង្កេត

តើមានអ្វីផ្សេងទៀតដែលអ្នកចង់ប្រាប់យើងអំពីបទពិសោធន៍របស់អ្នកក្នុងការធ្វើជាឪពុកម្តាយ /អ្នកមើលថែកុមារ/កូនក្មេងអូទីស្សឹមដែរឬទេ?

**សូមកុំភ្លេចថ្លែងអំណរគុណឪពុកម្តាយ /អ្នកមើលថែ និងផ្តល់ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងដល់ពួកគាត់ផង**

**សេចក្ដីបន្ថែមទី៥: សៀវភៅណែនាំអំពីរោគវិនិច្ឆ័យ និងស្ថិតិនៃវិបត្តិផ្លូវចិត្ត បោះពុម្ពលើកទីប្រាំ (DSM-5), និយមន័យនៃវិបត្តិវិសាគមអូទីស្សឹម**

ដើម្បីបំពេញតាមលក្ខណវិនិច្ឆ័យនៃរោគវិនិច្ឆ័យសម្រាប់អូទីស្សឹម ដែលបានកំណត់នៅក្នុងសៀវភៅណែនាំស្ដីពីរោគវិនិច្ឆ័យ និងស្ថិតិនៃវិបត្តិផ្លូវចិត្ត ការបោះពុម្ពលើកទីប្រាំ (DSM-5) កុមារត្រូវតែមានកង្វះខាតក្នុងរយៈពេលវែងនូវរោគវិនិច្ឆ័យនីមួយៗ ក្នុងចំណោមរោគវិនិច្ឆ័យចំនួនបីនៃការប្រាស្រ័យទាក់ទងសង្គម និងអន្តរកម្ម (សូមមើលចំនុច ក.១. ដល់ ក.៣. ខាងក្រោម) បូកបន្ថែមនឹងឥរិយាបថរឹតត្បិត ដដែលៗ យ៉ាងតិចពីរប្រភេទក្នុងចំណោម ៤ ប្រភេទ (សូមមើល ខ.១. ដល់ ខ.៤. ខាងក្រោម) ។

**ក. កង្វះខាតដដែលៗក្នុងការប្រាស្រ័យទាក់ទងសង្គម និងអន្តរកម្មក្នុងសង្គមនៅក្នុងបរិបទជាច្រើន ដូចដែលបង្ហាញឱ្យឃើញដោយកត្តាទាំងឡាយខាងក្រោម ក្នុងពេលបច្ចុប្បន្ន ឬកន្លងមក (នេះគឺគ្រាន់តែជាឧទាហរណ៍មួយចំនួនប៉ុណ្ណោះ មិនគ្រប់ជ្រុងជ្រោយនោះទេ)៖**

១. កង្វះខាតនៃការទំនាក់ទំនងផ្នែកសង្គម និងការបង្ហាញអារម្មណ៍ដូចជា៖ (ឧទាហរណ៍ ខាងក្រោម)
ការទំនាក់ទំនងផ្នែកសង្គមមិនមានភាពប្រក្រតី និងមិនអាចធ្វើការសន្ទនាគ្នាទៅវិញទៅមកធម្មតា មានការថយចុះក្នុងការចែករំលែកនូវចំណង់ចំណូលចិត្ត អារម្មណ៍ ឬសេចក្ដីស្រលាញ់ មានការបរាជ័យក្នុងការផ្ដួចផ្ដើមគំនិត ឬសកម្មភាពអ្វីមួយ ឬការឆ្លើយតបទៅសកម្មភាពណាមួយក្នុងសកម្មភាពប្រចាំថ្ងៃ។

២. កង្វះខាតនៅក្នុងឥរិយាបថប្រាស្រ័យទាក់ទងគ្នាដោយមិនប្រើពាក្យសំដី (ភាសាកាយវិការ) នៅក្នុងសកម្មភាពប្រចាំថ្ងៃដូចជា៖ (ឧទាហរណ៍ ខាងក្រោម)
ភាពបន្សីគ្នារវាងការប្រាស្រ័យទាក់ទងដោយពាក្យសំដី និងមិនប្រើពាក្យសំដី (កាយវិការ) មិនបានល្អ មិនអាចរក្សា ឬប្រើការមើលចំភ្នែកនៅពេលសន្ទនា និងមិនអាចប្រើភាសាកាយវិការបាន (ការទំនាក់ទំនងដោយមិនប្រើពាក្យសំដី) ឬកង្វះការយល់ដឹង និងការប្រើប្រាស់កាយវិការ រហូតដល់ការកង្វះខាតទាំងស្រុងនៃការបញ្ចេញទឹកមុខ និងការប្រាស្រ័យទាក់ទងដោយមិនប្រើពាក្យសំដី ។

៣. កង្វះខាតក្នុងការអភិវឌ្ឍ ការថែរក្សា និងការយល់ដឹងពីទំនាក់ទំនងដូចជា៖ (ឧទាហរណ៍ ខាងក្រោម)
អាចមានចាប់ពីការលំបាកក្នុងសម្របឥរិយាបថឱ្យសមស្របទៅតាមបរិបទសង្គមផ្សេងៗ រហូតដល់ការលំបាកក្នុងការលេងបែបស្រមើស្រមៃជាមួយក្មេងៗដទៃទៀត ឬការរាប់អានមិត្តភក្តិ រហូតដល់កង្វះខាតចំណាប់អារម្មណ៍ក្នុងការរាប់អានមិត្តភក្តិ។

ភាពធ្ងន់ធ្ងរគឺផ្អែកលើកកម្សោយនៃការប្រាស្រ័យទាក់ទងក្នុងសង្គម និងសណ្ឋាននៃឥរិយាបថដែលមានលក្ខណៈរឹតត្បិតដដែលៗ ។

**ខ. លំនាំដដែលៗនៃឥរិយាបថ ចំណាប់អារម្មណ៍ ឬសកម្មភាព ដែលអាចមានយ៉ាងហោចណាស់ពីរចំណុចក្នុងចំណោមចំណុចទាំងឡាយខាងក្រោមនេះ ទាំងក្នុងពេលបច្ចុប្បន្ន ឬពីអតីតកាល (នេះគឺគ្រាន់តែជាឧទាហរណ៍ខ្លះៗប៉ុណ្ណោះមិនពេញលេញទាំងអស់នោះទេ)៖**

១. ចលនាចលករដែលមានលក្ខណៈសើរៗ ឬដដែលៗក្នុងការប្រើប្រាស់វត្ថុ ឬការនិយាយ (ឧ. គំរូចលករសាមញ្ញ ការតម្រៀប ឬត្រលប់ឧបករណ៍ក្មេងលេង ការនិយាយចដដែលៗ ការនិយាយពាក្យចម្លែកៗ)។

២. ការធ្វើអ្វីដដែលៗ ការប្រកាន់ខ្ជាប់នូវទម្លាប់ដែលមិនអាចបត់បែនបាន ឬទម្រង់នៃឥរិយាបថ ពាក្យសំដី ឬកាយវិការ (ឧទា. សម្ដែងទុក្ខព្រួយធំធេងចំពោះការផ្លាស់ប្ដូរឬរឿងរ៉ាវតូចតាច ការលំបាកក្នុងការសម្របខ្លួន ការគិតតូចចង្អៀត មិនបើកចំហរ ការស្វាគមន៍ចម្លែកៗ ត្រូវការដើរលើផ្លូវដដែល ឬញ៉ាំអាហារដដែលជារៀងរាល់ថ្ងៃ)

៣. ចំណាប់អារម្មណ៍ដែលមានការរឹតត្បិតខ្ពស់ ជាប់នឹងមួយកន្លែង ដែលមានលក្ខណៈមិនធម្មតាចំពោះការផ្ដោតអារម្មណ៍ (ឧ. ការជាប់ពាក់ព័ន្ធខ្លាំង ឬជាប់គាំងជាមួយវត្ថុខុសប្រក្រតី ឬដក់អារម្មណ៍ជាប់ហួសហេតុ ទៅលើវត្ថុអ្វីមួយ) ។

៤. ប្រតិកម្មខ្លាំងហួសហេតុ ឬតិចពេកចំពោះការប៉ះពាល់អ្វីមួយលើរាងកាយ (ជាតុចូលលើកាយវិញ្ញាណ) ឬបង្ហាញចំណាប់អារម្មណ៍ខុសធម្មតាចំពោះបរិស្ថានខាងក្រៅដែលទទួលបានឥន្ទ្រីយារម្មណ៍ (ឧទា. ការមិនយកចិត្តទុកដាក់ចំពោះការឈឺចាប់/សីតុណ្ហភាព ការមិនឆ្លើយតបទៅនឹងសំឡេងអ្វីមួយ ឬលក្ខណៈដាក់លាក់ណាមួយ ប្រតិកម្មហួសហេតុចំពោះក្លិន ឬការប៉ះវត្ថុអ្វីមួយ ការចាប់អារម្មណ៍ហួសហេតុនៅពេលឃើញពន្លឺ ឬចលនាអ្វីមួយ។




**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ**
អាសយដ្ឋានៈ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស
សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : +៨៥៥-២៣-៧២៧-៤២៨
ទូរសារ : +៨៥៥-២៣-៧២៧-៤២៨
អ៊ីម៉ែល : info@dac.org.kh
គេហទំព័រ : www.dac.org.kh

**ACCESS**
អាសយដ្ឋានៈ អគារលេខ ២៤០ ជាន់ទី៣
អគារអានីណា ផ្លូវ ២៧១ សង្កាត់បឹងទំពុន
ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : +៨៥៥-១២-៨៧៦-៥៤៩
អ៊ីម៉ែល : info@accesscambodia.org
គេហទំព័រ : www.accesscambodia.org